ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

3

ក្រសួងអប់រំ យុវជន និងកីឡា

ផែនការមេ
ស្តីពី
ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន
រយៈពេលមធ្យម
ឆ្នាំ២០២១-២០២៥

ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន
ទៅកម្រិតបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន

សេចក្តីព្រាងទី៦
ខែកុម្ភៈ ឆ្នាំ២០២១

មាតិកា

១. សារបានគោលនយោបាយ 2

១.១ ការបណ្តុះបណ្តាលគ្រូបង្រៀនក្នុងពិភពលោកដែលប្រែប្រួល 2

១.២ ការបណ្តុះបណ្តាលគ្រូបង្រៀនក្នុងបរិបទតំបន់ 5

១.៣ ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនក្នុងបរិបទកម្ពុជា 6

២. យុទ្ធសាស្ត្រនៃការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន 15

២.១ អាទិភាពក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន 15

២.២ គ្រឹះស្ថានផ្តល់សេវាបណ្តុះបណ្តាលគ្រូបង្រៀន 20

២.៣. ការជ្រើសរើសគ្រូបង្រៀនតាមប្រភេទភូមិសិក្សា 32

២.៤ យុទ្ធសាស្ត្រការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន 36

២.៥ ថវិកាសម្រាប់ការអនុវត្ត 51

២.៦ បញ្ហាប្រឈមនាពេលបច្ចុប្បន្ននិងអនាគត 52

៣. ម៉ាទ្រិចផែនការសកម្មភាពដំឡើងគុណវុឌ្ឍិគ្រូបង្រៀន 60

ឯកសារយោង 69

១. សារបានគោលនយោបាយ

១.១ ការបណ្តុះបណ្តាលគ្រូបង្រៀនក្នុងពិភពលោកដែលប្រែប្រួល

១.១.១ និន្នាការគោលនយោបាយបណ្តុះបណ្តាលគ្រូបង្រៀន

ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ នៅក្នុងប្រព័ន្ធអប់រំនៃប្រទេសកំពុងអភិវឌ្ឍន៍ មានការផ្លាស់ប្តូរពីក្តីបារម្ភក្នុងការទទួលបានការអប់រំ ទៅជាក្តីបារម្ភក្នុងការទទួលបានគុណភាពនៃការអប់រំ។ នៅក្នុងបរិបទនៃការធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំ ប្រសិទ្ធិភាពរបស់គ្រូបង្រៀនបានក្លាយជាប្រធានបទសំខាន់បំផុតក្នុងរបៀបវារៈនៃគោលនយោបាយអប់រំ ដោយសារប្រទេសជាច្រើនជឿជាក់ថា ការបង្រៀនគឺជាកត្តាមួយសំខាន់បំផុតដែលប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្ស (OECD, ២០១១; Darling-Hammond, ២០១៧)។

គោលនយោបាយអប់រំគ្រូបង្រៀនគ្រប់ដណ្តប់នូវសកម្មភាព និងទិដ្ឋភាពទូលំទូលាយដែលផ្តើមចេញពីការបណ្តុះបណ្តាលគ្រូបង្រៀន រយៈពេលសាកល្បងការងារដែលជាអំឡុងពេលមួយគ្រូបង្រៀនចេញថ្មីអាចទទួលបានសមិទ្ធផលពីការណែនាំពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការគ្រប់គ្រងធនធានមនុស្ស ការវាយតម្លៃនិងវឌ្ឍនភាពនៃអាជីព និងប្រាក់ខែនិងប្រាក់លើកទឹកចិត្ត (ធនាគារពិភពលោក ២០១១ យូណេស្កូ ២០១៣)។ រដ្ឋាភិបាលជុំវិញពិភពលោកបានផ្តួចផ្តើមគំនិតផ្សេងៗគ្នា ដែលទទួលបាននូវកម្រិតជោគជ័យខុសៗគ្នា ហើយដោយសារតែភាពខុសគ្នានៃប្រព័ន្ធផ្សេងៗគ្នា ធ្វើឱ្យមានការលំបាកក្នុងការប្រៀបធៀបវឌ្ឍនភាពនៃគំនិតទាំងនេះ។

ទោះបីជាយ៉ាងណាក៏ដោយ ការកំណត់និន្នាការរួមមួយអាចត្រូវបានធ្វើឡើងក្នុងគោលបំណងដ៏មុតមាំនៃការធ្វើកំណែទម្រង់ការអប់រំគ្រូបង្រៀន។ ក្នុងប៉ុន្មានទសវត្សថ្មីៗនេះ កំណែទម្រង់មួយក្នុងចំណោមកំណែទម្រង់ជាច្រើន ផ្តោតលើការពង្រឹងគុណភាពអប់រំដែលពាក់ព័ន្ធនឹងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន។ ក្នុងទសវត្សឆ្នាំ១៩៧០ ប្រទេសជាច្រើនដែលមានគុណផលអប់រំខ្ពស់ បានដាក់ចេញនូវកំណែទម្រង់វិស័យអប់រំដើម្បីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនពីកម្រិតមធ្យមសិក្សាទុតិយភូមិ ទៅកម្រិតបរិញ្ញាបត្រ។ ចាប់ផ្តើមពីទសវត្សឆ្នាំ១៩៨០ ប្រទេសមួយចំនួនបានដំឡើងគុណវុឌ្ឍិគ្រូបង្រៀនពីកម្រិតបរិញ្ញាបត្រ ទៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ក្នុងគោលបំណងបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយវិជ្ជាជីវៈ និងមានគុណភាពប្រសើរជាងមុន។ ប្រទេសទាំងនេះរួមមាន សហរដ្ឋអាមេរិក បណ្តាប្រទេសក្នុងសហគមអឺរ៉ុប សិង្ហបុរី ជប៉ុន និងកូរ៉េ។ ប្រទេសទាំងនេះក៏បានចូលរួមអភិវឌ្ឍស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងបានអភិវឌ្ឍស្តង់ដាថ្នាក់ជាតិរបស់ពួកគេ។ ស្ទើរតែពាក់កណ្តាលនៃប្រទេសសមាជិកអង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍសេដ្ឋកិច្ច (OECD) បានកំណត់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងបានដាក់ចេញនូវប្រព័ន្ធផ្តល់អាជ្ញាបណ្ណគ្រូបង្រៀន (OECD ២០១៥)។

ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនក៏បានចូលរួមក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនផងដែរ។ ទោះបីជាតម្រូវការអប្បបរមាសម្រាប់គ្រូបង្រៀន នៅតែជាកម្រិតមធ្យមសិក្សាឬក្រោយមធ្យមសិក្សា និងមិនមែនជាកម្រិតឧត្តមសិក្សានៅប្រទេសជាច្រើនជាពិសេសបណ្តាប្រទេសនៅតំបន់សាហារា ប្រទេសមួយចំនួនបានដំឡើងគុណវុឌ្ឍិទៅកម្រិតបរិញ្ញាបត្ររងសម្រាប់គ្រូបង្រៀនបឋមសិក្សា និងបរិញ្ញាបត្រសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន។ វិធីជាប្រព័ន្ធសម្រាប់លទ្ធផលការអប់រំល្អប្រសើរជាងមុន(SABER) ដឹកនាំដោយធនាគារពិភពលោកបានកំណត់សូចនាករមួយនៃគោលនយោបាយគ្រូបង្រៀន ដើម្បីវាស់គុណភាពនៃការអប់រំជាស្តង់ដាអប្បបរមាសម្រាប់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សានិងគ្រូបង្រៀនកម្រិតមូលដ្ឋាន។ ទោះបីជាអង្គការអន្តរជាតិធំៗដែលបាន

ចូលរួមក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនបានអះអាងថា តម្រូវការអប្បបរមាសម្រាប់គ្រូបង្រៀនគួរតែជាកម្រិតបរិញ្ញាបត្រ (ធនាគារពិភពលោក ឆ្នាំ២០១៣) ប៉ុន្តែនៅតែមានគន្លាតរវាងគោលដៅគោលនយោបាយ និងអនុវត្តជាក់ស្តែងនៅក្នុងប្រទេសជាច្រើន។

បញ្ហាប្រឈមគឺមិនមែនត្រឹមតែរយៈពេលនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានចំណុចផ្សេងៗទៀតដូចជា៖ ខ្លឹមសារនៃកម្មវិធីបណ្តុះបណ្តាល វិធីសាស្ត្របង្រៀន តុល្យភាពនៃការបង្រៀននិងកម្មសិក្សាគរុកោសល្យ គុណភាពគ្រូឧទ្ទេស កម្រិតសិក្សារបស់គរុសិស្ស។ល។ ការស្ទង់មតិ របស់ SACMEQ បង្ហាញថា រយៈពេលបណ្តុះបណ្តាលគ្រូបង្រៀនតែមួយមុខ មិនអាចធានានូវគុណផលសិក្សារបស់សិស្សបានទេ (ធនាគារពិភពលោក ឆ្នាំ២០០៧)។

បន្ថែមលើនេះទៀត បេក្ខជនបានសម្រេចចិត្តដាក់ពាក្យប្រឡងដើម្បីទទួលការបណ្តុះបណ្តាលជាគ្រូបង្រៀនដោយផ្អែកលើបរិបទដ៏ទូលាយនៃប្រព័ន្ធអប់រំឧត្តមសិក្សានិងទីផ្សារការងារ។ ការទាក់ទាញបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនត្រូវគិតពីបរិបទខាងលើនេះ។ ដើម្បីឱ្យលទ្ធផលនៃការអប់រំប្រសើរឡើង ប្រទេសដែលទទួលជោគជ័យក្នុងការទាក់ទាញនិងរក្សាទុកបេក្ខជនដែលមានគុណសម្បត្តិគ្រប់គ្រាន់បានអនុវត្តតាមគោលការណ៍ខាងលើ ដើម្បីធ្វើជានាថាការបង្រៀនជាវិជ្ជាជីវៈមួយដែលបេក្ខជនពូកែបំផុតបានដាក់ពាក្យចូលសិក្សា បើប្រៀបធៀបទៅនឹងវិជ្ជាជីវៈដូចជាវេជ្ជសាស្ត្រ វិស្វកម្ម និងច្បាប់។ ប្រាក់បៀវត្សជាកត្តាចម្បងក្នុងការទាក់ទាញនិងរក្សាទុកបុគ្គលដែលសក្តិសមនឹងវិជ្ជាជីវៈគ្រូបង្រៀន៖

> តាមទស្សនៈទីផ្សារការងារ ប្រព័ន្ធអប់រំដែលផ្តល់ប្រាក់បៀវត្សគួរឱ្យទាក់ទាញបើប្រៀបធៀបនឹងវិជ្ជាជីវៈប្រហាក់ប្រហែលគ្នានឹងទទួលបានជោគជ័យជាង ក្នុងការទាក់ទាញនិងរក្សាទុកគ្រូបង្រៀនដែលមានសមត្ថភាព។ នៅពេលដែលប្រាក់បៀវត្សមិនបានឆ្លើយតបនឹងកម្រិតនៃការអប់រំរបស់ពួកគាត់ ត្រូវមានការបណ្តុះបណ្តាលនិងការទទួលខុសត្រូវ ឬក៏អនុញ្ញាតឱ្យគ្រូបង្រៀនរស់នៅសមរម្យដោយមិនចាំបាច់ធ្វើការងារទី២ វិជ្ជាជីវៈគ្រូបង្រៀនបាត់បង់កិត្យានុពលភាព ប៉ះពាល់លើការជ្រើសរើស ការលើកទឹកចិត្ត និងការរក្សាទុក (UNESCO ឆ្នាំ២០១៥/២០១៩:២៤)។

កត្តាផ្សេងទៀតដែលរួមចំណែកក្នុងការទាក់ទាញបេក្ខជនឱ្យជ្រើសរើសការបណ្តុះបណ្តាលគ្រូបង្រៀនរួមមានសក្តានុពលនៃវិជ្ជាជីវៈគ្រូបង្រៀនក្នុងការរីកចម្រើនអាជីពនិងការទទួលបាននូវការអភិវឌ្ឍវិជ្ជាជីវៈ ការទទួលបានការងារនិងស្ថានភាពការងារ គោលនយោបាយពង្រាយគ្រូបង្រៀន ការយល់ដឹងរួមគ្នាពីអត្តសញ្ញាណវិជ្ជាជីវៈនិងកិច្ចព្រមព្រៀងពីចំណុចដែលគ្រូបង្រៀនល្អត្រូវមាន វប្បធម៌គណនេយ្យភាពនិងតម្លាភាព និងសំណួរពីការដឹកនាំនិងអភិបាលកិច្ចនៅក្នុងសាលារៀន (យូណេស្កូ ឆ្នាំ២០១៥/២០១៩:២៤)។ ផែនការមេស្តីពីការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនរយៈពេលមធ្យម មានគោលបំណងបង្កើនគុណវុឌ្ឍិគ្រូបង្រៀនទៅកម្រិតបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន គឺស្ថិតនៅក្នុងបរិបទមួយទូលាយ។ ការគាំទ្រគ្រូបង្រៀនដើម្បីដំឡើងគុណវុឌ្ឍិ ត្រូវគិតពីទីផ្សារការងារនិងបរិបទកាន់តែទូលាយ ប្រសិនបើពួកគេនៅតែបន្តអាជីពជាគ្រូបង្រៀននិងដឹងពី សក្តានុពលរបស់ពួកគេថាជាអ្នកអប់រំដែលនឹងនាំឱ្យលទ្ធផលសិក្សាសិស្សពួកគេកាន់តែប្រសើរឡើង។ ដូចនេះ ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនជាយុទ្ធសាស្ត្រមួយក្នុងកំណែទម្រង់គោលនយោបាយគ្រូបង្រៀនទូទៅ ដូចដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន សូមមើលចំណុច១.៣.៣ខាងក្រោម)។

១.១.២ សមត្ថភាពសំខាន់ៗនៅក្នុងសង្គមឌីជីថល

កត្តាសំខាន់មួយក្នុងគោលនយោបាយគ្រូបង្រៀនគឺការកំណត់នូវសមត្ថភាព ដែលគ្រូបង្រៀនត្រូវអភិវឌ្ឍ។ សមត្ថភាពដែលគ្រូបង្រៀនត្រូវមានគួរតែឆ្លើយតបនឹងគោលបំណងនៃការអប់រំកុមារ និងសមត្ថភាពដែលកុមារត្រូវអភិវឌ្ឍនៅក្នុងសាលារៀន (OECD ឆ្នាំ២០០៥ យូណេស្កូ ឆ្នាំ២០១១ ធនាគារពិភពលោក ឆ្នាំ២០១៣)។ ការកំណត់សមត្ថភាពសំខាន់ៗរបស់គ្រូបង្រៀន គឺមានសារៈសំខាន់ណាស់សម្រាប់យុគសម័យបច្ចុប្បន្ននៃការអភិវឌ្ឍយ៉ាងឆាប់រហ័សផ្នែកព័ត៌មានវិទ្យានិងសេដ្ឋកិច្ច។ សមត្ថភាពសំខាន់ៗទាំងនេះប្រែប្រួលទៅតាមអាទិភាពនៃប្រទេសនីមួយៗ ប៉ុន្តែមាននិន្នាការរួមមួយចំនួនលេចចេញជាសកលរួមមាន ការផ្តោតលើការដែលកុមារទទួលបាននូវបំណិនសតវត្សរ៍ទី២១ ដែលជាទូទៅត្រូវគេកំណត់ថាជាការរួមបញ្ចូលគ្នានៃការច្នៃប្រឌិត ការគិតពិចារណា នវានុវត្តន៍ បំណិនអក្ខរកម្មឌីជីថល ការទំនាក់ទំនង ការសហការ មុខរបរនិងបណិនជីវិតជាដើម (OECD ឆ្នាំ២០០៩)។ ការកំណត់នេះគឺដើម្បីគាំទ្រសិស្សរបស់ពួកគេ អាចរស់នៅ និងមានភាពរីកចម្រើននៅក្នុងយុគសម័យឌីជីថលនេះ។ គ្រូបង្រៀនត្រូវតែគាំទ្រសហគមន៍សិក្សា ដែលអាចឱ្យសិស្ស សហការ និងចែករំលែកនូវការអនុវត្តល្អៗ និងការបញ្ចូលបំណិនសតវត្សរ៍ទី២១ ទៅក្នុងការអនុវត្តនៅក្នុងថ្នាក់រៀន។ ការធ្វើបែបនេះនឹងអាចជួយឱ្យសិស្សរៀនពីអ្វីដែលទាក់ទងនឹងបរិបទពិភពលោកជាក់ស្តែង (តាមរយៈការសិក្សាតាមបែបគម្រោង និងការងារអនុវត្តផ្ទាល់)។ ការបង្រៀនដែលមានប្រសិទ្ធភាពខ្ពស់ពីបំណិនសតវត្សរ៍ទី២១ គឺត្រូវការនូវវិធីសាស្រ្តរួមបញ្ចូលគ្នា ដែលអាចឱ្យសិស្សានុសិស្សយល់ដឹងពីរបៀបទទួលបានការវាយតម្លៃ ការសំយោគ និងការរួមចំណែកក្នុងការផ្តល់ព័ត៌មាន។ វាជាការចាំបាច់ក្នុងការផ្តល់ឱកាស ឱ្យសិស្សអនុវត្តបំណិនទាំងនេះលើគ្រប់មុខវិជ្ជា និងនៅក្នុងវិធីរៀនផ្អែកលើសមត្ថភាព។ ក្របខណ្ឌសិក្សារបស់ OECD ២០៣០ ដែលចេញនៅឆ្នាំ២០១៨ នឹងត្រូវប្រើបន្តទៀត និងមានគោលបំណងរួមបញ្ចូលនិងបន្ថែមបំណិនផ្សេងទៀត ដែលលើសពីបំណិនសតវត្សរ៍ទី២១ ដើម្បីទទួលបានការអភិវឌ្ឍប្រកបដោយចីរភាព (OECD ឆ្នាំ២០១៨)។

នៅក្នុងប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានប្រកាសនូវតម្រូវការចាំបាច់ ដើម្បីណែនាំនិងពង្រឹងបំណិនសតវត្សរ៍ទី២១ នៅក្នុងវិស័យអប់រំ ក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្សដែលមានជំនាញខ្ពស់ដើម្បីធ្វើសមាហរណកម្មក្នុងសមាគមអាស៊ាន និងបង្កើតវិស័យសេដ្ឋកិច្ចថ្មីដូចជាអេឡិចត្រូនិក កសិឧស្សាហកម្ម ការដឹកជញ្ជូនក្នុងសម័យឌីជីថល និងដើម្បីសម្រេចនូវគោលដៅជាតិក្នុងការប្រែក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ក្រសួងអប់រំ យុវជន និងកីឡាបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការអប់រំតាមបែបឌីជីថល ក្នុងគោលបំណងប្រើប្រាស់បច្ចេកវិទ្យា ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចនិងសង្គម ក្នុងបរិបទបដិវត្តឧស្សាហកម្ម៤.០ និងការបង្កើតទីក្រុងឆ្លាតវៃ។ ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡាបានគាំទ្រកម្មវិធីសិក្សាតាមបែបបញ្ញត្តិដើម្បីឱ្យសិស្សទទួលបានចំណេះដឹង ជំនាញ និងឥរិយាបថតាមរយៈវិធីបង្រៀននិងរៀនតាមបែបរិះរក រួមទាំងការអនុវត្តកម្មវិធីសិក្សាខាងលើ ការធ្វើអធិការកិច្ចនិងវាយតម្លៃការសិក្សានៅក្នុងថ្នាក់ និងការប្រឡងបញ្ចប់ឆ្នាំសិក្សា (ណារ៉ុន ឆ្នាំ២០១៩)។

លើសពីនេះទៅទៀត ការរីករាតត្បាតនៃជំងឺកូវីដ១៩ដែលបានប៉ះពាល់ដល់ប្រព័ន្ធអប់រំជាសកល ហើយឈានទៅរកការបិទគ្រឹះស្ថានអប់រំស្ទើរតែទាំងស្រុង បានពន្លឿនការអភិវឌ្ឍការបង្រៀននិងរៀនពីចម្ងាយ និងសម្ភារៈបង្រៀននិងរៀនតាមប្រព័ន្ធអេឡិចត្រូនិក ដែលជួយឱ្យការសិក្សារបស់សិស្សនៅបឋមសិក្សា និងមធ្យមសិក្សា សកលវិទ្យាល័យ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននៅតែដំណើរការបន្ត។ ក្រសួងអប់រំ យុវជន

និងកីឡា បានប្រកាសគោលនយោបាយលើកកម្ពស់ការបង្រៀននិងរៀនពីចម្ងាយនៅទូទាំងប្រទេស នៅខែមេសា ឆ្នាំ២០២០ ហើយបានចាត់វិធានការយ៉ាងទូលំទូលាយពាក់ព័ន្ធនឹងការបង្រៀននិងរៀនសិស្សតាមអនឡាញ ចាក់ផ្សាយវីដេអូមេរៀនតាមរយៈYouTube សេវាបណ្តាញសង្គម ទូរទស្សន៍ វិទ្យុ និងបង្រៀននិងរៀននៅក្នុងថ្នាក់សម្រាប់ថ្នាក់មានសិស្សតិចនៅតាមតំបន់ដាច់ស្រយាល ដែលប្រជាជនមានធនធាននិងឱកាសនៅមានកម្រិត។ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដូចជា វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ និងសាលាគរុកោសល្យ បានត្រៀមវីដេអូមេរៀន ហើយចែករំលែកមេរៀនទាំងនោះជាមួយគរុនិស្សិត/គរុសិស្សដែលអាចទាញយកមេរៀនទាំងនោះបានតាមរយៈសេវាបណ្តាញសង្គម ដូច្នេះគ្រូឧទ្ទេសនិងគរុនិស្សិត/គរុសិស្សអាចទំនាក់ទំនងគ្នាបានយ៉ាងងាយស្រួលនិងទៀងទាត់។ នៅក្នុងកាលៈទេសៈបែបនេះ គ្រូឧទ្ទេសត្រូវមានកាតព្វកិច្ចសិក្សាស្វែងយល់ពីរបៀបប្រើប្រាស់ឧបករណ៍ឌីជីថលឱ្យមានប្រសិទ្ធភាព រៀបចំមាតិកាសម្រាប់ការរៀនតាមប្រព័ន្ធអេឡិចត្រូនិក និងទំនាក់ទំនងជាមួយសិស្សតាមសេវាបណ្តាញសង្គម ដែលតាមរយៈនេះគ្រូបង្រៀននិងគ្រូឧទ្ទេសបានសម្របខ្លួនបានយ៉ាងឆាប់រហ័សទៅនឹងការអប់រំតាមបែបឌីជីថល។

១.២ ការបណ្តុះបណ្តាលគ្រូបង្រៀនក្នុងបរិបទតំបន់

រយៈពេលនៃការបណ្តុះបណ្តាលគ្រូបង្រៀនកំពុងកើនឡើង ដើម្បីឱ្យស្របនឹងនិន្នាការសកលលោកនាពេលបច្ចុប្បន្ន។ ក្នុងចំណោមប្រទេសសមាជិកអាស៊ានទាំង១០ មានប្រទេសសមាជិកចាស់ចំនួន៦ ដែលមានកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សានៅកម្រិតបរិញ្ញាបត្រឬខ្ពស់ជាងនេះ (យូណេស្កូឆ្នាំ២០១៤ ធនាគារពិភពលោកឆ្នាំ២០១៥ OECD/យូណេស្កូឆ្នាំ២០១៦)។ ប្រទេសសមាជិកថ្មីៗ និងប្រទេសដែលមានសេដ្ឋកិច្ចមិនទាន់រឹងមាំដូចជា ប្រទេសកម្ពុជា ឡាវ ភូមា និងវៀតណាម ក៏បានបើកដំណើរការបណ្តុះបណ្តាលគ្រូបង្រៀនរយៈពេល៤ឆ្នាំ សម្រាប់គ្រូបង្រៀនបឋមសិក្សា (JICA ឆ្នាំ២០១៥ Nomura, J. et al, ឆ្នាំ២០១៩ Nguyen ឆ្នាំ២០០៨)។ ក្នុងនោះប្រទេសភូមាបានចាប់ផ្តើមកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត ១១+៤ នៅចុងឆ្នាំ២០១៩ ហើយគ្រោងនឹងផ្លាស់ប្តូរទៅ ១២+៤ នៅបំណាច់ឆ្នាំ២០២៣។ ភាគច្រើននៃបណ្តាប្រទេសទាំងនេះ ក៏បណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សាតាមរូបមន្តផ្សេងទៀតដែរជាមួយនឹងកម្មវិធីបណ្តុះបណ្តាល ៤ ឆ្នាំ ដូចជា ៩+៣ និង១២+២ ហើយប្រទេសប្រុយណេបានកំណត់យកបរិញ្ញាបត្រជាន់ខ្ពស់ជាលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់អាជីពគ្រូបង្រៀន (Jawawi, R. et al., ឆ្នាំ២០១៤) ដែលជាលក្ខខណ្ឌខ្ពស់បំផុតនៅក្នុងតំបន់អាស៊ាន។ ដោយសារតម្រូវការគុណវុឌ្ឍិសម្រាប់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ស្មើឬខ្ពស់ជាងគុណវុឌ្ឍិគ្រូបង្រៀនបឋមសិក្សា បណ្តាប្រទេសអាស៊ានទាំងអស់មានកម្មវិធីបណ្តុះបណ្តាលរយៈពេល ៤ឆ្នាំ ដើម្បីក្លាយជាគ្រូបង្រៀនកម្រិតមូលដ្ឋាន។

ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពគឺប្រែប្រួលទៅតាមប្រទេសនីមួយៗ ហើយប្រទេសមួយចំនួនបង្ហាញនូវឥរិយាបថស្ទាក់ស្ទើរចំពោះតម្រូវការគុណវុឌ្ឍិអប្បបរមាសម្រាប់គ្រូបង្រៀន។ ឧទាហរណ៍ នៅប្រទេសថៃ រយៈពេលនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបានកើនឡើងពី៤ ទៅ៥ឆ្នាំ ក្នុងឆ្នាំ២០០២ ក្នុងគោលបំណងពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន។ ជាលទ្ធផល ប្រទេសថៃបានក្លាយជាប្រទេសដែលមានចំនួនគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រ និងគ្រូបង្រៀនមធ្យមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ច្រើនជាងគេក្នុងចំណោមប្រទេសអាស៊ាន (Ingersoll ឆ្នាំ២០០៧)។ ទោះបីជាយ៉ាងណាក៏ដោយ រយៈពេលនៃការបណ្តុះបណ្តាលត្រូវបានពិនិត្យឡើងវិញនាពេលថ្មីៗនេះនៅប្រទេសថៃ ហើយក្រុមប្រឹក្សាគ្រូ

បង្រៀនថៃបានឯកភាពក្នុងការផ្លាស់ប្តូរទៅរយៈពេល៤ឆ្នាំវិញនៅឆ្នាំ២០១៧។ សព្វថ្ងៃនេះគេជឿជាក់ថា កម្មវិធីបណ្តុះបណ្តាលដែលមានគុណភាព គឺជាកម្មវិធីដែលអាចផលិតគ្រូបង្រៀនប្រកបដោយគុណភាពក្នុងរយៈពេល៤ឆ្នាំ ប្រសិនបើប្រទេសនោះអាចទាក់ទាញគរុនិស្សិតដែលមានកម្រិតសិក្សាខ្ពស់នៅក្នុងដំណាក់កាលចុះឈ្មោះចូលរៀន (Nomura et al. ឆ្នាំ២០១៩)។

នៅប្រទេសឥណ្ឌូណេស៊ី ច្បាប់ស្តីពីគ្រូបង្រៀននិងសាស្រ្តាចារ្យ (ឆ្នាំ២០០៥) តម្រូវឱ្យគ្រូបង្រៀនទាំងអស់មានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រ ដែលបានរួមចំណែកក្នុងការបង្កើនចំនួនគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រ ពី១៧ភាគរយក្នុងឆ្នាំ២០០៦ ទៅដល់៩៥ភាគរយក្នុងឆ្នាំ២០១២ (ធនាគារពិភពលោក ឆ្នាំ២០១៥)។ លើសពីនេះទៀត រដ្ឋាភិបាលឥណ្ឌូណេស៊ីបានដាក់ចេញនូវកម្មវិធីវិញ្ញាបនបត្រគ្រូបង្រៀន ក្នុងឆ្នាំ២០០៧ សម្រាប់គ្រូបង្រៀនដែលមានសញ្ញាបត្រទាបបំផុតកម្រិតបរិញ្ញាបត្រ និងជាបុគ្គលិកអចិន្ត្រៃយ៍ ក្នុងគោលបំណងបង្កើនគុណភាពគ្រូបង្រៀន។ គ្រូបង្រៀនដែលបានបញ្ចប់កម្មវិធីនេះដោយជោគជ័យ ទទួលបាននូវប្រាក់ឧបត្ថម្ភវិជ្ជាជីវៈ ដែលស្មើនឹងប្រាក់ខែគោលរបស់ពួកគាត់។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវដោយធនាគារពិភពលោកបានបង្ហាញថា គ្រូបង្រៀនដែលមានបរិញ្ញាបត្រមិនមានសមត្ថភាពខ្ពស់ជាងគ្រូបង្រៀនដែលគ្មានបរិញ្ញាបត្រប៉ុន្មានទេ ជាពិសេសវាជាការពិតសម្រាប់គ្រូបង្រៀនបឋមសិក្សា ហើយគ្រូបង្រៀនដែលមានចំណេះដឹងឯកទេសគ្រប់គ្រាន់ ល្អជាងគ្រូបង្រៀនដែលមានផលវិបាកសូម្បីលើលំហាត់មូលដ្ឋានគណិតវិទ្យា (ធនាគារពិភពលោកឆ្នាំ២០១៥)។

១.៣ ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនក្នុងបរិបទកម្ពុជា

១.៣.១ សារបាន

ផ្នែកនេះបង្ហាញពីបរិបទគោលនយោបាយក្នុងប្រទេសកម្ពុជា និងគោលនយោបាយផ្សេងៗគ្នាដែលទាក់ទងនឹងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន។ ការបង្រៀនត្រូវទាក់ទាញបេក្ខជនដែលល្អបំផុតឱ្យចូលក្នុងអាជីពគ្រូបង្រៀនគឺជាផ្នែកមួយនៃចលករវិជ្ជាជីវៈគ្រូបង្រៀន ដែលចាំបាច់ក្នុងការអភិវឌ្ឍគុណភាពនៃការបង្រៀននិងរៀនជាទូទៅ។ ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនជាផ្នែកសំខាន់មួយនៃកិច្ចខិតខំប្រឹងប្រែងនេះ។ នៅក្នុងបរិបទប្រទេសកម្ពុជាមានទិដ្ឋភាពចំនួន២ នៃការការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនៈ (១) គឺការដំឡើងប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនដែលមានស្រាប់ពី១២+២ ទៅ១២+៤ និង(២) ការដំឡើងគុណវុឌ្ឍិអប់រំរបស់គ្រូបង្រៀនកំពុងបម្រើការងារ ដែលមានសញ្ញាបត្រ១២+២ ទៅកម្រិតបរិញ្ញាបត្រតាមរយៈកម្មវិធីរ៉ឺក្រឹតការ។

គ្រូបង្រៀនក្នុងប្រទេសកម្ពុជាភាគច្រើនរហូតដល់កម្រិតមធ្យមសិក្សាបឋមភូមិ ពុំទាន់មានបរិញ្ញាបត្រលើជំនាញបង្រៀននៅឡើយនាពេលបច្ចុប្បន្ន។ ទោះបីជាគ្រូបង្រៀនមត្តេយ្យសិក្សាចំនួន៤០៨នាក់ និងគ្រូបង្រៀនបឋមសិក្សាចំនួន៥,៤៥០នាក់ មានបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្របណ្ឌិតក្នុងឆ្នាំសិក្សា ២០១៩-២០២០ដូចតារាង១.១ខាងក្រោមបង្ហាញក៏ដោយ ជំនាញដែលពួកគាត់បានសិក្សាទំនងជាមិនទាក់ទងនឹងការបង្រៀន ពីព្រោះមិនមានគ្រឹះស្ថានឧត្តមសិក្សាណាមួយនៅប្រទេសកម្ពុជាបើកបង្រៀនបរិញ្ញាបត្រឯកទេសអប់រំគ្រូបង្រៀននៅឡើយ។ តារាង១.១ បង្ហាញថា មានបេក្ខជនចំនួន១៧,៩៨៥នាក់ មានបរិញ្ញាបត្រនៅកម្រិតមធ្យមសិក្សា ប៉ុន្តែចំនួននេះរួមបញ្ចូលទាំង (១) គ្រូបង្រៀនកម្រិតមូលដ្ឋានដែលបញ្ចប់ ១២+២ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ បន្ទាប់មកទទួលបានបរិញ្ញាបត្រពីសកលវិទ្យាល័យឯកជនក្នុងស្រុក និង (២) គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ បញ្ចប់ថ្នាក់បរិញ្ញាបត្រ+១ នៅវិទ្យាស្ថានជាតិអប់រំ។ ដូច្នេះវាមិនច្បាស់

ទេថាគ្រូបង្រៀនកម្រិតមូលដ្ឋានដែលមានបរិញ្ញាបត្រ ឬកម្រិតសញ្ញាបត្រខ្ពស់ជាងនេះមានចំនួនប៉ុន្មាន សូម្បីតែសញ្ញាបត្ររបស់ពួកគាត់ទំនងជាមិនមានឯកទេសខាងបង្រៀននិងរៀនឡើយ។

តារាង ១.១ កម្រិតអប់រំនៃបុគ្គលិកបង្រៀនក្នុងឆ្នាំសិក្សា ២០១៩-២០២០

កម្រិតអប់រំ	បឋមសិក្សា	អនុវិទ្យាល័យ	វិទ្យាល័យ	បរិញ្ញាបត្រ	បរិញ្ញាបត្រជាន់ខ្ពស់	បណ្ឌិត	សរុប
មត្តេយ្យសិក្សា	២៣៨	១,៥៦៩	៣,០៦៨	៥៣០	១១	១	៥,៤១៧
បឋមសិក្សា	១,៤២៨	១០,០៦២	២៦,៩០៤	៦,២៥៦	២៣០	៤	៤៤,៨៨៤
មធ្យមសិក្សា	៨១៦	៥,៧១១	១៦,៤៦៥	១៨,៤២០	១,៣០២	១៨	៤២,៧៣២
សរុប	២,៤៨២	១៧,៣៤២	៤៦,៤៣៧	២៥,២០៦	១,៥៤៣	២៣	៩៣,០០៣

ប្រភព៖ ក្រសួងអប់រំ (ឆ្នាំ២០២០) សូចនាករនិងស្ថិតិអប់រំ ឆ្នាំ២០១៩-២០២០

ម្យ៉ាងវិញទៀត មានតែស្ថាប័នមួយចំនួនប៉ុណ្ណោះដែលអាចផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រ ឬខ្ពស់ជាងនេះ ក្នុងនោះវិទ្យាស្ថានជាតិអប់រំបានផ្តល់ការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ+១ សម្រាប់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបងផ្តល់ការបណ្តុះបណ្តាល ១២+៤ សម្រាប់គ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋាន និងវគ្គរឹក្រឹតការជូនគ្រូឧទ្ទេសសាលាគរុកោសល្យ និងរឹក្រឹតការខេត្ត ដើម្បីដំឡើងគុណវុឌ្ឍិរបស់ពួកគាត់ពីកម្រិត ១២+២ ទៅកម្រិតបរិញ្ញាបត្រ តាមរយៈគម្រោងពង្រឹងកម្មវិធីអប់រំនៅកម្ពុជា (STEPCam) ដែលគាំទ្រដោយអង្គការយូណេស្កូ ហើយសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (TUP) ជាផ្នែកមួយនៃគម្រោងពង្រឹងការអប់រំមធ្យមសិក្សា (SEIP) ដែលផ្តល់មូនិធិដោយធនាគារពិភពលោក ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនបឋមសិក្សាចំនួន២០០០នាក់ ពីកម្រិត១២+២ ទៅកម្រិតបរិញ្ញាបត្រ។

ដូចបានលើកឡើងខាងលើ មានគ្រូបង្រៀនបឋមសិក្សាចំនួន៤៥,៨៣៦នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន២៨,៧៥៨នាក់ នៅក្នុងឆ្នាំសិក្សា២០១៩-២០២០ (ក្រសួង អ.យ.ក ឆ្នាំ២០២០)[1]។ កម្មវិធីលើកកម្ពស់គុណវិឌ្ឍិគ្រូបង្រៀន (TUP) ខាងលើបានរួមចំណែក ក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនប្រមាណជា៧ភាគរយនៃគ្រូបង្រៀនកម្រិតមូលដ្ឋាន។ ទោះបីជាវិទ្យាស្ថានគរុកោសល្យទាំងពីរត្រូវបានរំពឹងថានឹងបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សាចំនួន៣០០នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន២០០នាក់តាមរយៈការបណ្តុះបណ្តាលតាមប្រព័ន្ធ១២+៤ ដែលមានចំនួនត្រឹមតែ ០.៦ភាគរយ និង០.៧ភាគរយនៃគ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋាន។ ដោយសារការបណ្តុះបណ្តាលតាមប្រព័ន្ធ ១២+៤ នៅវិទ្យាស្ថានគរុកោសល្យគឺជាយន្តការអចិន្ត្រៃយ៍តែមួយគត់ដែលអាចជួយបង្កើនចំនួនគ្រូបង្រៀនមានបរិញ្ញាបត្រអប់រំ ដូចនេះវាជាតម្រូវការបន្ទាន់ក្នុងការបង្កើតយន្តការផ្សេងទៀតដើម្បីជួយពន្លឿនដំណើរការដំឡើងគុណវិឌ្ឍិគ្រូបង្រៀន ដែលនឹងមិនធ្វើឱ្យប្រទេសកម្ពុជាដើរពីក្រោយបណ្តាប្រទេសអាស៊ានក្នុងការអភិវឌ្ឍគ្រូបង្រៀនឡើយ។

---

[1] ចំនួននេះត្រូវបានដកស្រង់ពី សូចនាករនិងស្ថិតិអប់រំ ឆ្នាំ២០១៩-២០២០ "តារាងទី១.សាលារៀន ថ្នាក់ សិស្ស និងបុគ្គលិក" (ទំព័រទី១)។

១.៣.២ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣

គោលនយោបាយ យុទ្ធសាស្ត្រ និងគោលដៅពាក់ព័ន្ធនឹងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ដែលចែង នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ត្រូវបានសង្ខេបនៅក្នុងប្រអប់១.១។ ផែនការ យុទ្ធសាស្ត្រនេះបង្ហាញគំរូមួយចំនួនសម្រាប់ពន្លឿនការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដូចជា៖ អនុវត្តកម្មវិធីអភិវឌ្ឍ វិជ្ជាជីវៈជាប្រចាំរយៈពេលវែង និងរយៈពេលខ្លី សាកល្បងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រ+១ និងបង្កើន ចំនួនវិទ្យាស្ថានគរុកោសល្យដោយប្រែក្លាយសាលាគរុកោសល្យទៅជាវិទ្យាស្ថានគរុកោសល្យ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ បានកំណត់នូវចំនួនគោលដៅសម្រាប់ការដំឡើង គុណវុឌ្ឍិគ្រូបង្រៀន ដូចបានបង្ហាញនៅក្នុងប្រអប់១.១។ ដើម្បីសម្រេចគោលដៅនេះ តម្រូវឱ្យមានសកម្មភាព ជាបន្ទាន់ដើម្បីរៀបចំផែនការអនុវត្ត និងបែងចែកថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តកម្មវិធីមួយចំនួនតាមរយៈគំរូ ដែលបានរៀបរាប់មកខាងលើ។ គួរចងចាំថា មានគ្រូបង្រៀនបឋមសិក្សាប្រហែល ៤៥,០០០នាក់ និងគ្រូបង្រៀន កម្រិតមូលដ្ឋានប្រហែល ២៨,០០០នាក់ (ក្រសួងអប់រំឆ្នាំ២០២០) នៅឆ្នាំសិក្សា ២០១៩-២០២០។ ដូច្នេះ ដើម្បីសម្រេចគោលដៅ ៧ភាគរយនៃគ្រូបង្រៀនបឋមសិក្សា និង១៥ភាគរយនៃគ្រូបង្រៀនកម្រិតមូលដ្ឋានមាន សញ្ញាបត្របរិញ្ញាបត្រ គ្រូបង្រៀនថ្មីមានសញ្ញាបត្របរិញ្ញាបត្រចំនួនច្រើនជាង៣,២០០នាក់ និង២,៣០០នាក់ នឹងត្រូវទទួលការបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិត្រឹមឆ្នាំ២០២៣។

ប្រអប់១.១ ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣

****

លទ្ធផលសូចនាករ និងគោលដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣

អនុវិស័យបឋមសិក្សា(ទំព័រ ២៨)

#	សូចនាករ	ឆ្នាំគោល ២០១៨	ចំណុចដៅ ២០២៣
២១	ភាគរយនៃគ្រូបង្រៀនបឋមសិក្សាដែលបានបញ្ចប់បរិញ្ញបត្រនៅវិទ្យាស្ថានគរុកោសល្យ	0.0%	៧.0%

អនុវិស័យមធ្យមសិក្សា (ទំព័រ ៣៥)

#	សូចនាករ	ឆ្នាំគោល ២០១៨	ចំណុចដៅ ២០២៣
២៣	ភាគរយនៃគ្រូមធ្យមសិក្សាបឋមភូមិដែលបញ្ចប់បរិញ្ញបត្រតាមរយៈកម្មវិធីអប់រំគ្រូបង្រៀន	៦.៧%	១៥.0%

****

៣.២. អនុវិស័យបឋមសិក្សា

យុទ្ធសាស្ត្រ២.២៖ ពង្រឹងគុណភាពនៃវគ្គវិក្រឹតការគ្រូបង្រៀនបឋមសិក្សា

- អភិវឌ្ឍ និងអនុវត្តទាំងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលវែង និងរយៈពេលខ្លីក្នុងគោលបំណងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន(ទំព័រ ៣០)
****
៤.៤. កំណែទម្រង់ការបណ្ដុះបណ្ដាលគ្រូបង្រៀននៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ - ប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទៅជាវិទ្យាស្ថានគរុកោសល្យមានគុណភាពខ្ពស់(ទំព័រ ៥៩) - អភិវឌ្ឍគោលនយោបាយស្ដីពីវិទ្យាស្ថានគរុកោសល្យ បង្កើតផែនការមេនៃការអភិវឌ្ឍវិទ្យាស្ថានគរុកោសល្យ ដោយពិនិត្យឡើងវិញពីតួនាទី និងភារកិច្ច/ឈ្មោះនានា និងផែនទីតម្រង់ផ្លូវសាលាគរុកោសល្យឱ្យក្លាយជាវិទ្យាស្ថានគរុកោសល្យ (ទំព័រ ៥៩) ************************ យុទ្ធសាស្ត្រសំខាន់ទី៤៖ កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើនគុណវុឌ្ឍិនៃការបណ្ដុះបណ្ដាលគ្រូបង្រៀន ១.១២ ដាក់សំណើថវិកាជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីឱ្យគ្រូបង្រៀនដែលមានស្រាប់អាចលើកកម្ពស់សមត្ថភាពពី១២+២ ទៅ១២+៤។ (ទំព័រ ១០៣) ១.១៣ សាកល្បងកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀន បរិញ្ញាបត្រ+១ ដោយគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូដែលមានស្តង់ដាដើម្បីដោះស្រាយបញ្ហាខ្វះគ្រូបង្រៀន។ (ទំព័រ ១០៣)

១.៣.៣. គោលនយោបាយស្ដីពីគ្រូបង្រៀនផែនការសកម្មភាព

គោលនយោបាយស្ដីពីគ្រូបង្រៀនផែនការសកម្មភាពត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥ ក្រោមផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ហើយនៅតែជាស្នូលសម្រាប់ការអភិវឌ្ឍគ្រូបង្រៀន។ ខណៈដែលយុទ្ធសាស្ត្រមួយចំនួននៃគោលនយោបាយស្ដីពីគ្រូបង្រៀនផែនការសកម្មភាពដូចជា ការដាក់ឱ្យដំណើរការវិទ្យាស្ថានគរុកោសល្យនៅរាជធានីភ្នំពេញ និងខេត្តបាត់ដំបង សម្រាប់ការបណ្ដុះបណ្ដាល១២+៤ ត្រូវបានអនុវត្តយ៉ាងជោគជ័យ ការពិនិត្យឡើងវិញ និងវិភាគពីផែនការសកម្មភាពនេះ (ឆ្នាំ២០១៩) បានបង្ហាញថាចំណុចជាច្រើនមិនទាន់បានបញ្ចប់ ហើយបញ្ហាចម្បងគឺបណ្ដាលមកពីកង្វះខាតហិរញ្ញវត្ថុ និងធនធានមនុស្ស។ ពាក់ព័ន្ធនឹងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ សកម្មភាពនៃគោលនយោបាយស្ដីពីគ្រូបង្រៀនផែនការសកម្មភាព ដែលមាននៅក្នុងតារាង១.២ គឺមិនទាន់បានអនុវត្តនៅឡើយទេ។

ដូចដែលបានឃើញនៅក្នុងតារាង គោលនយោបាយស្ដីពីគ្រូបង្រៀនផែនការសកម្មភាពគ្រោងនឹងដាក់ឱ្យអនុវត្តសាកល្បងគំរូការបណ្ដុះបណ្ដាលបរិញ្ញាបត្រ+១ នៅតាមគ្រឹះស្ថានឧត្តមសិក្សា និងវិទ្យាស្ថានគរុកោសល្យ និងកម្មវិធីវិក្រឹតការដើម្បីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនឱ្យដល់កម្រិតបរិញ្ញាបត្រ ឬក៏ខ្ពស់ជាងនេះ ទោះបីជា ការបណ្ដុះបណ្ដាលបរិញ្ញាបត្រ+១ មិនទាន់ត្រូវបានពិភាក្សាយ៉ាងហ្មត់ចត់នៅក្នុងក្រសួងអប់រំ យុវជន និងកីឡាយ៉ាងណាក៏ដោយ។ ផែនការសកម្មភាពនេះក៏បានកំណត់នូវគោលដៅក្នុងការជ្រើសរើសបេក្ខជនមានបរិញ្ញាបត្រជាន់ខ្ពស់ចំនួន១,០០០នាក់ មកធ្វើជាគ្រូឧទ្ទេស ជាពិសេសគឺទាក់ទាញគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិដែលមានបរិញ្ញាបត្រជាន់ខ្ពស់មកចូលរួមក្នុងការបណ្ដុះបណ្ដាលគ្រូបង្រៀន។ ទោះបីជាយ៉ាង

ណាក៏ដោយ វិទ្យាស្ថានគរុកោសល្យមានបញ្ហាប្រឈមដោយសារខ្វះគ្រូឧទ្ទេស (ឧទាហរណ៍ បេក្ខជនដែលមានបរិញ្ញាបត្រជាន់ខ្ពស់ មានបទពិសោធន៍ក្នុងការបង្រៀនគ្រប់គ្រាន់ មានជំនាញព័ត៌មានវិទ្យា និងភាសាអង់គ្លេស...)។ បេក្ខជនមានបរិញ្ញាបត្រជាន់ខ្ពស់ប្រហែលជាមិនមានឆន្ទៈទៅបម្រើការនៅសាលាគរុកោសល្យ និងវិក្រឹតការ ឬមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនោះទេ។ ដូច្នេះទាមទារឱ្យមានកំណែទម្រង់ចាំបាច់ដើម្បីលើកទឹកចិត្តដល់បុគ្គលមានសមត្ថភាពមកបម្រើការនៅក្នុងវិស័យអប់រំ។

តារាង១.២ សកម្មភាពដែលមិនទាន់បានអនុវត្តទាក់ទងនឹងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀននៅក្នុងគោលនយោបាយស្តីពីគ្រូបង្រៀនផែនការសកម្មភាព

	កិច្ចការ/សកម្មភាព	សូចនាករ
យុទ្ធសាស្ត្រទី២៖ ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈគ្រូបង្រៀន		
២.៣.១.១	បង្កើតច្រកចូលដើម្បីធ្វើជាគ្រូបង្រៀនដោយបើកទូលាយការបណ្តុះបណ្តាលបេក្ខជនបរិញ្ញាបត្រនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងគ្រឹះស្ថានឧត្តមសិក្សាឯកជនឱ្យទទួលបានអាជ្ញាបណ្ណគ្រូបង្រៀន	• ចំនួនអ្នកមានបរិញ្ញាបត្រដែលទទួលបានអជ្ញាបណ្ណគ្រូបង្រៀន
២.៤.៣.១	អនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនសាធារណៈតាមរូបមន្តបរិញ្ញាបត្របូក១នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន (មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ) ដោយមានជំនួយបច្ចេកទេសពីគ្រឹះស្ថានឧត្តមសិក្សា ដែលបានបំពេញលក្ខខណ្ឌស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល	• បានអភិវឌ្ឍផែនការបណ្តុះបណ្តាលសាកល្បងតាមរូបមន្តបរិញ្ញាបត្របូក១ • ចំនួនគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដែលបណ្តុះបណ្តាលគ្រូតាមរូបមន្តបរិញ្ញាបត្របូក១ (ភ្នំពេញ និងបាត់ដំបង)
២.៤.៣.២	អនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់គ្រឹះស្ថានឯកជនតាមរូបមន្តបរិញ្ញាបត្របូក១នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដោយមានជំនួយបច្ចេកទេសពីគ្រឹះស្ថានឧត្តមសិក្សា ដែលទទួលស្គាល់ដោយស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដោយផ្តល់សញ្ញាបត្រតែមិនធានាផ្តល់ការងារក្នុងក្របខ័ណ្ឌរដ្ឋទេ	• ចំនួនគ្រឹះស្ថានឧត្តមសិក្សា (ទទួលស្គាល់ដោយស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន) ធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្តបរិញ្ញាបត្របូក១
យុទ្ធសាស្ត្រទី៣៖ កំណត់ស្តង់ដាប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន		
៣.១.២.២	រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានតាមរូបមន្តបរិញ្ញាបត្របូក១ សម្រាប់អ្នកមានបរិញ្ញាបត្រនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដោយផ្តោតលើចិត្តគរុកោសល្យ បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ វិធីសាស្ត្របង្រៀន ភាសាបរទេស គណិតវិទ្យា និងវិទ្យាសាស្ត្រ	• ការកសាងកម្មវិធីបណ្តុះបណ្តាលបានបញ្ចប់

កិច្ចការ/សកម្មភាព		សូចនាករ
៣.១.៣.២	សាកល្បងអនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្តបរិញ្ញាបត្របូក១ នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនចំនួនពីរ(មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ) ដោយប្រើជំនួយបច្ចេកទេសពីគ្រឹះស្ថានឧត្តមសិក្សា	• រៀបចំផែនការសាកល្បង • ការសាកល្បងចាប់ផ្តើមនៅភ្នំពេញនិងបាត់ដំបង
យុទ្ធសាស្ត្រទី៤៖ អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន		
៤.៣.១.២	ជ្រើសរើសគ្រូឧទ្ទេសថ្មីពេញម៉ោងចេញពីចំណោមអ្នកដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឬបណ្ឌិតឬអ្នកដែលមានបទពិសោធន៍បង្រៀនខ្ពស់ ទាំងចំណេះដឹងមុខវិជ្ជា បទពិសោធន៍ បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ភាសាបរទេស និងក្រមសីលធម៌វិជ្ជាជីវៈ)	• គ្រូឧទ្ទេសរើសថ្មីដែលមានគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១០០០នាក់ និងបណ្ឌិតចំនួន ៣០នាក់
យុទ្ធសាស្ត្រទី៦៖ អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ		
៦.១.១.៤	បង្កើតរចនាសម្ព័ន្ធការងារវិក្រឹតការថ្មីមួយនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន (វិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន)	• សាកល្បងរចនាសម្ព័ន្ធការងារវិក្រឹតការនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យនិងវិក្រឹតការរាជធានីភ្នំពេញនិងបាត់ដំបង
៦.១.១.៦	រៀបចំវគ្គវិក្រឹតការការបង្កើនគុណវុឌ្ឍិគ្រូបង្រៀនតាមរូបភាព៖១) វិក្រឹតការជាជំហានៗ (មួយជុំ៣ជំហាន មួយជំហាន១,៥ខែ) ២) វិក្រឹតការរយៈពេលវែង (១ឬ២ឆ្នាំ) និង ៣) វិក្រឹតការតាមប្រព័ន្ធក្រេឌីត ធ្វើនៅនឹងកន្លែងឬតាមការសិក្សាពីចម្ងាយដែលមានការវាយតម្លៃនិងគ្រប់គ្រងច្បាស់លាស់ដើម្បីទទួលបានសញ្ញាបត្រសមមូលនឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្របរិញ្ញាបត្រនិងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់	• ចំនួនវគ្គវិក្រឹតការដែលបានបើកតាមប្រភេទនីមួយៗ • ចំនួនគ្រូបង្រៀនដែលបានចូលរួមតាមវគ្គនីមួយៗ

១.៣.៤ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

ក្របខណ្ឌ និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំឆ្នាំ២០១៩-២០២៣ ត្រូវបានអនុម័តកាលពីខែកញ្ញា ឆ្នាំ២០១៩។ ក្របខណ្ឌ និងផែនការសកម្មភាពនេះលើកទឹកចិត្តគ្រូបង្រៀន និងនាយកសាលារៀនឱ្យអភិវឌ្ឍចំណេះដឹង និងជំនាញរបស់ពួកគាត់តាមរយៈប្រព័ន្ធនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំបែបកូនកាត់រវាង academic and non-academic ដែលផ្តល់ចំនួនក្រេឌីតសម្រាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជាច្រើនរួមទាំងវគ្គសិក្សាថ្នាក់ឧត្តមសិក្សាដូចជាកម្មវិធីបរិញ្ញាបត្រ ការដំឡើងគុណវឌ្ឍិ វិញ្ញាបនបត្រគ្រូបង្រៀន និងឌីប្លូម៉ាក្រោយកម្រិតឧត្តមសិក្សា និងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈដូចជា ស្វ័យសិក្សា ការចូលរួមក្នុងសហគមន៍

សិក្សាវិជ្ជាជីវៈ ការអភិវឌ្ឍវិជ្ជាជីវៈនៅតាមសាលារៀន និងតាមកម្រង។ ក្របខណ្ឌ និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំបានកំណត់និយមន័យការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់ប្រទេសកម្ពុជាថាជា "ការបណ្តុះបណ្តាលឯកទេសជាច្រើនទាំងផ្លូវការនិងមិនផ្លូវការ ឬការសិក្សាវិជ្ជាជីវៈកម្រិតខ្ពស់ដែលមានគោលបំណងជួយថ្នាក់រៀន គ្រូជំនាញ និងនាយកសាលារៀនអភិវឌ្ឍចំណេះដឹងវិជ្ជាជីវៈ ជំនាញ សមត្ថភាព និងប្រសិទ្ធភាព" (៨)។ នៅក្នុងប្រទេសកម្ពុជាប្រព័ន្ធនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ មានពីរប្រភេទ៖

- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានរចនាសម្ព័ន្ធច្បាស់លាស់៖ សំដៅទៅវគ្គសិក្សាផ្លូវការ ឬសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផ្តល់ដោយអ្នកផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលមានការទទួលស្គាល់ ឧទាហរណ៍គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដៃគូអភិវឌ្ឍន៍ ឬនាយកដ្ឋានជំនាញនៃក្រសួងអប់រំ យុវជន និងកីឡា
- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំធ្វើដោយខ្លួនឯង៖ សំដៅលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលអនុវត្តដោយបុគ្គលិកអប់រំដោយគ្មានការគាំទ្រជាផ្លូវការពីអ្នកផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលមានការទទួលស្គាល់ ប៉ុន្តែនៅក្នុងវិសាលភាពនៃក្របខណ្ឌនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ[2]។

ក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំអាចទទួលបានពី ប្រភេទទាំងពីរនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ[3]។ ប្រព័ន្ធនៃអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅប្រទេសកម្ពុជា ជាដំណើរការជាដំណាក់ដោយចាប់ផ្តើមពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានរចនាសម្ព័ន្ធច្បាស់លាស់។

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានរចនាសម្ព័ន្ធច្បាស់លាស់

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានរចនាសម្ព័ន្ធច្បាស់លាស់ រួមមានសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផ្តល់ដោយអ្នកផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានការទទួលស្គាល់ ដោយរាប់បញ្ចូលនូវពេលវេលាជាក់លាក់ដែលបានរៀនក្នុងថ្នាក់។ សកម្មភាពរៀនក្នុងថ្នាក់អាចជាទម្រង់សិក្ខាសាលា វគ្គសិក្សា សកម្មភាពក្រុមស្រាវជ្រាវប្រតិបត្តិ ឬសកម្មភាពផ្សេងៗទៀត។ សម្រាប់មួយម៉ោងសិក្សានៃសកម្មភាពរៀនក្នុងថ្នាក់ សិក្ខាកាមត្រូវរៀនដោយខ្លួនឯងបន្ថែមចំនួនពីរម៉ោងទៀត។ ដោយសារការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជាដំណើរការសកម្មដែលគ្រូបង្រៀនជាអ្នកទទួលខុសត្រូវលើការអភិវឌ្ឍផ្ទាល់ខ្លួន ទោះបីជាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានរចនាសម្ព័ន្ធច្បាស់លាស់ពាក់ព័ន្ធនឹងចំនួនម៉ោងសិក្សាដោយខ្លួនឯង និងតម្រូវឱ្យគ្រូបង្រៀនឬនាយកសាលារៀនបង្ហាញថាពួកគាត់បានចូលរួមយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយមានភស្តុតាងបង្ហាញថាពួកគេបានអនុវត្តអ្វីដែលបានរៀន ក្នុងការអនុវត្តវិជ្ជាជីវៈរបស់ពួកគាត់នៅក្នុងថ្នាក់រៀននិងសាលារៀន ដែលឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្តីនិងការអនុវត្ត និងវិធីដែលការរៀនអាចជួយអភិវឌ្ឍការបង្រៀនរបស់ពួកគាត់។

---

[2] ប្រព័ន្ធនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំត្រូវដាក់ឱ្យអនុវត្តដោយប្រើវិធីសាស្រ្តចាប់ផ្តើមជាដំណាក់ដោយចាប់ផ្តើមពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផ្លូវការក្នុងឆ្នាំ២០២០។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំធ្វើដោយខ្លួនឯងនឹងត្រូវដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០២៥។

[3] ក្របខណ្ឌនិងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសំដៅទៅប្រព័ន្ធក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានលក្ខណៈកូនកាត់រវាង academic and non-academic (17) ដែល academic CPD ត្រូវផ្តល់ដោយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ឬគ្រឹះស្ថានឧត្តមសិក្សា និងទទួលបានក្រេឌីតនៃវគ្គសិក្សា (ក្នុងទស្សនវិស័យនៃការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន) និង non-academic ឬ professional CPD អាចមានលក្ខណៈជា ការអភិវឌ្ឍវិជ្ជាជីវៈតាមសាលារៀន តាមកម្រង ឬផ្តល់ដោយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឬដោយក្រសួង អ.យ.ក។

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯង

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯង គឺផ្អែកលើប្រភពដែលផ្ដល់ដោយគ្រូបង្រៀនម្នាក់ៗដោយមិនបាច់ពឹងផ្អែកលើអ្នកផ្ដល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានការទទួលស្គាល់។ ប្រភពរួមមាន (ប៉ុន្តែមិនបានកំណត់ចំពោះ) Massive open online course (MOOC) ចូលរួមនិង/ឬធ្វើបទបង្ហាញពីស្នាដៃដើមនៅក្នុងសន្និសិទ្ធ ឬសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗទៀត ចូលរួមក្នុងក្រុមស្រាវជ្រាវ អានវិចារណនិពន្ធន៍អាជីពក្នុងទម្រង់ជាឧទាហរណ៍ និទានុប្បវត្តិ សៀវភៅ ស្រាវជ្រាវនិងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ។ល។ បញ្ជីប្រភពដែលទទួលស្គាល់ដោយការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ នឹងបោះពុម្ពជំណាលគ្នានឹងពេលដែលប្រព័ន្ធទទួលស្គាល់ក្រេឌីតសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំធ្វើដោយខ្លួនឯងត្រូវបានដំណើរការ។ វាក៏អាចទៅរួចដែរក្នុងការទទួលបានក្រេឌីតសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯង ពីប្រភពដែលមិនទាន់បានទទួលស្គាល់នៅឡើយ។ គ្រូបង្រៀន នាយកសាលារៀន និងអ្នកឯកទេសអប់រំត្រូវធ្វើសំណើផ្ទាល់ខ្លួនសម្រាប់ការទទួលស្គាល់ប្រភពនានាដែលបានប្រើ។

សម្រាប់មួយម៉ោងនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯង ដែលសិក្សាជាមួយប្រភពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ អ្នកចូលរួមត្រូវបានគេរំពឹងទុកថានឹងសិក្សាដោយខ្លួនឯងយ៉ាងហោចណាស់ចំនួនពីរម៉ោង។ គ្រូបង្រៀន ឬនាយកសាលារៀនត្រូវបង្ហាញថាពួកគេបានចូលរួមយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដោយមានភស្តុតាងបង្ហាញថាពួកគេបានអនុវត្តអ្វីដែលបានរៀនក្នុងការអនុវត្តវិជ្ជាជីវៈរបស់ពួកគាត់នៅក្នុងថ្នាក់រៀន និងសាលារៀន ដែលឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្ដី និងការអនុវត្ត និងវិធីដែលការរៀនអាចជួយអភិវឌ្ឍការបង្រៀនរបស់ពួកគាត់។

ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៨ និងកំពុងត្រូវបានពិនិត្យឡើងវិញដើម្បីផ្ដល់ឱ្យគ្រូបង្រៀននូវផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍអាជីព តាមរយៈការរីកចម្រើនជាបណ្ដើរៗនៅក្នុងគន្លងអាជីពចំនួន៣ដែលពាក់ព័ន្ធគ្នា៖ គន្លងគ្រូបង្រៀន គន្លងគណៈគ្រប់គ្រង ឬគន្លងអ្នកឯកទេសអប់រំ។ ការរីកចម្រើននៅលើគន្លងអាជីពត្រូវបានកំណត់ដោយលក្ខណៈវិនិច្ឆ័យចំនួន៥ចំណុច៖ កម្រិតគុណវុឌ្ឍិ បទពិសោធន៍ការងារ ស្នាដៃការងារ លទ្ធផលការងារ និងសមត្ថភាពវិជ្ជាជីវៈ។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំបានរួមចំណែកដោយផ្ទាល់ក្នុងការលើកកម្ពស់គុណវុឌ្ឍិនិងសមត្ថភាពវិជ្ជាជីវៈ និងដោយប្រយោលលើស្នាដៃការងារ។ នៅពេលដែលគ្រូបង្រៀនបានបំពេញលក្ខណៈវិនិច្ឆ័យ និងរីកចម្រើនតាមគន្លង ពួកគាត់អាចអភិវឌ្ឍខ្លួនពី "គ្រូបង្រៀន" ទៅជា "គ្រូល្អ"។ គ្រូបង្រៀនមួយចំនួននឹងបន្តក្លាយខ្លួនជា "គ្រូឈានមុខ" ឬក៏ "គ្រូឆ្នើម"។ គន្លងអាជីពគ្រូបង្រៀនត្រូវបានបន្សុីជាមួយនឹងក្របខណ្ឌ និងផែនការសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដូច្នេះវាមានការពាក់ព័ន្ធគ្នា។ ការចូលរួមដោយជោគជ័យនៅក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជំរុញឱ្យមានវឌ្ឍនភាពលើអាជីព។ វឌ្ឍនភាពក្នុងជំហាននីមួយៗនៃគន្លងអាជីពគ្រូបង្រៀនទាក់ទងនឹងកំណើនប្រាក់លើកទឹកចិត្តដែលជាលទ្ធផលនៃការបំពេញការងារប្រចាំឆ្នាំ ដោយផ្អែកលើកត្តាផ្សេងៗទៀត នៅពេលដែលបានបំពេញនូវផែនការសិក្សាវិជ្ជាជីវៈបុគ្គលប្រចាំឆ្នាំដោយជោគជ័យ។ វឌ្ឍនភាពរវាងកម្រិតគន្លងអាជីពគ្រូបង្រៀនត្រូវបានកំណត់ដោយការវាយតម្លៃខ្ពស់នៃកិច្ចព្រមព្រៀងគន្លងអាជីពគ្រូបង្រៀនពីគណៈកម្មការគន្លងអាជីពគ្រូបង្រៀន និងឈានទៅឋានៈវិជ្ជាជីវៈថ្មី និងការឡើងប្រាក់លើកទឹកចិត្ត។

យោងតាមក្របខណ្ឌនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គ្រឹះស្ថានឧត្តមសិក្សា នាយកដ្ឋានជំនាញនៃក្រសួងអប់រំ យុវជន និងកីឡា ដែលត្រូវបានទទួលស្គាល់គុណភាព គឺជាអ្នកផ្តល់សេវានៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមួយចំនួនសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន (សូមមើលសៀវភៅណែនាំស្តីពីការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពីអ្នកផ្តល់សេវាផ្សេងទៀត និងលក្ខណៈវិនិច្ឆ័យទទួលស្គាល់គុណភាព)។ ដូចបានលើកឡើងខាងលើនៅក្នុងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន គុណវុឌ្ឍិសិក្សាជាកត្តាមួយដែលរាប់បញ្ចូលក្នុងការអភិវឌ្ឍអាជីព។ នៅពេលដែលគ្រូបង្រៀនទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលបំពេញលក្ខណៈវិនិច្ឆ័យនៃការទទួលបានក្រេឌីត ចំនួនក្រេឌីតទាំងនោះនឹងរាប់បញ្ចូលក្នុងការដំឡើងគុណវុឌ្ឍិទៅកម្រិតបរិញ្ញាបត្ររបស់ពួកគេ។ ការធ្វើបែបនេះនឹងជួយពួកគេឱ្យដើរតាមគន្លងអាជីព។ ដូច្នេះកម្មវិធីវិក្រឹតការ /ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន គួរតែធ្វើឡើងដោយបន្ស៊ីគ្នាទៅនឹងប្រព័ន្ធក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដូចនេះបម្រែបម្រួលគុណវុឌ្ឍិសិក្សារបស់គ្រូបង្រៀននឹងត្រូវបានកត់ត្រាទុកនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សនឹងត្រូវគ្រប់គ្រងដោយការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPDMO) ហើយដែលនឹងរួមបញ្ចូលព័ត៌មាននៃគ្រូបង្រៀនបានចូលរួមអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងរង្វាន់ជាក្រេឌីតដែលទទួលបាន ដើម្បីធានាថាសកម្មភាពទាំងនេះរួមចំណែកដល់ការរីកចម្រើនអាជីពជាគ្រូបង្រៀនតាមរយៈគន្លងអាជីពគ្រូបង្រៀន។

វាជាការចាំបាច់ដែលត្រូវមានទាំងការបត់បែន និងការបន្ស៊ីគ្នាកម្រិតខ្ពស់រវាងធាតុផ្សំផ្សេងៗគ្នានៃប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន។ នៅក្នុងប្រព័ន្ធផ្តល់ក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រាល់ការផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យកំណត់ក្រេឌីត នឹងត្រូវផ្តល់ជូនចំនួនក្រេឌីត។ យោងតាមគោលដៅប្រកបដោយមហិច្ឆិតានៃការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ក៏ដូចជាតម្រូវការក្នុងការផ្តល់រង្វាន់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលជាផ្នែកមួយនាំឱ្យមានការអភិវឌ្ឍគុណភាពអប់រំ វាមានសារៈសំខាន់ណាស់ដែលថាចំនួនក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលគ្រូបង្រៀនបានចូលរួម អាចរួមចំណែកក្នុងការដំឡើងគុណវុឌ្ឍិ និងការអភិវឌ្ឍគន្លងអាជីពរបស់ពួកគេក្នុងបរិបទដែលបានព្រមព្រៀងគ្នា។ វគ្គសិក្សាឬម៉ូឌុលនៃកម្មវិធីវិក្រឹតការដែលត្រូវបានអភិវឌ្ឍឡើងដើម្បីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនទៅដល់កម្រិតបរិញ្ញាបត្រអាចត្រូវបានផ្តល់ជូនគ្រូបង្រៀនដែលមិនបានចូលរួមក្នុងកម្មវិធីដំឡើងគុណវុឌ្ឍិនាពេលបច្ចុប្បន្ន ជាផ្នែកមួយនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ ផ្ទុយមកវិញចំនួនក្រេឌីតដែលទទួលបានពីសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមិនមែនជាផ្នែកនៃកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនផ្លូវការ អាចរួមចំណែកក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ដោយផ្តល់នូវខ្លឹមសារនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលត្រូវបានទទួលស្គាល់និងវាយតម្លៃដែលឆ្លើយតបនឹងតម្រូវការបរិញ្ញាបត្រអប់រំដូចដែលមានចែងក្នុងប្រកាសលេខ១៨៧០។ សម្រាប់សំណើលម្អិតអំពីរបៀបដែលមុខងារនេះអាចដំណើរការបាន សូមមើលតារាង ២.១ ក្នុងផ្នែក២.១.២។

២. យុទ្ធសាស្ត្រនៃការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

២.១ អាទិភាពក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

២.១.១ ការផ្គត់ផ្គង់ និងតម្រូវការគ្រូបង្រៀន

របាយការណ៍វិភាគអនុវិស័យការបណ្តុះបណ្តាលគ្រូបង្រៀន (E-TEC ឆ្នាំ២០១៩) ផ្តល់ការវិភាគលម្អិតស្តីពីការផ្គត់ផ្គង់ និងតម្រូវការគ្រូបង្រៀននៅក្នុងសាលារៀនសាធារណៈ (មិនមែនឯកជន) រហូតដល់ឆ្នាំ២០៣០។ ការវិភាគគឺយោងលើការសន្មតខាងក្រោម។ គួរកត់សម្គាល់ថាការសន្មតទី១ ដល់ទី៤ ខាងក្រោមជាគោលដៅនៃគោលនយោបាយ ហើយការសន្មតទី៥អាចជាដែនកំណត់ក្នុងដំណើរការប្រមូលទិន្នន័យតាមកម្រិតសាលារៀន ថ្នាក់ស្រុក និងថ្នាក់ខេត្ត ដែលក្រសួងអប់រំ យុវជន និងកីឡាបានជួបប្រទះ។

១. នៅបឋមសិក្សា អត្រាពិតនៃការសិក្សា១០០ភាគរយនឹងសម្រេចបាននៅឆ្នាំ២០៣០
២. នៅមធ្យមសិក្សាបឋមភូមិ អត្រារួមនៃការសិក្សា១០០ភាគរយនឹងសម្រេចបាននៅឆ្នាំ២០៣០
៣. បទដ្ឋានបុគ្គលិកឆ្នាំ២០១៤ សម្រាប់សាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនឹងសម្រេចបាននៅឆ្នាំ២០៣០
៤. សាលារៀនពីរវេនសិក្សានឹងត្រូវលុបបំបាត់ចោលនៅឆ្នាំ២០៣០
៥. នៅកម្រិតមធ្យមសិក្សាបឋមភូមិ ការវិភាគពុំបានរាប់បញ្ចូលនូវភាពខុសគ្នារវាងបណ្តាខេត្តនានា និងមុខវិជ្ជាសិក្សាទេ។

បើយោងទៅតាមរបាយការណ៍ខាងលើ ខណៈដែលចំនួនគ្រូបង្រៀនបឋមសិក្សាដែលត្រូវការក្នុងរយៈពេល១០ឆ្នាំខាងមុខគឺមានប្រមាណជា ២,០០០នាក់ក្នុងមួយឆ្នាំ និងគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន៣,៥០០នាក់ក្នុងមួយឆ្នាំដោយយោងលើការសន្មតទី២ ដែលសន្មតនូវការកើនឡើងយ៉ាងឆាប់រហ័សបំផុត នូវការអប់រំកម្រិតមូលដ្ឋានដែលមិនធ្លាប់មានពីមុនមក។ ម្យ៉ាងវិញទៀត បើសិនយើងសន្មតថាការកើនឡើងនៃចំនួនសិស្សមធ្យមសិក្សាបឋមភូមិនឹងស្របតាមនិន្នាការពីមុនមក ចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានដែលត្រូវការនឹងធ្លាក់ចុះយ៉ាងកំហុករហូតដល់ចំនួន៤៥០ ទៅ៥០០នាក់ក្នុងមួយឆ្នាំនៅទសវត្សបន្ទាប់។

របាយការណ៍ក៏បានចង្អុលបង្ហាញពីចំនួនលើស និងខ្វះដ៏គួរឱ្យកត់សម្គាល់នៃចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាននៅតាមខេត្ត និងតាមមុខវិជ្ជាផ្អែកលើទិន្នន័យស្ថិតិឆ្នាំ២០១៤-១៥ ទទួលបានពីនាយកដ្ឋានបុគ្គលិកៈ នៅរាជធានីភ្នំពេញមានគ្រូបង្រៀនលើសច្រើនជាង១០០០នាក់ត្រូវបានគេប៉ាន់ស្មាន ខេត្តតាកែវត្រូវការគ្រូបង្រៀនប្រមាណ៣០០០នាក់ គ្រូបង្រៀនភាសាខ្មែរជាក់ស្តែងមានចំនួនច្រើនលើសលប់ ហើយគ្រូកីឡា និងគ្រូបង្រៀនព័ត៌មានវិទ្យាកំពុងខ្វះខាតខ្លាំង។

ម្យ៉ាងវិញទៀតការរីករាលដាលនៃជំងឺកូវីដ១៩ នាំឱ្យមានការធ្លាក់ចុះចំនួនសិស្ស និងចំនួនគ្រូបង្រៀនដែលត្រូវការផងដែរ។ ជាក់ស្តែងក្រសួងអប់រំ យុវជន និងកីឡាបានធ្វើសេចក្តីសម្រេចចិត្តមិនជ្រើសរើសគរុសិស្ស/គរុនិស្សិតថ្មីសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនក្នុងឆ្នាំសិក្សា២០២០-២០២១។ ដូចគ្នានេះផងដែរ ធនាគារពិភពលោក (ឆ្នាំ២០២០) បានចង្អុលបង្ហាញពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចលើសហគមន៍ជនបទដែលងាយរងគ្រោះដោយរួមបញ្ចូលជាមួយនិងការបិទសាលារៀនរយៈពេលវែង និងការមិនបានសិក្សា ដែលទំនងជាបង្កើននូវអត្រាបោះបង់ការសិក្សារបស់សិស្ស។ ទាំងនេះបង្ហាញថាការប៉ាន់ប្រមាណកន្លងមក គឺមិន

មានប្រសិទ្ធិភាពសម្រាប់ថ្ងៃអនាគតឡើយរហូតដល់ចុងបញ្ចប់នៃការរីករាលដាលនៃជំងឺនេះ ដូច្នេះយើងត្រូវខិតខំត្រួសត្រាយផ្លូវបន្តទៀតដោយប្រើប្រាស់ព័ត៌មានដែលទាន់ហេតុការណ៍បំផុត។

២.១.២ និយមន័យ "គ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់"

ពាក្យ "គ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" បច្ចុប្បន្នត្រូវបានប្រើដើម្បីចង្អុលបង្ហាញ គ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានដែលបានបញ្ចប់កម្មវិធីបណ្តុះបណ្តាល១២+២នៅតាមសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ឬគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិដែលបានបញ្ចប់បរិញ្ញាបត្រ+១នៅវិទ្យាស្ថានជាតិអប់រំ។ ទោះជាយ៉ាងណាក៏ដោយមិនមាននិយមន័យច្បាស់លាស់សម្រាប់គ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គ្រូបង្រៀនដល់កម្រិតមធ្យមសិក្សាបឋមភូមិ ទាល់តែក្រសួងអប់រំ យុវជន និងកីឡាចេញសេចក្តីប្រកាសលេខ១៨៧០ ស្តីពីការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន នៅខែវិច្ឆិកា ឆ្នាំ២០១៩។ ប្រកាសលេខ១៨៧០នេះ ចែងពីចំនួនក្រេឌីត និងមុខវិជ្ជាសិក្សាចាំបាច់ត្រូវទទួលស្គាល់ជាគ្រូបង្រៀនបរិញ្ញាបត្រ និងដំឡើងគុណវុឌ្ឍិគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានពីកម្រិត១២+២ ទៅបរិញ្ញាបត្រ និងធ្វើឱ្យមានភាពខុសគ្នារវាងគ្រូបង្រៀនដែលមានបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន និងគ្រូបង្រៀនដែលមានបរិញ្ញាបត្រលើជំនាញមិនពាក់ព័ន្ធនឹងការបង្រៀននិងរៀន (ឧទាហរណ៍៖ បរិញ្ញាបត្រផ្នែកគ្រប់គ្រង សេដ្ឋកិច្ច គណនេយ្យជាដើម)។

ម្យ៉ាងទៀត វាអាចមានជម្រើសផ្សេងៗគ្នាក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចបង្ហាញក្នុងរូបភាពទី២.១។ នៅក្នុងផ្នែកវគ្គបណ្តុះបណ្តាល គំរូស្របគ្នារួមមានការសិក្សាពីជំនាញ និងការសិក្សាគរុកោសល្យក្នុងបែបរួមបញ្ចូលគ្នាក្នុងកម្មវិធីថ្នាក់បរិញ្ញាបត្រទាំងមូល ហើយគំរូជាប់ផ្តោតភាគច្រើនលើការសិក្សាគរុកោសល្យ បន្ទាប់ពីបានបញ្ចប់ការសិក្សាជំនាញនៅសាកលវិទ្យាល័យ។ ខណៈដែលគំរូស្របគ្នាគឺមានភាពទូទៅសម្រាប់គ្រូបឋមសិក្សា និងគ្រូមធ្យមសិក្សា គំរូជាប់មានភាពទូទៅជាងសម្រាប់គ្រូមធ្យមសិក្សា។



រូបភាព ២.១ ជម្រើសនៃការបណ្តុះបណ្តាលគ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
នៅក្នុងរូប

- គំរូ ក ពាក់ព័ន្ធនឹងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (TUP) ដែលបានធ្វើឡើងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ២០០០នាក់
- គំរូ ខ មិនទាន់បានអនុវត្តនៅឡើយ ប៉ុន្តែមានសក្តានុពលក្នុងការផលិតគ្រូបង្រៀនមានបរិញ្ញាបត្រដែលមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងរយៈពេល១ឆ្នាំ
- គំរូ គ បង្ហាញពីកម្មវិធីបណ្តុះបណ្តាល ១២+៤ នៅវិទ្យាស្ថានគរុកោសល្យ ដែលផលិតគ្រូបង្រៀនបឋមសិក្សាចំនួន៣០០នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន២០០នាក់ នៅឆ្នាំ២០២២ និងឆ្នាំ២០២៣
- គំរូ ឃ ដែលភាគច្រើនសម្រាប់គ្រូបង្រៀនមធ្យមសិក្សា មិនទាន់បានអនុវត្តនៅឡើយសម្រាប់គ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋាន ប៉ុន្តែបានធ្វើនៅវិទ្យាស្ថានជាតិអប់រំសម្រាប់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ។

ប្រកាសលេខ១៨៧០ ខាងលើបានចែងពីចំនួនក្រេឌីត និងមុខវិជ្ជាសិក្សាសម្រាប់គំរូ ក ដល់គំរូ គ ប៉ុន្តែមិនមែនសម្រាប់គំរូ ឃ ទេ។ ដូច្នេះវាជាការចាំបាច់ដែលត្រូវមានសេចក្តីប្រកាសមួយទៀតដើម្បីធានាបាននូវសមភាពរវាងបរិញ្ញាបត្រ+១ និងគំរូដទៃទៀតទាក់ទងនឹងកម្រិត និងមាតិកានៃការសិក្សា។ ឧទាហរណ៍៖ បើទោះបីជាគំរូ ក និងឃ មានរយៈពេលប្រហាក់ប្រហែលគ្នាក៏ដោយ គំរូ ឃ គួរតែយកចិត្តទុកដាក់ទៅលើគរុកោសល្យ វិធីសាស្ត្របង្រៀន និងកម្មសិក្សាគរុកោសល្យ ព្រោះគរុនិស្សិតបានសិក្សាពីមុខវិជ្ជាឯកទេសរួចហើយនៅសាកលវិទ្យាល័យ ខណៈដែលគំរូ ក អាចកាត់ចំនួនក្រឌីតសម្រាប់កម្មសិក្សាគរុកោសល្យព្រោះសិក្ខាកាមជាគ្រូបង្រៀនមានបទពិសោធន៍ស្រាប់។

ដោយសារលទ្ធភាពដែលចំនួនក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ អាចរួមចំណែកដល់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន វាមានសារៈសំខាន់ក្នុងការកំណត់ថាក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំអាចផ្ទេរទៅតាមមុខវិជ្ជាបានកម្រិតណានៅក្នុងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ដូចដែលបង្ហាញនៅក្នុងតារាង២.១។

តារាង ២.១ ចំនួនក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលអាចចូលរួមក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

	មុខវិជ្ជាសិក្សា	គ្រូបង្រៀនមធ្យមសិក្សា (ទូទៅ) គំរូ គ	គ្រូបង្រៀនមធ្យមសិក្សាមានបរិញ្ញាបត្រឬសញ្ញាបត្រខ្ពស់ជាងនេះលើមុខវិជ្ជាពាក់ព័ន្ធ (TQU) គំរូ ខ	គ្រូបង្រៀនមធ្យមសិក្សាមានបរិញ្ញាបត្ររងលើការបង្រៀនឬបរិញ្ញាបត្រមិនមែនការអប់រំកុមារតូច (TQU) គំរូ ក	គ្រូបង្រៀនបឋមសិក្សា (ទូទៅ) គំរូ គ	គ្រូបង្រៀនបឋមសិក្សាមានបរិញ្ញាបត្រលើមុខវិជ្ជាពាក់ព័ន្ធ (TQU) គំរូ ខ	គ្រូបង្រៀនបឋមសិក្សាមានបរិញ្ញាបត្ររងលើការបង្រៀនឬបរិញ្ញាបត្រមិនមែនការអប់រំបឋមសិក្សា (TQU) គំរូ ក	គ្រូបង្រៀនកម្រិតមូលដ្ឋាន (ទូទៅ) គំរូ គ	គ្រូបង្រៀនកម្រិតមូលដ្ឋានមានបរិញ្ញាបត្រលើមុខវិជ្ជាពាក់ព័ន្ធ (TQU) គំរូ ខ	គ្រូបង្រៀនកម្រិតមូលដ្ឋានមានបរិញ្ញាបត្ររងលើការបង្រៀនឬបរិញ្ញាបត្រមិនពាក់ព័ន្ធ (TQU) គំរូ ក
១	ការសិក្សាពីការអប់រំ	12	4 (2)	6 (3)	12	4 (2)	6 (3)	15	4 (2)	6 (3)
២	ចំណេះដឹងមុខវិជ្ជាឯកទេស	25	9 (4)	6 (3)	25	9 (4)	14 (5)	55	9 (4)	22 (8)
៣	ការសិក្សាពីកម្មវិធីសិក្សា	54	0 (0)	24 (12)	54	0 (0)	21 (7)	12	0 (0)	9 (4)
៤	ការលើកកម្ពស់ផ្នែកភាសាបរទេស	2	0 (0)	2 (2)	2	0 (0)	2 (2)	8	0 (0)	6 (6)
៥	ការស្រាវជ្រាវអប់រំ	3	3 (1)	3 (1)	3	3 (1)	3 (1)	3	3 (1)	3 (1)
៦	កម្មសិក្សាប្រតិបត្តិ	20	0 (0)	0 (0)	20	0 (0)	0 (0)	20	0 (0)	0 (0)
៧	មុខវិជ្ជារួម	4	2 (1)	4 (2)	4	2 (2)	4 (2)	7	2 (1)	4 (2)
	មុខវិជ្ជាជម្រើសកំណត់ដោយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន	0	12 (12)	15 (15)	0	12 (12)	10 (10)	0	12 (12)	10 (10)
	ចំនួនក្រេឌីតសរុប (តម្រូវការអប្បបរមា)	120	30 (15)	60 (30)	120	30 (15)	60 (30)	120	30 (15)	60 (30)
	ចំនួនក្រេឌីតជាក់ស្តែងបច្ចុប្បន្ន				134 [TEC]			136 [TEC]		63 [RUPP]

មុខវិជ្ជាជម្រើសនឹងត្រូវរៀបចំដោយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដោយផ្អែកលើតម្រូវការរបស់សិក្ខាកាម (ឧទាហរណ៍ ការបង្កើនប្រាក់ចំណូលនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ការសិក្សាតាមបែបគម្រោងនៅតាមសាលារៀន/ថ្នាក់រៀន ។ល។) លក្ខខណ្ឌអប្បបរមានៃក្រេឌីតសម្រាប់គំរូ ក ខ គ គឺ ៦០ ៣០ និង១២០ក្រេឌីត ប៉ុន្តែគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនអាចបង្កើនចំនួនក្រេឌីតទៅតាមតម្រូវការ។ គម្រោងនៃការបែកចែងចំនួនក្រេឌីតជាក់ស្តែងនៃគំរូនីមួយៗនៃកម្មវិធីជំឡើងគុណវុឌ្ឍិគ្រូបង្រៀននឹងត្រូវធ្វើការពិភាក្សាក្នុងចំណោមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងដំណាក់កាលអនុវត្ត។

ចំនួននៅក្នុងរង្វង់ក្រចកសំដៅលើចំនួនក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំបានមកពីការបំពេញសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលទទួលស្គាល់ ប្រកបដោយជោគជ័យ ដែលអាចរួមចំណែកដល់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនលើមុខវិជ្ជាសិក្សាដែលបានផ្តល់ឱ្យ។ មានគោលការណ៍ទូទៅក្នុងការផ្ទេរចំនួនក្រេឌីតសរុបនៃគំរូនីមួយៗ (ក្រហម ក្នុងរង្វង់ក្រចក) ដែលបានស្នើរហូតដល់ ៥០% ជាបណ្តោះអាសន្ន។ គោលការណ៍នេះត្រូវការធ្វើការពិភាក្សានៅដំណាក់កាលបន្ទាប់។

សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលអាចទទួលបានក្រេឌីតសម្រាប់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនរួមមាន សកម្មភាពដែលផ្តល់នៅតាមសាលារៀន និងកម្រិតកម្រងដោយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងគ្រឹះស្ថានឧត្តមសិក្សា(វិទ្យាស្ថានគរុកោសល្យ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ល។) ក៏ដូចជាសកម្មភាពធ្វើឡើងដោយខ្លួនឯងដូចជា ការចូលរួមវគ្គបណ្តុះបណ្តាលអនឡាយ (MOOC)។ ទាំងសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគ្រឹះស្ថានផ្តល់សេវាត្រូវការ ការទទួលស្គាល់ពីការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៃក្រសួងអប់រំ យុវជន និងកីឡា និងការផ្ទេរចំនួនក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន គឺលើប្រធានបទត្រូវបញ្ជាក់ និងយល់ព្រមដោយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងគ្រឹះស្ថានឧត្តមសិក្សាដែលអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ឱ្យអនុលោមទៅតាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីតរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (២០០៤)។ ការទទួលស្គាល់នៃសកម្មភាពទាំងនេះដោយការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនឹងបញ្ជាក់ថាចំនួនក្រេឌីតទទួលបានអាចរួមចំណែកដល់សុពលភាពមុខវិជ្ជាសិក្សា។ ឧទាហរណ៍ នៅពេលដែលសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានចំណងជើងថា "យុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងថ្នាក់រៀនធំឬចម្រុះ" ត្រូវបានទទួលស្គាល់ ចំនួនក្រេឌីតដែលទទួលបាននឹងបូកបញ្ចូលក្នុងមុខវិជ្ជាការសិក្សាពីការអប់រំ សម្រាប់គ្រូបង្រៀនដែលចូលរួមក្នុងការដំឡើងគុណវុឌ្ឍិ។

២.២ គ្រឹះស្ថានផ្តល់សេវាបណ្តុះបណ្តាលគ្រូបង្រៀន

២.២.១ ទិដ្ឋភាពទូទៅ

គ្រឹះស្ថានដែលផ្តល់សេវាបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជាមានដូចបានបង្ហាញនៅតារាង២.២។

តារាង ២.២ គ្រឹះស្ថានផ្តល់សេវាបណ្តុះបណ្តាលនៅកម្ពុជា

គ្រឹះស្ថាន	គោលដៅនៃការបណ្តុះបណ្តាល	គោលដៅនៃវគ្គវិក្រឹតការសម្រាប់ការដំឡើងគុណវុឌ្ឍិ
សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម	• គ្រូបង្រៀនមត្តេយ្យសិក្សា	-----
សាលាគរុកោសល្យ និងវិក្រឹតការ	• គ្រូបង្រៀនបឋមសិក្សា	-----
មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ	• គ្រូបង្រៀនកម្រិតមូលដ្ឋាន	• ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានសម្រាប់គ្រូបង្រៀនបឋមសិក្សា *
វិទ្យាស្ថានគរុគោសល្យ	• គ្រូបង្រៀនបឋមសិក្សា/ • គ្រូបង្រៀនកម្រិតមូលដ្ឋាន	• ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានសម្រាប់គ្រូបង្រៀនបឋមសិក្សា * • កម្មវិធីថ្នាក់បរិញ្ញាបត្រសម្រាប់គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការខេត្ត
វិទ្យាស្ថានជាតិអប់រំ	• គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ	• កម្មវិធីពន្លឿនកម្រិតបរិញ្ញាបត្រសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន * * • បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញប្រឹក្សា
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ	-----	• កម្មវិធីលើកកម្ពស់គ្រូបង្រៀន(ដល់បរិញ្ញាបត្រ)សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន * * *

*វគ្គវិក្រឹតការសម្រាប់គ្រូបង្រៀនបឋមសិក្សាដើម្បីដំឡើងឋានៈទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ដោយផ្លាស់ប្តូរកាំប្រាក់របស់ពួកគេពីគ ទៅខ (កាំប្រាក់គ្រូបង្រៀនកម្រិតមូលដ្ឋាន) ប៉ុន្តែមិនផ្លាស់ប្តូរគុណវុឌ្ឍិនៃការអប់រំទេ

* *វគ្គវិក្រឹតការគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលបានកំពុងបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ ដោយផ្លាស់ប្តូរកាំប្រាក់របស់ពួកគេពីខ ទៅក (កាំប្រាក់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ)

* * *វគ្គវិក្រឹតការសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលឧបត្ថម្ភដោយធនាគារពិភពលោក ដោយមិនមានការផ្លាស់ប្តូរកាំប្រាក់ឡើយ។

គ្រឹះស្ថានផ្តល់សេវាបណ្តុះបណ្តាលគ្រូបង្រៀនទាំងនេះអនុវត្តទាំងកម្មវិធីបណ្តុះបណ្តាលនៅកម្រិតផ្សេងៗគ្នា ឬវគ្គវិក្រឹតការដើម្បីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ឬទាំងពីរ។ ក្រសួងអប់រំ យុវជន និងកីឡាមិនអនុញ្ញាតឱ្យគ្រឹះស្ថានឯកជនចូលរួមជាអ្នកផ្តល់សេវាបណ្តុះបណ្តាលគ្រូបង្រៀននៅពេលនេះទេ។

<u>សាលាគរុកោសល្យ</u>(សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ)

សាលាគរុកោសល្យរួមមាន សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមចំនួន០១ នៅរាជធានីភ្នំពេញ សាលាគរុកោសល្យ និងវិក្រឹតការ[4]ចំនួន១៦ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ[5]ចំនួន០៤ ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋាន តាមរយៈការបណ្តុះបណ្តាលតាមរូបមន្ត១២+២ កម្រិតបរិញ្ញាបត្ររង។ លក្ខខណ្ឌនៃការដាក់ពាក្យប្រឡងចូលរៀននៅសាលាគរុកោសល្យគឺត្រូវបញ្ចប់មធ្យមសិក្សាទុតិយភូមិ ប៉ុន្តែគរុសិស្សភាគច្រើននៃសាលាគរុកោសល្យមាននិទ្ទេសD ឬE ខ្ពស់ជាងនិទ្ទេសF ដែលធ្លាក់ការប្រឡងថ្នាក់ជាតិសម្រាប់ថ្នាក់ទី១២[6]។ កម្មវិធីបណ្តុះបណ្តាលតាមរូបមន្ត១២+២ ត្រូវបានចាប់ផ្តើមនៅឆ្នាំ១៩៩៨ បន្ទាប់ពីការផ្លាស់ប្តូរពីរូបមន្ត៧+១ នៅទសវត្សឆ្នាំ១៩៨០ ទៅ៨+២ និង១១+២ នៅទសវត្សឆ្នាំ១៩៩០។ លើសពីនេះទៀត ការបណ្តុះបណ្តាលតាមរូមមន្ត៩+២ ត្រូវបានអនុវត្តនៅសាលាគរុកោសល្យ និងវិក្រឹតកាតខេត្តរហូតដល់ឆ្នាំ២០១៥ ដើម្បីបំពេញតម្រូវការគ្រូបង្រៀនបឋមសិក្សានៅតំបន់ជនបទ។ គរុសិស្សបញ្ចប់ការសិក្សានៅសាលាគរុកោសល្យ និងវិក្រឹតការ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ត្រូវបានចាត់ចូលក្នុងក្របខណ្ឌ គ ក្នុងកម្រិតប្រាក់បៀវត្សមន្ត្រីសាធារណៈ ខណៈដែលគរុសិស្សនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទទួលបានក្របខណ្ឌ ខ។

គ្រូឧទ្ទេសសាលាគរុកោសល្យមានគុណវុឌ្ឍិអប់រំខុសៗគ្នា។ នៅពេលដែលពួកគេភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រ ហើយគ្រូឧទ្ទេសដែលត្រូវបានជ្រើសរើសនាពេលថ្មីៗនេះមានសញ្ញាបត្របរិញ្ញាបត្រ+១ ពីវិទ្យាស្ថានជាតិអប់រំ គ្រូឧទ្ទេសនៅសាលាគរុកោសល្យ និងវិក្រឹតការមួយចំនួនមិនទាន់មានសូម្បីតែសញ្ញាបត្របរិញ្ញាបត្រ។ គ្រូឧទ្ទេសមួយចំនួនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ប៉ុន្តែជំនាញគឺមិនទាក់ទងជាមួយមុខវិជ្ជាដែលពួកគេបង្រៀននៅសាលាគរុកោសល្យឡើយ។

ក្នុងចំណោមគ្រូបង្រៀនទាំងនេះ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគបានធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ដើម្បីដំឡើងពីគ្រូបង្រៀនបឋមសិក្សាទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋានតាមរយៈការបណ្តុះបណ្តាលរយៈពេល១ខែកន្លះ ចំនួន២ដង។ កម្មវិធីនេះដំឡើងឋានៈគ្រូបង្រៀនដោយផ្លាស់ប្តូរក្របខណ្ឌពី គ ទៅខ។

<u>វិទ្យាស្ថានគរុកោសល្យ</u>

ដើម្បីឆ្លើយតបនឹងគោលនយោបាយស្តីពីគ្រូបង្រៀនផែនការសកម្មភាព និងផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៤-២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតវិទ្យាស្ថានគរុកោសល្យចំនួន២ នៅរាជធានីភ្នំពេញ និងខេត្តបាត់ដំបងដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត១២+៤ ដោយការបញ្ចូលសាលា

---

[4] សាលាគរុកោសល្យនិងវិក្រឹតការមានទីតាំងនៅ ខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្តាល ក្រចេះ ព្រះវិហារ ព្រៃវែង ពោធិ៍សាត់ សៀមរាប ព្រះសីហនុ ស្ទឹងត្រែង ស្វាយរៀង និងតាកែវ។

[5] មជ្ឈមណ្ឌលគរុកោសល្យភូមិភាគមានទីតាំងនៅ ខេត្តកំពង់ចាម កណ្តាល ព្រៃវែង និងតាកែវ។

[6] Tandon, P and Fukao, T (2015). Educating the Next Generation: Improving Teacher Quality in Cambodia, World Bank, Washington DC.

គរុកោសល្យនិងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនៃតំបន់នីមួយៗ។ វិទ្យាស្ថានគរុកោសល្យបង្កើតឡើងនៅឆ្នាំ២០១៨ ផ្តល់ជូនកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រ(ផ្នែកអប់រំ) ហើយរំពឹងថានឹងបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានដែលពោរពេញទៅដោយចំណេះដឹងគរុកោសល្យនិងចំណេះដឹងលើមុខវិជ្ជាជ្រៅជ្រះ។ យោងតាមស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន វិទ្យាស្ថានគរុកោសល្យបានខិតខំប្រឹងប្រែងរក្សាចំនួនគ្រូឧទ្ទេស ដែលមានបរិញ្ញាបត្រជាន់ខ្ពស់តាមមុខវិជ្ជាដែលពួកគេបង្រៀនមិនឱ្យតិចជាង ៥០ភាគរយ។

រហូតដល់ឆ្នាំសិក្សា២០១៩-២០២០ វិទ្យាស្ថានគរុកោសល្យបានធ្វើការបណ្តុះបណ្តាលទាំងកម្មវិធី ១២+២ និង១២+៤ ដើម្បីឆ្លើយតបបន្ទាន់នឹងតម្រូវការគ្រូបង្រៀននៅតាមបណ្តាខេត្តដែលជាតំបន់របស់វិទ្យាស្ថានគរុកោសល្យ។ នៅពេលដែលគោលនយោបាយគ្រូបង្រៀនផែនការសកម្មភាពរំពឹងថានឹងដំឡើងគុណវុឌ្ឍិគ្រូបង្រៀនអប្បបរមាពី១២+២ ទៅ១២+៤ត្រឹមឆ្នាំ២០២០ អន្តរការនេះគឺកំពុងដំណើរការដោយគ្មានកាលបរិច្ឆេទបញ្ចប់ច្បាស់លាស់ នៅពេលដែលវិទ្យាស្ថានគរុកោសល្យនឹងបន្តបណ្តុះបណ្តាលកម្មវិធីទាំងពីរនេះក្រោមការកំណត់ពីក្រសួងអប់រំ យុវជន និងកីឡា។

ដោយមានការគាំទ្រពីកម្មវិធីពង្រឹងការអប់រំគ្រូបង្រៀននៅកម្ពុជា (STEPCam) វិទ្យាស្ថានគរុកោសល្យបានចាប់ផ្តើមកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រនៅចន្លោះពេលនៃឆ្នាំសិក្សានីមួយៗ សម្រាប់គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការដែលមិនមានបរិញ្ញាបត្រ។ កម្មវិធីនេះជួយដល់សាលាគរុកោសល្យ និងវិក្រឹតការលើកកម្ពស់ការអប់រំគ្រូបង្រៀនដោយការពង្រឹងសមត្ថភាព និងបិទគម្លាតរវាងបុគ្គលិកបង្រៀន។ ចន្លោះពេលនេះក៏ត្រូវបានប្រើដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ដូចនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគដែរ។

បន្ថែមលើនេះ ប្រកាសលេខ៩៦៣ របស់ក្រសួងអប់រំ យុវជន និងកីឡានៅឆ្នាំ២០១៨បានចាត់ថ្នាក់គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យជា ៣ថ្នាក់៖ ទី១ គ្រូឧទ្ទេស ទី២ គ្រូឧទ្ទេសរង និងទី៣ គ្រូឧទ្ទេសជំនួយ។ ប្រកាសនេះជួយវិទ្យាស្ថានគរុកោសល្យជ្រើសរើសគ្រូឧទ្ទេសថ្មីៗ ដោយផ្តោតទៅលើស្តង់ដាជ្រើសរើសច្បាស់លាស់ និងរក្សាបាននូវគុណភាពអប់រំ តាមរយៈការចាត់តាំងបុគ្គលិកបង្រៀនឬគ្រូឧទ្ទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅក្នុងកម្មវិធី ១២+៤។

<u>វិទ្យាស្ថានជាតិអប់រំ</u>

វិទ្យាស្ថានជាតិអប់រំស្ថិតនៅរាជធានីភ្នំពេញ គឺជាគ្រឹះស្ថានតែមួយគត់ដែលផ្តល់នូវកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត បរិញ្ញាបត្រ+១ ដើម្បីក្លាយជាគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ។ លក្ខខណ្ឌដាក់ពាក្យសម្រាប់ប្រឡងចូលវិទ្យាស្ថានជាតិអប់រំ គឺត្រូវមានសញ្ញាបត្របរិញ្ញាបត្រលើជំនាញដែលពាក់ព័ន្ធនឹងមុខវិជ្ជាដែលត្រូវសិក្សា។ គ្រូឧទ្ទេសរបស់វិទ្យាស្ថានជាតិអប់រំមួយចំនួនមានសញ្ញាបត្រអនុបណ្ឌិត និងខ្លះទៀតមានសញ្ញាបត្របណ្ឌិតដែលភាគច្រើនពួកគេបានបញ្ចប់ការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សានៅក្រៅប្រទេស។

កម្មវិធីវិក្រឹតការ/ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមួយចំនួនផ្តល់ដោយវិទ្យាស្ថានជាតិអប់រំ ហើយកម្មវិធីខ្លះទាក់ទងនឹងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន។ វិទ្យាស្ថានជាតិអប់រំបានអនុវត្តនូវកម្មវិធីពន្លឿនដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានប្រមាណ ៣,០០០នាក់ ដែលបាន

បង្រៀននៅមធ្យមសិក្សាទុតិយភូមិដោយសារការខ្វះគ្រូបង្រៀននៅសាលារបស់ពួកគេ ឱ្យទៅជាគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ។ វិទ្យាស្ថានជាតិអប់រំក៏បានបង្កើតនូវមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) នៅឆ្នាំ២០១៩ ដែលមានការគាំទ្រពី KAPE ក្នុងការផ្តល់នូវការបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់អប់រំផ្នែកប្រឹក្សា។ នេះក៏ជាប្រភេទមួយនៃកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដោយនិស្សិតជំនាន់ដំបូងចំនួន ២៥នាក់ ភាគច្រើនជាគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិដែលបានបណ្តុះបណ្តាលតាមរូបមន្តបរិញ្ញាបត្រ+១។ និស្សិតទាំងនេះនឹងត្រូវចាត់តាំងឱ្យទៅបម្រើការនៅវិទ្យាស្ថានជាតិអប់រំចំនួន ២នាក់ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញចំនួន ៣នាក់ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបងចំនួន ៣នាក់បន្ទាប់ពីបញ្ចប់ការសិក្សា។

<u>សាកលវិទ្យាល័យភូមិន្ទភ្នំពេញ</u>

នៅពេលដែលសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មិនមែនជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន សាកលវិទ្យាល័យនេះបាននិងកំពុងបណ្តុះបណ្តាលកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ដោយមានការគាំទ្រពីធនាគារពិភពលោក ដើម្បីដំឡើងគុណវុឌ្ឍិអប់រំគ្រូបង្រៀនកម្រិតមូលដ្ឋានប្រមាណ ២០០០នាក់ ពីកម្រិត១២+២ ទៅបរិញ្ញាបត្រ ដោយពុំមានការផ្លាស់ប្តូរក្របខណ្ឌឡើយ។

២.២.២ ការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន

ផ្នែកនេះនឹងបង្ហាញពីកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានគរុកោសល្យ និងសាលាគរុកោសល្យដើម្បីសិក្សាពីគម្លាតរវាងកម្មវិធី១២+៤ និង១២+២ និងគិតពីមេរៀនដែលត្រូវបង្រៀនក្នុងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនសម្រាប់គ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋាន។

<u>ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានគរុកោសល្យ</u>

ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានគរុកោសល្យ ត្រូវបានរៀបចំឡើងដោយយោងតាមកម្មវិធីសិក្សាបរិញ្ញាបត្រសិល្បៈ (អប់រំ) របស់វិទ្យាស្ថានជាតិអប់រំសិង្ហបុរី សាកលវិទ្យាល័យបច្ចេកវិទ្យាណានយ៉ាង (NIE/NTU ឆ្នាំ២០១៧) ដើម្បីបំពេញតាមស្តង់ដាថ្នាក់តំបន់។ ម្យ៉ាងវិញទៀត កម្មវិធីនេះត្រូវបានធ្វើឡើងក្នុងគោលបំណងបញ្ចូលមុខវិជ្ជាដែលកំពុងបង្រៀននៅសាលាគរុកោសល្យនិងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដើម្បីឱ្យស្របនឹងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស (ក្រសួងអប់រំឆ្នាំ២០១៦) និងអនុលោមតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤)។ ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានគរុកោសល្យមានចំនួន ១៣៤ក្រេឌីត សម្រាប់ការអប់រំបឋមសិក្សា និងចំនួន ១៣៦ក្រេឌីតសម្រាប់ការអប់រំមធ្យមសិក្សាបឋមភូមិ (សូមមើលតារាង ២.៣ ខាងក្រោម)។

តារាង ២.៣ បំណែងចែកក្រេឌីតតាមមុខវិជ្ជានីមួយៗនៃកម្មវិធីបណ្តុះបណ្តាល១២+៤របស់វិទ្យាស្ថានគរុកោសល្យ

ល.រ	មុខវិជ្ជា	ឆ្នាំ				សរុបក្រេឌីត *
		១	២	៣	៤	
កម្មវិធីអប់រំបឋមសិក្សា						
១	ការសិក្សាពីការអប់រំ (*រួមបញ្ចូល៦ក្រេឌីតសម្រាប់ការស្រាវជ្រាវ)	៦	៦	៤	៥	២១
២	ការសិក្សាពីកម្មវិធីសិក្សា	៤	២០	១៩	១៥	៥៨
៣	ចំណេះដឹងលើមុខវិជ្ជា	២១	២	២	២	២៥
៤	ការលើកកម្ពស់សមត្ថភាពភាសានិងបំណិនឧទ្ទេស-សរសេរ សម្រាប់ការបង្រៀន	២	-	-	-	២
៥	មុខវិជ្ជារួម	១	១	១	១	៦
៦	កម្មសិក្សាគរុកោសល្យ	២	៥	៥	១០	២២
ក្រេឌីតសរុប		៣៦	៣៤	៣១	៣៣	១៣៤

កម្មវិធីអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ						
១	ការសិក្សាពីការអប់រំ(*រួមបញ្ចូល៦ក្រេឌីតសម្រាប់ការស្រាវជ្រាវ)	៦	៦	៦	៤	២២
២	មុខវិជ្ជាឯកទេស (មុខវិជ្ជាឯកទេស)	២០	១៥	១០	១០	៥៥
៣	ការសិក្សាពីកម្មវិធីសិក្សា (មុខវិជ្ជាឯកទេស)					
	ក. កម្មវិធីមិនប្រើប្រាស់ភាសាបរទេស	-	៣	៣	៦	១២
	ខ. កម្មវិធីប្រើប្រាស់ភាសាបរទេស	-	៦	៦	១២	២៤
៤	ការលើកកម្ពស់សមត្ថភាពភាសានិងបំណិនឧទ្ទេស-សរសេរ សម្រាប់ការបង្រៀន					
	កម្មវិធីមិនប្រើប្រាស់ភាសាបរទេស	៥	៣	៣	៣	១៤
	កម្មវិធីប្រើប្រាស់ភាសាបរទេស	២	-	-	-	២
៥	មុខវិជ្ជារួម	៣	១	៤	៣	១១
៦	កម្មសិក្សាគរុកោសល្យ	២	៥	៥	១០	២២
សរុបក្រេឌីត						
ក. កម្មវិធីនានាមិនប្រើប្រាស់ភាសាបរទេស		៣៦	៣៣	៣១	៣៦	១៣៦
ខ. កម្មវិធីនានាប្រើប្រាស់ភាសាបរទេស		៣៣	៣៣	៣១	៣៩	១៣៦

ប្រភព៖ ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ (ក្រសួងអ.យ.ក ពិនិត្យឡើងវិញឆ្នាំ២០១៩)

គួរកត់សម្គាល់ថា គរុនិស្សិតម្នាក់ៗទទួលបាន ១ក្រេឌីតតាមរយៈ ការសិក្សាផ្ទាល់ចំនួន ១៥ម៉ោង បូកនឹង៣០ម៉ោងនៃស្វ័យសិក្សា (ឧទាហរណ៍ ការរៀបចំ ការរំលឹក ។ល។) ឬក៏ចំនួន៣០ម៉ោងនៃអនុវត្តឬការពិសោធន៍/នៅមន្ទីរពិសោធន៍ បូកថែមចំនួន១៥ម៉ោងស្វ័យសិក្សា ឬចំនួន៤៥ម៉ោងនៃទស្សនកិច្ចសិក្សា។

ដូចមាននៅក្នុងតារាងខាងលើ កម្មវិធី១២+៤ រួមមានមុខវិជ្ជាសិក្សាដូចខាងក្រោម៖

- **"ការសិក្សាពីការអប់រំ"** ផ្តោតលើបញ្ញត្តិនិងគោលការណ៍នៃការអប់រំ ចាំបាច់សម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព និងការអនុវត្តជាក់ស្តែងនៅក្នុងសាលារៀន
- **"ការសិក្សាពីកម្មវិធីសិក្សា"** ត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងគរុកោសល្យ និងជំនាញចាំបាច់ក្នុងការបង្រៀនមុខវិជ្ជាជាក់លាក់ ផ្អែកលើកម្មវិធីសិក្សាចំណេះទូទៅ
- **"ចំណេះដឹងលើមុខវិជ្ជា"** ការបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា ជួយពង្រឹងខ្លឹមសារនៃមុខវិជ្ជានីមួយៗក្នុងការបង្រៀន
- **"មុខវិជ្ជាឯកទេស"** ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ពង្រឹងចំណេះដឹងមុខវិជ្ជានិងជំនាញនានា ហើយធ្វើឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅពីបញ្ញត្តិទាក់ទងនឹងមុខវិជ្ជា
- **"មុខវិជ្ជារួម"** ណែនាំគរុនិស្សិតឱ្យយល់ដឹងពីផលប៉ះពាល់នៃការរស់នៅក្នុងសង្គមចម្រុះ
- **"ការលើកកម្ពស់សមត្ថភាពភាសានិងបំណិនឧទ្ទេស-សរសេរសម្រាប់ការបង្រៀន"** ផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានភាសា និងបំណិនប្រើប្រាស់ភាសាសម្រាប់ការពន្យល់បកស្រាយដែលត្រូវការក្នុងការបង្រៀនក៏ដូចជាការចូលរួមក្នុងការសរសេរកិច្ចការស្រាវជ្រាវ និងនិក្ខេបបទ
- **"កម្មសិក្សាគរុកោសល្យ"** ជួយគរុនិស្សិតទទួលបាននូវសមត្ថភាពក្នុងការបង្រៀនតាមរយៈការអនុវត្តការបង្រៀនផ្ទាល់ក្នុងបរិបទ និងកម្រិតផ្សេងៗគ្នាក្រោមការជួយជ្រោមជ្រែងពីគ្រូឧទ្ទេសនៃវិទ្យាស្ថានគរុកោសល្យ និងគ្រូបង្រៀននៃសាលារៀនដែលពួកគេចុះធ្វើកម្មសិក្សា។

ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលនៃវិទ្យាស្ថានគរុកោសល្យនឹងក្លាយជាមូលដ្ឋានក្នុងការពិភាក្សា ទាំងចំនួនក្រេឌីត និងមុខវិជ្ជាសិក្សាក្នុងការរៀបចំកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន។

សាលាគរុកោសល្យ និងវិក្រឹតការ និងវិទ្យាស្ថានគរុកោសល្យ

កម្មវិធីបណ្តុះបណ្តាលរបស់សាលាគរុកោសល្យ និងវិក្រឹតការ ត្រូវបានផ្លាស់ប្តូរពីប្រព័ន្ធម៉ោងទៅជាប្រព័ន្ធក្រេឌីតនៅឆ្នាំ២០១៧ ហើយអាចសង្ខេបបានដូចនៅក្នុងតារាង២.៤ ដោយយោងតាមក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានគរុកោសល្យ។ ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលរបស់សាលាគរុកោសល្យ និងវិក្រឹតការមានចំនួនសរុប ៧៩ក្រេឌីត ដែលសុទ្ធតែជាមុខវិជ្ជាកាតព្វកិច្ច។

តារាង ២.៤ ការប្រៀបធៀបចំនួនក្រេឌីតនៃកម្មវិធីបណ្តុះបណ្តាលរបស់សាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងវិទ្យាស្ថានគរុកោសល្យ(បឋមសិក្សា)

ល.រ	មុខវិជ្ជាសិក្សា	សាលាគរុកោសល្យនិងវិក្រឹតការខេត្ត	វិទ្យាស្ថានគរុកោសល្យ	គម្លាត
១	ការសិក្សាពីអប់រំ (ស្រាវជ្រាវ)	១៩ (៦)	២១ (៦)	២ (០)
២	ការសិក្សាពីកម្មវិធីសិក្សា	១៩	៥៨	៣៩
៣	ចំណេះដឹងលើមុខវិជ្ជា	១៩	២៥	៦
៤	ការលើកកម្ពស់សមត្ថភាពភាសានិងបំណិនឧទ្ទេស-សរសេរសម្រាប់ការបង្រៀន	២	២	០
៥	មុខវិជ្ជារួម	៨	៦	-២
៦	កម្មសិក្សាគរុកោសល្យ	១២	២២	១០
	សរុបក្រេឌីត	**៧៩**	**១៣៤**	**៥៥**

ប្រភព៖ កម្មវិធីបណ្តុះបណ្តាលរបស់សាលាគរុកោសល្យ និងវិក្រឹតការខេត្ត(ក្រសួងអប់រំ ឆ្នាំ២០១៧)

ដូចដែលបានឃើញនៅក្នុងតារាងខាងលើ នៅពេលដែលកម្មវិធីបណ្តុះបណ្តាលរបស់សាលាគរុកោសល្យ និងវិក្រឹតការត្រូវបានរៀបចំឡើងដោយមានតុល្យភាព គរុសិស្សទទួលបានចំណេះដឹងទូលំទូលាយដែលចាំបាច់សម្រាប់គ្រូបង្រៀនចេញថ្មីក្នុងរយៈពេល២ឆ្នាំ។ ចំនួនក្រេឌីតសម្រាប់ការសិក្សាពីកម្មវិធីសិក្សា គឺស្ទើរតែស្មើនឹងមួយភាគបីនៃចំនួនក្រេឌីតសម្រាប់ការសិក្សាពីកម្មវិធីសិក្សា នៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានគរុកោសល្យ។ ប្រសិនបើគុណវុឌ្ឍិគ្រូបង្រៀនបឋមសិក្សា១២+២ ត្រូវដំឡើង កម្មវិធីគួរផ្តោតទៅលើវិធីសាស្ត្របង្រៀន និងចំណេះដឹងលើមុខវិជ្ជាពាក់ព័ន្ធជាជាងកម្មសិក្សាគរុកោសល្យដោយសារគ្រូបង្រៀនក្នុងប្រព័ន្ធមានភាពស៊ាំក្នុងការបង្រៀនក្នុងថ្នាក់រៀន។ លើសពីនេះទៀត នៅពេលដែលកម្មវិធីបណ្តុះបណ្តាលរបស់សាលាគរុកោសល្យ និងវិក្រឹតការផ្តល់៦ក្រេឌីតសម្រាប់ការស្រាវជ្រាវអប់រំ គ្រូបង្រៀន១២+២ ត្រូវរៀនមុខវិជ្ជានេះម្តងទៀតពីព្រោះនៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់សាលាគរុកោសល្យ និងវិក្រឹតការរហូតដល់ឆ្នាំ២០១៦ មាន "ការស្រាវជ្រាវគរុកោសល្យ" ត្រឹមតែ ១៦ម៉ោងប៉ុណ្ណោះ ដែលត្រូវបានណែនាំដោយគ្រូឧទ្ទេសដែលភាគច្រើនពុំមានបទពិសោធន៍ក្នុងការស្រាវជ្រាវអប់រំ។

<u>មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានគរុកោសល្យ</u>

កម្មវិធីសិក្សារបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគគឺនៅតែផ្តោតលើចំនួនម៉ោង ដូច្នេះចំនួនក្រេឌីតដែលបង្ហាញនៅជួរឈរខាងស្តាំដៃនៃតារាង២.៥ គឺមិនទាន់ជាតួលេខផ្លូវការ ប៉ុន្តែត្រូវបានគណនាជាបណ្តោះអាសន្នសម្រាប់ការពិភាក្សានៅក្នុងផ្នែកនេះ។ ទោះបីជាយើងប្រើប្រាស់រូបមន្ត "១ក្រេឌីត ស្មើ៣០ម៉ោងសិក្សា" សម្រាប់គ្រប់មុខវិជ្ជាសិក្សាក៏ដោយ (លើកលែងតែចំនួនក្រេឌីតសរុបសម្រាប់ការស្រាវជ្រាវ និងកម្មសិក្សា

គរុកោសល្យ) ចំនួនក្រេឌីតសរុបមានដល់ទៅ ៨៨ក្រេឌីត ដែលហាក់បីដូចជាច្រើនបន្តិចសម្រាប់កម្មវិធីរយៈពេលពីរឆ្នាំនៅថ្នាក់ឧត្តមសិក្សា។ នៅក្នុងតារាង២.៥ យើងឃើញថាកម្មវិធីនេះផ្តោតលើការពង្រឹងចំណេះដឹងមុខវិជ្ជាដល់គ្រូបង្រៀនកម្រិតមូលដ្ឋាន។

តារាង២.៥ របាយម៉ោងបង្រៀននៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

ល.រ	មុខវិជ្ជាសិក្សាក្នុងក្របខណ្ឌកម្មវិធីសិក្សានៃវិទ្យាស្ថានគរុកោសល្យ	មុខវិជ្ជាក្នុងកម្មវិធីបណ្តុះបណ្តាលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ	ចំនួនម៉ោងបង្រៀន (*)	ក្រេឌីត (**)
១	ការសិក្សាពីការអប់រំ	ចិត្ត-គរុកោសល្យ ការអប់រំបញ្ចូលគ្នា សាលាកុមារមេត្រី វប្បធម៌ទូទៅ រដ្ឋបាលសិក្សា អាជីពផ្នែកសីលធម៌ រោងជាង បណ្ណាល័យ	៦៥១	២២
	(ការស្រាវជ្រាវ)	ការស្រាវជ្រាវគរុកោសល្យ	១៦	០
២	ការសិក្សាពីកម្មវិធីសិក្សា	វិធីសាស្ត្របង្រៀន	៥៣១	១៨
៣	ចំណេះដឹងលើមុខវិជ្ជា	ចំណេះដឹងមូលដ្ឋាន ចំណេះដឹងនៅក្នុងការអប់រំកម្រិតមូលដ្ឋាន	៦៨៧	២៣
៤	ការលើកកម្ពស់សមត្ថភាពភាសានិងបំណិនឧទ្ទេស-សរសេរសម្រាប់ការបង្រៀន	ភាសាបរទេស	១១៦	៤
៥	មុខវិជ្ជារួម	អប់រំកាយ – កីឡា កសិកម្ម សិល្បៈ កុំព្យូទ័រ	២៧៧	៩
៦	កម្មសិក្សាគរុកោសល្យ		៥៥២	១២
	ចំនួនម៉ោងបង្រៀនសរុប		**២,៨៣០**	**៨៨**

ប្រភព៖ កម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ (ក្រសួងអ.យ.ក ឆ្នាំ២០១១)

ចំណាំ៖ (*) កម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគបែងចែក ១,២១៨ម៉ោងទៅ "មុខវិជ្ជាឯកទេស" ដែលមានទាំងវិធីសាស្ត្របង្រៀននិងចំណេះដឹងមុខវិជ្ជា ហើយការបែងចែកម៉ោងទៅមុខវិជ្ជាទាំងពីរនេះខុសគ្នាពី ៦៧៤:៥៤៤ ចំពោះវគ្គសិក្សាមុខវិជ្ជាប្រវត្តិវិទ្យា/ភូមិវិទ្យា ទៅ៤៣១:៧៨៧ ចំពោះវគ្គសិក្សាមុខវិជ្ជាភាសាខ្មែរ/គេហវិជ្ជា។ ម៉ោងបង្រៀន

បែងចែកទៅ "២.ការសិក្សាពីកម្មវិធីសិក្សា" និង "៣.ចំណេះដឹងលើមុខវិជ្ជា" នៅក្នុងតារាងនេះជាមធ្យមភាគនៃវគ្គសិក្សាចំនួន៦ ដែលមានរាយក្នុងកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។

(**) ម៉ោងបង្រៀនត្រូវបានប្តូរទៅជាចំនួនក្រេឌីតតាមរូបមន្តដូចតទៅ៖ ម៉ោងបង្រៀន "ការស្រាវជ្រាវ" និង "កម្មសិក្សាគរុកោសល្យ" ត្រូវបានចែកនឹង ៤៥ ដោយសារជាមុខវិជ្ជាអនុវត្ត ហើយមុខវិជ្ជាផ្សេងទៀតត្រូវបានចែកនឹង៣០ មិនមែន ១៥ ព្រោះមេរៀនភាគច្រើននៃសាលាគរុកោសល្យគឺជាការបង្រៀននិងកិច្ចការផ្ទះ និងកម្រិតម្រូវឱ្យគរុសិស្សត្រូវធ្វើការត្រៀមឱ្យបានច្រើន ដូចជាការអានអត្ថបទពាក់ព័ន្ធ រៀបចំបទបង្ហាញ និងពិភាក្សា ។ល។

តារាង ២.៦ បង្ហាញពីចំនួនក្រេឌីតដែលបែងចែកសម្រាប់មុខវិជ្ជានីមួយៗនៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានគរុកោសល្យ។ ការប្រៀបធៀបសមាមាត្រនៃការសិក្សាពីកម្មវិធីសិក្សា និងចំណេះដឹងលើមុខវិជ្ជាបង្ហាញថា កម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគផ្តោតខ្លាំងលើការសិក្សាពីកម្មវិធីសិក្សា នៅពេលដែលកម្មវីធីបណ្តុះបណ្តាលនៃវិទ្យាស្ថានគរុកោសល្យផ្តោតលើចំណេះដឹងលើមុខវិជ្ជា។ ផ្ទុយពីគ្រូបង្រៀនបឋមសិក្សាដែលជាធម្មតាត្រូវបានបណ្តុះបណ្តាលជាលក្ខណៈទូទៅ ព្រោះតែពួកគាត់ត្រូវបង្រៀនមុខវិជ្ជាភាគច្រើននៅក្នុងកម្មវិធីសិក្សាបឋមសិក្សាដោយផ្តោតសំខាន់លើការអភិវឌ្ឍលើផ្នែកបញ្ញា ស្មារតី និងឥរិយាបថសម្រាប់ក្មេងម្នាក់ៗ គ្រូបង្រៀនកម្រិតមូលដ្ឋានដែលភាគច្រើនជាគ្រូបង្រៀនមុខវិជ្ជាឯកទេសត្រូវបានបណ្តុះបណ្តាលទៅជា "អ្នកជំនាញមុខវិជ្ជា" ជាការផ្តល់ការណែនាំពីចម្ងាយដោយគិតពីរបៀបដែលខ្លឹមសារនៃការអប់រំនៅមធ្យមសិក្សាបឋមភូមិ ផ្សារភ្ជាប់ទៅនឹងការអប់រំនៅមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា ដែលជាហេតុផលនៃការផ្តោតលើចំណេះដឹងលើមុខវិជ្ជានៅសាលាគរុកោសល្យ និងវិទ្យាស្ថានគរុកោសល្យ។

តារាង២.៦ ការប្រៀបធៀបចំនួនក្រេឌីតនៃកម្មវិធីបណ្តុះបណ្តាលរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងវិទ្យាស្ថានគរុកោសល្យ(អនុវិទ្យាល័យ)

ល.រ	មុខវិជ្ជាសិក្សា	មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ	វិទ្យាស្ថានគរុកោសល្យ	ចន្លោះ
១	ការសិក្សាពីការអប់រំ (ស្រាវជ្រាវ)	២២ (០)	២២ (៦)	០ (៦)
២	ការសិក្សាពីកម្មវិធីសិក្សា	១៨	១២	-៦
៣	ចំណេះដឹងលើមុខវិជ្ជា	២៣	៥៥	៣២
៤	ការលើកកម្ពស់សមត្ថភាពភាសានិងបំណិនឧទ្ទេស-សរសេរសម្រាប់ការបង្រៀន	៤	១៤	១០
៥	មុខវិជ្ជារួម	៩	១១	២
៦	កម្មសិក្សាគរុកោសល្យ	១២	២២	១០
	សរុបក្រេឌីត	**៨៨**	**១៣៦**	**៤៨**

មានភាពខុសគ្នាច្រើនត្រូវបានរកឃើញពីចំនួនក្រេឌីតលើការស្រាវជ្រាវ និងការលើកកម្ពស់សមត្ថភាពភាសានិងបំណិនឧទ្ទេស-សរសេរសម្រាប់ការបង្រៀន (ឬ "ភាសាបរទេស" នៅក្នុងកម្មវិធីបណ្តុះបណ្តាលនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ)៖ កម្មវិធីបណ្តុះបណ្តាលនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគដាក់បញ្ចូលត្រឹមតែ ១៦ម៉ោងសម្រាប់ "ការស្រាវជ្រាវគរុកោសល្យ" ទោះបីជាមុខវិជ្ជានេះទំនងជាមិនអាចបង្កើតបាននូវកិច្ចការស្រាវជ្រាវក្នុងកម្រិតណាមួយនៅរយៈពេលខ្លី ហើយកម្មវិធីបណ្តុះបណ្តាលនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគជំរុញគរុសិស្សឱ្យរៀនភាសាអង់គ្លេស ខណៈដែលកម្មវិធីបណ្តុះបណ្តាលនៃវិទ្យាស្ថានគរុកោសល្យត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱ្យគរុនិស្សិតនូវជំនាញសរសេរសម្រាប់ការស្រាវជ្រាវរបស់ពួកគេ។

២.២.៣ គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យ និងសាលាគរុកោសល្យ

គ្រូឧទ្ទេសដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សា និងលើកកម្ពស់គុណភាពការអប់រំគ្រូបង្រៀន និងទទួលខុសត្រូវដោយផ្ទាល់ចំពោះការទទួលបានចំណេះដឹងវិជ្ជាជីវៈ និងជំនាញរបស់គ្រូចេញថ្មីនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ ស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនបានចែងនូវលក្ខខណ្ឌ ដែលបុគ្គលិកបង្រៀននៃគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនគួរបំពេញដូចខាងក្រោម៖

- បុគ្គលិកបង្រៀនដែលមានគុណវុឌ្ឍិស្មើកម្រិតអប់រំដែលត្រូវបង្រៀន និងមានបទពិសោធន៍បង្រៀនយ៉ាងតិច ៥ឆ្នាំ មានចំនួនមិនលើសពី ៥០ភាគរយនៃបុគ្គលិកដែលបង្រៀននៅក្នុងកម្មវិធី
- បុគ្គលិកបង្រៀនដែលមានគុណវុឌ្ឍិលើកម្រិតអប់រំដែលត្រូវបង្រៀន និងមានបទពិសោធន៍បង្រៀនយ៉ាងតិច ៣ឆ្នាំ មានចំនួនយ៉ាងតិច ៥០ភាគរយនៃចំនួនគ្រូឧទ្ទេសក្នុងកម្មវិធី
- បុគ្គលិកបង្រៀនដែលមានគុណវុឌ្ឍិស្មើកម្រិតកម្មវិធីដែលត្រូវបង្រៀន ប៉ុន្តែមានបទពិសោធន៍តិចជាង៥ឆ្នាំ អាចធ្វើជាគ្រូជំនួយក្នុងកម្មវិធីអប់រំគ្រូបង្រៀន
- បុគ្គលិកបង្រៀនត្រូវមានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងប្រព័ន្ធផ្សព្វផ្សាយអប់រំដែលពាក់ព័ន្ធ

ម្យ៉ាងវិញទៀត មានបញ្ហាធ្ងន់ធ្ងរមួយចំនួនពាក់ព័ន្ធនឹងគ្រូឧទ្ទេសនៃសាលាគរុកោសល្យ និងវិទ្យាស្ថានគរុកោសល្យ ដែលត្រូវបានសង្ខេបដូចខាងក្រោម៖

១. អវត្តមាននៃយន្តការក្នុងការផលិតគ្រូឧទ្ទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅក្នុងស្រុក
២. ការលំបាកក្នុងការជ្រើសគ្រូឧទ្ទេសមានសម្បត្តិគ្រប់គ្រាន់ពីគ្រឹះស្ថានអប់រំផ្សេងៗ និង
៣. កង្វះឱកាសនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់គ្រូឧទ្ទេសដែលមានស្រាប់ដើម្បីធ្វើបច្ចុប្បន្នភាព និងលើកកម្ពស់ចំណេះដឹង និងជំនាញវិជ្ជាជីវៈរបស់ពួកគេ។

សម្រាប់ចំណុចទី១ អវត្តមាននៃយន្តការក្នុងការផលិតគ្រូឧទ្ទេសកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ តាមរយៈគ្រឹះស្ថានឧត្តមសិក្សានៅក្នុងស្រុក មិនត្រឹមតែធ្វើឱ្យមានការលំបាកក្នុងការផ្គត់ផ្គង់គ្រូឧទ្ទេសថ្មីតាមការគ្រោងទុកនោះទេ ថែមទាំងបណ្តាលឱ្យមានការពឹងផ្អែកលើកម្មវិធីអាហារូបករណ៍ក្រៅប្រទេសក្នុងការផ្គត់ផ្គង់គ្រូឧទ្ទេសដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងមានជំនាញភាសាអង់គ្លេសនិងICT។ សម្រាប់ចំណុចទី២ មានការរំពឹងទុកបែបសុទិដ្ឋិនិយមថា យ៉ាងហោចណាស់មានគ្រូបង្រៀនចំនួន ៨០០នាក់ មានបរិញ្ញាបត្រជាន់ខ្ពស់ត្រឹមរយៈពេលនៃការរំពឹងទុក ហើយតំណែងជាគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យនឹងងាយស្រួលបំពេញដោយ

បេក្ខជនទាំងនោះ។ តែទោះបីជាយ៉ាងណា តាមភាពជាក់ស្តែងវិទ្យាស្ថានគរុកោសល្យទាំងពីរ ជាពិសេសវិទ្យាស្ថានគរុកោសល្យបាត់ដំបងប្រឈមនឹងការខ្វះគ្រូឧទ្ទេសដែលលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដោយសារខ្វះបេក្ខជនដែលអាចបំពេញលក្ខខណ្ឌតម្រូវនៃគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យ។ សម្រាប់ចំណុចទី៣ ក៏ដូចជាគ្រូបង្រៀនដែរ គ្រូឧទ្ទេសភាគច្រើនមិនមានឱកាសស្វែងយល់ពីគំនិតនិងបញ្ញត្តិថ្មីៗ និងក្រេបយកចំណេះដឹងនិងជំនាញទាក់ទងនឹងមុខវិជ្ជាជំនាញរបស់ពួកគេ បន្ទាប់ពីពួកគេបានចាប់ផ្តើមធ្វើការនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ នៅក្នុងកាលៈទេសៈបែបនេះ កម្រិតចំណេះដឹង និងជំនាញវិជ្ជាជីវៈទំនងជាអាចចុះខ្សោយទៅតាមពេលវេលា ជាពិសេសនៅតំបន់ដាច់ស្រយាលដែលខ្វះការជម្រុញផ្នែកបញ្ញា។

ថ្មីៗនេះ វិទ្យាស្ថានគរុកោសល្យបានចាត់តាំងគ្រូឧទ្ទេសរងឱ្យបង្រៀនម៉ូឌុលមួយចំនួនដើម្បីឆ្លើយតបនឹងកង្វះគ្រូឧទ្ទេស។ ទោះបីជាយ៉ាងនេះក៏ដោយ នេះមិនមែនជាដំណោះស្រាយមូលដ្ឋាន ហើយការខ្វះគ្រូឧទ្ទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គឺជាឧបសគ្គក្នុងការរៀបចំ និងពង្រីកវិសាលភាពនៃកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន។

២.២.៤ តើមានកម្មវិធីបណ្តុះបណ្តាលអ្វីខ្លះសម្រាប់ដំឡើងគុណវុឌ្ឍិគ្រូបង្រៀន?

ដូចដែលបានរៀបរាប់ក្នុងតារាង២.៧ ខាងក្រោម មានជម្រើសមួយចំនួនក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនពីកម្រិត១២+២ ទៅ១២+៤៖ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនមួយចំនួនអាចជួយប្រព័ន្ធរៀបចំគ្រូបង្រៀនផលិតគ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានមួយចំនួនប្រចាំឆ្នាំ ដែលមានគុណវុឌ្ឍិអប់រំខ្ពស់ជាងមុន ហើយកម្មវិធីវិក្រឹតការអាចជួយគ្រូបង្រៀនកម្រិត១២+២ ក្នុងការដំឡើងគុណវុឌ្ឍិទៅដល់កម្រិតបរិញ្ញាបត្រ។ គួរកត់សម្គាល់ថាវិទ្យាស្ថានគរុកោសល្យតែឯង អាចចូលរួមចំណែកក្នុងការផលិតគ្រូបង្រៀនដែលមានសញ្ញាបត្របរិញ្ញាបត្រត្រឹមតែ ១ភាគរយនៃចំនួនគ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានទាំងអស់ក្នុងមួយឆ្នាំ។

តារាង២.៧ កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

	គោលដៅ	កម្រិត	កំណត់ចំណាំ
ការបណ្តុះបណ្តុះគ្រូបង្រៀន			
• ១២+៤ (៤ ឆ្នាំ)	សិស្សបញ្ចប់ការសិក្សាមធ្យមសិក្សាទុតិយភូមិ	• មធ្យមសិក្សាបឋមភូមិ • បឋមសិក្សា (មត្តេយ្យ)	ត្រូវបានអនុវត្តនៅវិទ្យាស្ថានគរុកោសល្យ
• បរិញ្ញាបត្រ+១ (១ ឆ្នាំ)	និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រថ្មីៗ	• អនុវិទ្យាល័យ	មិនមាន

វគ្គវិក្រឹតការគ្រូបង្រៀន/ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ			
• កម្មវិធីរយៈពេលវែង (៦០ ក្រេឌីត)	គ្រូបង្រៀន១២+២ ក្នុងប្រព័ន្ធទាំងអស់	• អនុវិទ្យាល័យ • បឋមសិក្សា (មត្តេយ្យ)	ត្រូវបានអនុវត្តនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញជាកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន
• កម្មវិធីរយៈពេលខ្លី (៣០ ក្រេឌីត)	គ្រូបង្រៀន១២+២ ដែលមានបរិញ្ញាបត្រលើជំនាញពាក់ព័ន្ធ	• ជាពិសេសសម្រាប់អនុវិទ្យាល័យ	មិនមាន

ក្នុងចំណោមជម្រើសទាំងអស់នៅក្នុងតារាង ខណៈដែល "១២+២" (និង១២+៤) ត្រូវបានគេហៅថា "គំរូស្របគ្នា" សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនដំបូង "បរិញ្ញាបត្រ+១" ត្រូវបានគេហៅថា "គំរូជាប់គ្នា" ដែលផ្តោតលើវិធីសាស្ត្របង្រៀន ពីព្រោះថាគរុនិស្សិតត្រូវបានសន្មតថាបានសិក្សាពីចំណេះដឹងខ្លឹមសារយ៉ាងទូលំទូលាយនៃមុខវិជ្ជារបស់ពួកគេក្នុងកម្មវិធីបរិញ្ញាបត្រមុន។ ហេតុផលនេះហើយបានជាគំរូជាប់គ្នាគឺមានលក្ខណៈទូទៅសម្រាប់គ្រូបង្រៀនមធ្យមសិក្សាជាងបឋមសិក្សានៅប្រទេសជាច្រើន។

ម្យ៉ាងវិញទៀត "កម្មវិធីរយៈពេលវែង" ជាកម្មវិធីផ្អែកលើចំនួនក្រេឌីត ដែលគ្រូបង្រៀនក្នុងប្រព័ន្ធទទួលបានក្រេឌីតដោយការសិក្សាម៉ូឌុលនានា (មិនមាន) ផ្តល់ដោយគ្រឹះស្ថានផ្តល់សេវាអប់រំគ្រូបង្រៀន។ ឧទាហរណ៍ដូចជាកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ធ្វើឡើងដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាផ្នែកនៃគម្រោងធនាគារពិភពលោក ផ្តល់កម្មវិធីវិក្រឹតការចំនួន ៦០ក្រេឌីតសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ២០០០នាក់តាមរយៈការរៀនផ្ទាល់ និងពីចម្ងាយ។

"កម្មវិធីរយៈខ្លី" ក៏ជាកម្មវិធីផ្អែកលើចំនួនក្រេឌីត សម្រាប់គ្រូបង្រៀន១២+២ ដែលបានសិក្សា (ភាគច្រើនតាមសាកលវិទ្យាល័យឯកជន) នៅសាកលវិទ្យាល័យស្របពេលដែលកំពុងបម្រើការងារនៅតាមសាលារៀនរបស់ពួកគាត់ និងទទួលបានបរិញ្ញាបត្រលើមុខវិជ្ជាឯកទេសដែលកំពុងបង្រៀន។ កម្មវិធីនេះតម្រូវឱ្យសិក្សាចំនួន ៣០ក្រេឌីតក្នុងចំណោមម៉ូឌុលដែលបានផ្តល់ឱ្យ (ប្រការ១៤ និង១៧ ក្នុងប្រកាសលេខ១៨៧០) និងគ្រូបង្រៀនខាងលើអាចទទួលបានចំនួនក្រេឌីតតាមរយៈកម្មវិធីវិក្រឹតការ/អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ឬអាចចុះឈ្មោះចូលរៀននៅវិទ្យាស្ថានគរុកោសល្យ ជាសិស្សបង់ថ្លៃក្រៅម៉ោងដើម្បីសិក្សាម៉ូឌុលដែលចាំបាច់។ កម្មវិធីរយៈពេលខ្លីនេះ មិនសំដៅចំពោះគ្រូបង្រៀន ១២+២ ដែលមានបរិញ្ញាបត្រលើជំនាញដែលមិនពាក់ព័ន្ធនឹងមុខវិជ្ជាពួកគាត់បង្រៀននៅសាលារៀននោះទេ ហើយចំពោះ"គ្រូបង្រៀនដែលមានបរិញ្ញាបត្របែបនេះ" តម្រូវឱ្យបញ្ចប់កម្មវិធីរយៈពេលវែងដើម្បីក្លាយជា "គ្រូបង្រៀនមានបរិញ្ញាបត្រលើជំនាញបង្រៀន" ឬក៏ "គ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់"។ លើសពីនេះទៀត តារាងខាងលើបានបង្ហាញថា កម្មវិធីរយៈពេលខ្លីគឺផ្តោតសំខាន់សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន ពីព្រោះមានការបណ្តុះបណ្តាលបរិញ្ញាបត្រតិចតួចប៉ុណ្ណោះ

ដែលពាក់ព័ន្ធនឹងការអប់រំបឋមសិក្សា និងមត្តេយ្យសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុក លើកលែងតែកម្មវិធី ១២+៤ នៅវិទ្យាស្ថានគរុកោសល្យ។

ទោះបីជាវិទ្យាស្ថានគរុកោសល្យ វិទ្យាស្ថានជាតិអប់រំ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញនឹងក្លាយជាតួអង្គសំខាន់ដែលអាចរួមចំណែកដោយផ្ទាល់ក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន សាលាគរុកោសល្យទំនងជាមិនអាចដើរតួនាទីក្នុងកម្រិតនេះបានទេដោយសារការខ្វះគ្រូឧទ្ទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ទោះបីជាយ៉ាងណា ក៏មានជម្រើសមួយចំនួនក្នុងការប្រើប្រាស់ធនធាននៃសាលាគរុកោសល្យសម្រាប់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដូចជា ការប្រើប្រាស់សាលាគរុកោសល្យជាគ្រឹះស្ថានរណបរបស់វិទ្យាស្ថានគរុកោសល្យ ដូច្នេះគ្រូបង្រៀនចេញថ្មី និងគ្រូបង្រៀនក្នុងប្រព័ន្ធអាចរៀនម៉ូឌុលមួយចំនួននៃកម្មវិធីបណ្តុះបណ្តាល និងរិក្រឹតការខាងលើនៅសាលាគរុកោសល្យទាំងនោះ។ គំរូគ្រឹះស្ថានរណបនេះអាចអនុវត្តបានដោយមានការបញ្ចូលគ្នានៃ (១) ការរៀនមេរៀនផ្ទាល់ជាមួយគ្រូឧទ្ទេសសាលាគរុកោសល្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (២) ការរៀនពីចម្ងាយដោយភ្ជាប់សាលាគរុកោសល្យជាមួយនិងវិទ្យាស្ថានគរុកោសល្យតាមប្រព័ន្ធអ៊ីនធឺណេត និង(៣) ការរៀនតាមរយៈសម្ភារៈអនឡាញ រួមមានមេរៀនជាវីដេអូដែលវិទ្យាស្ថានគរុកោសល្យបានផលិត។

២.៣. ការជ្រើសរើសគ្រូបង្រៀនតាមប្រភេទភូមិសិក្សា

ការរីករាតត្បាតនៃជំងឺកូវីដ-១៩នៅឆ្នាំ២០២០ បណ្តាលឱ្យមានការផ្អាកជ្រើសរើសគរុសិស្ស/គរុនិស្សិតចូលរៀននៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដូចជា សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមសាលាគរុកោសល្យនិងរិក្រឹតការ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ វិទ្យាស្ថានគរុកោសល្យ និងវិទ្យាស្ថានជាតិអប់រំក្នុងឆ្នាំសិក្សា២០២០-២០២១ ដែលទំនងជាធ្វើឱ្យការផ្គត់ផ្គង់គ្រូបង្រៀនមិនគ្រប់គ្រាន់នៅក្នុងរយៈពេលពីរឬបីឆ្នាំខាងមុខ ជាពិសេសនៅតំបន់ដាច់ស្រយាល។ ជំងឺនេះក៏បានប៉ះពាល់ដល់សេដ្ឋកិច្ចប្រទេសកម្ពុជាទោះបីជាបណ្តោះអាសន្ន ហើយវានៅតែមានភាពមិនច្បាស់លាស់ថាវិបត្តិសេដ្ឋកិច្ចនឹងប៉ះពាល់ដល់គ្រួសារនិងការចុះឈ្មោះចូលរៀនរបស់កូនពួកគេប៉ុណ្ណា។ នៅក្នុងពេលវេលាដែលមិនអាចទាយទុកបាន និងមិនច្បាស់លាស់បែបនេះ ផែនការមេធ្យមនេះប្រើប្រាស់ស្ថិតិថ្មីៗបំផុតអំពីគ្រូបង្រៀនមកធ្វើជាមូលដ្ឋាននៃការប៉ាន់ស្មានចំនួនគ្រូបង្រៀនដើម្បីដំឡើងទៅបរិញ្ញាបត្រជាជាងការព្យាករណ៍ទុកយោងតាមស្ថិតិមុនៗ ដូចដែលបានបង្ហាញក្នុងតារាង២.៨ ខាងក្រោម។ ចំនួនក្នុងជួរឈរ គ នៃតារាងនឹងត្រូវកែសម្រួលដោយយោងតាមចំនួននៃបុគ្គលិកបង្រៀនបានមកពីស្ថិតិរបស់ក្រសួង។

តារាង២.៨ ចំនួនគ្រូបង្រៀនប៉ាន់ស្មានសម្រាប់ដំឡើងគុណវុឌ្ឍិទៅដល់កម្រិតបរិញ្ញាបត្រ

ភូមិសិក្សា	ក	ខ	គ
	បុគ្គលិកសិក្សា នៅឆ្នាំសិក្សា ២០១៩-២០២០	គោលដៅ % ក្នុងឆ្នាំ ២០២៣ ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣	ចំនួនគ្រូបង្រៀនមានបរិញ្ញាបត្រ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប៉ាន់ស្មាននៅក្នុងឆ្នាំ ២០២៣ (= ក*ខ)
បឋមសិក្សា	៤៤,៩១៤	៧%	៣,១៤៤

អនុវិទ្យាល័យ	២៧,៧៣៨	១៥ %	៤,១៦០

ប្រភព៖ ស្ថិតិនិងសូចនាករអប់រំសាធារណៈឆ្នាំ២០១៨-២០១៩និងឆ្នាំ២០១៨-២០១៩ (ក្រសួងអ.យ.ក ឆ្នាំ២០១៩ ២០២០)

ដោយសារថវិកាមានកម្រិត ក្រសួងអប់រំ យុវជន និងកីឡានឹងផ្តល់អាទិភាពដំឡើងគុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋានមុន បន្ទាប់មកគ្រូបង្រៀនបឋមសិក្សាក្នុងកំឡុងពេលអនុវត្តផែនការមេធ្យម។

២.៣.១ គ្រូបង្រៀនកម្រិតមូលដ្ឋាន

តួលេខគោលដៅបង្ហាញក្នុងតារាង២.៨ ដែលមានចំនួនច្រើនជាង ៤,១០០នាក់ កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនធ្វើឡើងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានរំពឹងថានឹងដំឡើងគុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋានប្រហែល ៣,៥០០នាក់ពី ១២+២ ទៅបរិញ្ញាបត្រ[7] ហើយវិទ្យាស្ថានគរុកោសល្យទាំង២នឹងផលិតគ្រូបង្រៀនកម្រិតមូលដ្ឋាន១២+៤ ថ្មីចំនួន ២០០នាក់ ក្នុងឆ្នាំ២០២២ និង២០០នាក់ ក្នុងឆ្នាំ២០២៣។ ដូច្នេះយ៉ាងហោចណាស់នឹងមានគ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំនួន ១,០០០នាក់ត្រូវបានបណ្តុះបណ្តាលត្រឹមឆ្នាំ២០២៣។

ក្នុងចំណោមកម្មវិធីដែលមាននៅក្នុងតារាង២.៧ នៅផ្នែកមុន កម្មវិធីក្រឹតការ/អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលវែង និងរយៈពេលខ្លីអាចត្រូវផ្តល់ជូនគ្រូបង្រៀនកម្រិតមូលដ្ឋានដែលនៅក្នុងប្រព័ន្ធ និងកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រ+១ អាចផ្តល់ជូនបន្ថែមនៅពេលដែលលក្ខខណ្ឌចាំបាច់នានាត្រូវបានបំពេញ។

កម្មវិធីក្រឹតការ/អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលវែង និងរយៈពេលខ្លីទាំងនេះ អាចត្រូវអនុវត្តដោយវិទ្យាស្ថានជាតិអប់រំ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យជាលក្ខណៈសិក្សាផ្ទាល់នៅពេលវិស្សមកាល និងការសិក្សាពីចម្ងាយ/ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។ ខណៈដែលកម្មវិធីរយៈពេលខ្លីចំនួន៣០ក្រេឌីតអាចអនុវត្តបានយ៉ាងហ្មត់ចត់ក្នុង១ឆ្នាំ កម្មវិធីរយៈពេលវែងចំនួន៦០ក្រេឌីតអាចបញ្ចប់បានក្នុងរយៈពេល២ឆ្នាំឬយូរជាងនេះ។ វានឹងជំរុញការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនប្រសិនបើវិទ្យាស្ថានគរុកោសល្យអាចទទួលគ្រូបង្រៀនក្នុងប្រព័ន្ធជាសិស្សក្រៅម៉ោង ដូច្នេះពួកគេអាចសិក្សាម៉ូឌុលនៅថ្ងៃ និងពេលវេលាដែលពួកគេមិនបង្រៀននៅសាលារៀនរបស់ពួកគេ។

តម្រូវការក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋានគឺខ្ពស់ជាងគ្រូបង្រៀនបឋមសិក្សា។ ដូច្នេះត្រូវផ្តល់អាទិភាពច្រើនជាងគេបំផុតក្នុងចំណោមភូមិសិក្សាទាំងអស់។

២.៣.២ គ្រូបង្រៀនបឋមសិក្សា

តារាង ២.៨ បង្ហាញថា គ្រូបង្រៀនជាង ៣,១០០នាក់ គួរត្រូវបានដំឡើងគុណវុឌ្ឍិដើម្បីសម្រេចគោលដៅផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយសារមិនមានកម្មវិធីដំឡើងគុណវុឌ្ឍិគុណវុឌ្ឍិគ្រូបង្រៀនណាមួយទេសម្រាប់គ្រូបឋមសិក្សា១២+២។

[7] គម្រោងពង្រឹងការអប់រំមធ្យមសិក្សា (SEIP) បានអនុវត្តកម្មវិធីលើកកម្ពស់សម្រាប់ ១២+២ ទៅបរិញ្ញាបត្រត្រឹមឆ្នាំ២០២១ និងគម្រោងពង្រឹងការអប់រំចំណេះទូទៅ (GEIP) មានគម្រោងអនុវត្តកម្មវិធីនេះសម្រាប់ ១,៥០០នាក់ត្រឹមឆ្នាំ២០២៣ នៅដំណាក់កាលវាយតម្លៃមុនខែធ្នូ ឆ្នាំ២០២០។

ក្នុងចំណោមកម្មវិធីដែលមាននៅក្នុងតារាង២.៧ នៅផ្នែកមុន កម្មវិធីវិក្រឹតការ/អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលវែង និងរយៈពេលខ្លីអាចត្រូវផ្តល់ជូនគ្រូបង្រៀនកម្រិតមូលដ្ឋាននៅក្នុងប្រព័ន្ធ។ ការបណ្តុះបណ្តាលបរិញ្ញាបត្រ+១ ទំនងជាមិនត្រូវបានផ្តល់ជូនគ្រូបង្រៀនបឋមសិក្សាជាគំរូជាប់គ្នានៃការបណ្តុះបណ្តាលតាមរចនាសម្ព័ន្ធ ដែលមានម៉ូឌុលតិចតួចលើវិធីសាស្ត្របង្រៀនដែលជាចំណុចសំខាន់នៃការបង្រៀន និងរៀននៅកម្រិតបឋមសិក្សា។

នៅកម្រិតមធ្យមសិក្សាបឋមភូមិ កម្មវិធីវិក្រឹតការ/អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលវែង និងរយៈពេលខ្លីអាចអនុវត្តដោយវិទ្យាស្ថានជាតិអប់រំ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យជាលក្ខណៈសិក្សាផ្ទាល់នៅពេលវិស្សមកាល និងការសិក្សាពីចម្ងាយ/ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាទាក់ទងនឹងសមត្ថភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននឹងលេចឡើងនៅពេលកម្មវិធីទាំងនេះត្រូវបានធ្វើឡើងស្របគ្នានឹងកម្មវិធីគ្រូបង្រៀនកម្រិតមូលដ្ឋាន។

២.៣.៣ គ្រូបង្រៀនមត្តេយ្យសិក្សា

ស្ថានភាពទាក់ទងនឹងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនមត្តេយ្យសិក្សាគឺនៅឆ្ងាយ បើប្រៀបធៀបនឹងគ្រូបង្រៀនកម្រិតមូលដ្ឋាន។ សាវតាអប់រំរបស់គ្រូបង្រៀនមត្តេយ្យសិក្សាភាគច្រើនគឺការអប់រំមធ្យមសិក្សា ដូចដែលបានកត់ត្រាទុកនៅប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំឆ្នាំ២០១៨-២០១៩ និងបានបង្ហាញនៅក្នុងតារាង ២.៩ ខាងក្រោម (មធ្យមសិក្សាទុតិយភូមិ ៥៨.៣៥ភាគរយ មធ្យមសិក្សាបឋមភូមិ ៣២.៤៨ភាគរយ បឋមសិក្សា ៣.៦៤ភាគរយ) មានតែចំនួន ៥.៥៣ភាគរយប៉ុណ្ណោះដែលបញ្ចប់បរិញ្ញាបត្រឬអាចខ្ពស់ជាងនេះ។ អ្វីដែលកាន់តែចម្រូងចម្រាស់គឺពួកគាត់ភាគច្រើនជាគ្រូបង្រៀនសហគមន៍ ដែលមិនមែនជាបុគ្គលិករដ្ឋាភិបាល។

តារាង ២.៩ សាវតាអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា

	[ក]	[ខ]	[គ]	[ឃ]	[ង]	[ច]	[ឆ]
ឆ្នាំ	បឋមសិក្សា	មធ្យមសិក្សាបឋមភូមិ	មធ្យមសិក្សាទុតិយភូមិ	បរិញ្ញាបត្រ	អនុបណ្ឌិត	បណ្ឌិត	សរុប
២០១១	១៩៣	២,១៦៨	១,៤៩៤	២៥	១	០	៣,៨៨១
២០១២	១៦៩	២,១៨០	១,៧៧៣	៣០	០	០	៤,១៥២
២០១៣	១៨០	១,៩២៦	២,៣៨០	៥១	០	០	៤,៥៣៧
២០១៤	១៩២	១,៩៨៩	២,៥៦៥	៩១	២	០	៤,៨៣៩
២០១៥	១៧៥	១,៦៨២	២,៥៣៨	១៤០	២	០	៤,៥៣៧
២០១៦	១៨១	១,៦៦២	២,៨១៤	២១៨	២	០	៤,៨៧៧
២០១៧	**១៨៧**	**១,៦៧០**	**៣,០០០**	**២៧៩**	**៥**	**០**	**៥,១៤១**
២០១៧ (%)	**៣.៦៤%**	**៣២.៤៨%**	**៥៨.៣៥%**	**៥.៤៣%**	**០.១០%**	**០%**	**១០០%**

ដូច្នេះវានឹងចំណាយពេលច្រើនឆ្នាំទៀតក្នុងការដំឡើងគុណវុឌ្ឍិពួកគេនាពេលអនាគត ហើយកម្មវិធីបណ្តុះបណ្តាលផ្សេងៗនឹងត្រូវការរៀបចំជាលក្ខណៈយុទ្ធសាស្ត្រ និងអនុវត្តជាជំហានៗ។ ជម្រើសពិតប្រាកដមួយនាពេលអនាគតគឺប្រហែលជាការដាក់ឱ្យដំណើរការកម្មវិធី១២+៤ ដើម្បីផលិតអ្នកដឹកនាំនៃគ្រូបង្រៀនមត្តេយ្យសិក្សា។ ទោះបីជាយ៉ាងណា វានឹងត្រូវការពេលវេលាបន្ថែមសម្រាប់ការពិភាក្សាពីកម្មវិធីនេះ និងប្រព័ន្ធវិញ្ញាបនបត្រសមស្រប។ បញ្ហានេះនឹងមកដល់នៅដំណាក់កាលបន្ទាប់ នៅពេលដែលក្រសួងអប់រំ យុវជន និងកីឡាចាប់ផ្តើមដំណើរការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាន។

សម្រាប់ការរៀបចំកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនមត្តេយ្យសិក្សាគួរតែបញ្ចូល ៤៥ក្រេឌីតនៃការសិក្សាលើមុខវិជ្ជា/ម៉ូឌុលកាតព្វកិច្ចចំនួន៧ (រួមមាន ការអប់រំភាសាខ្មែរ ការអប់រំគណិតវិទ្យា ការអប់រំបរិស្ថានជីវិត ការអប់រំភាសាអង់គ្លេស ការអប់រំកាយនិងសុខភាព ការអប់រំសិល្បៈ ល្បែងសិក្សា) យោងតាមប្រកាសលេខ ១៨៧០ ប្រការ១០ដល់១២។ ១៥ ក្រេឌីតផ្សេងទៀត អាចទទួលបានតាមរយៈម៉ូឌុលជម្រើសដែលអាស្រ័យលើចក្ខុវិស័យ និងគោលការណ៍របស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននីមួយៗ។

២.៣.៤ គ្រូបង្រៀនសាលាឯកជន

សាវតាអប់រំនៃគ្រូបង្រៀនសាលាឯកជនគឺខុសឆ្ងាយពីគ្រូបង្រៀនសាលារដ្ឋ។ ស្ទើរតែជាងពាក់កណ្តាលនៃគ្រូបង្រៀនសាលាឯកជន (៥៨.៣៧ភាគរយ) ទទួលបានបរិញ្ញាបត្រ និង៥.០១ភាគរយ មានសញ្ញាបត្រអនុបណ្ឌិត (សូមមើលតារាង ២.១០ ខាងក្រោម)។ ទោះជាយ៉ាងណាក៏ដោយ ទោះបីជាមិនមានទិន្នន័យគួរឱ្យទុកចិត្តបានក៏ដោយ គេសន្និដ្ឋានថាគ្រូបង្រៀនសាលាឯកជនភាគច្រើនដែលមានបរិញ្ញាបត្រ ឬសញ្ញាបត្រអនុបណ្ឌិត មិនបានទទួលការបណ្តុះបណ្តាលផ្នែកគរុកោសល្យគ្រប់គ្រាន់ ពីព្រោះពុំមានសាកលវិទ្យាល័យរដ្ឋឬឯកជនណាមួយផ្តល់កម្មវិធីសិក្សាក្រោយឧត្តមសិក្សាលើមុខជំនាញការបង្រៀន និងរៀននៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិឡើយ។

តារាង២.១០ សាវតាអប់រំគ្រូបង្រៀនឯកជន

	[ក]	[ខ]	[គ]	[ឃ]	[ង]	[ច]	[ឆ]
ឆ្នាំ	**បឋមសិក្សា**	**មធ្យមសិក្សាបឋមភូមិ**	**មធ្យមសិក្សាទុតិយភូមិ**	**បរិញ្ញាបត្រ**	**អនុបណ្ឌិត**	**បណ្ឌិត**	**សរុប**
២០១៥	៣៧៩	១,០៣០	៣,៨៥៦	៤,៥៤៤	៥០៣	០	១០,៣១២
២០១៦	មិនមាន	មិនមាន	មិនមាន	មិនមាន	មិនមាន	មិនមាន	មិនមាន
២០១៧	១៨៧	៧៣៩	៣,៧៤២	៦,៩៨៨	៥៧៩	១៣	១២,២៤៨
២០១៨	**១៨៦**	**៨១៥**	**៣,៩៤១**	**៧,៨៧៧**	**៦៦២**	**១៥**	**១៣,៤៩៦**
២០១៨ (%)	**១.៣៨%**	**៦.០៤%**	**២៩.២០%**	**៥៨.៣៧%**	**៤.៩០%**	**០.១១%**	**១០០%**

ដូច្នេះសម្រាប់គោលបំណងត្រួតពិនិត្យគុណភាព ក្រសួងអប់រំ យុវជន និងកីឡាគួរតែធ្វើការស្រាវជ្រាវ ដើម្បីបញ្ជាក់ថា គ្រូបង្រៀនឯកជនក្នុងប្រព័ន្ធបានទទួលការបណ្តុះបណ្តាលគរុកោសល្យកម្រិតណា រៀបចំនិយាមច្បាប់ សម្រាប់សាលារៀនឯកជនក្នុងការជួលគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលគរុកោសល្យគ្រប់គ្រាន់ និងបង្កើតយន្តការដែលតាមរយៈនេះគ្រូបង្រៀនសាលាឯកជនមិនបាន ឬបានទទួលការបណ្តុះបណ្តាល អាចរៀនម៉ូឌុលចាំបាច់នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

២.៤ យុទ្ធសាស្ត្រការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

២.៤.១ គោលការណ៍គ្រឹះ

ដូចដែលបានពិភាក្សានៅផ្នែកមុន មិនមានវិធីច្រើនទេក្នុងការផ្គត់ផ្គង់គ្រូបង្រៀនដែលមានបរិញ្ញាបត្រជំនាញក្នុងការបង្រៀន ឬ "គ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" ទៅដល់សាលារៀន។ ដូច្នេះដើម្បីផលិតគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំនួនរាប់រយនាក់ជាបន្តបន្ទាប់ វាចាំបាច់ខ្លាំងក្នុងការបញ្ចូលគ្នានូវវិធីទាំងនោះ ដើម្បីឱ្យមនុស្សកាន់តែច្រើនចូលរួមក្នុងកម្មវិធីដំឡើងគុណវុឌ្ឍិ ដូចបង្ហាញក្នុងរូបភាព២.២ ដែលនឹងតាមពីក្រោយដោយការអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់នៃកម្មវិធីដំឡើងគុណវុឌ្ឍិ ដោយមិនធ្វើឱ្យប៉ះពាល់គុណភាពនៃការបង្រៀន និងរៀនឡើយ។ ដោយសារបច្ចុប្បន្ននេះមានគ្រូបង្រៀនកម្រិតមូលដ្ឋានច្រើនបំផុតប្រមាណ ៣០,០០០នាក់ ដែលភាគច្រើននៃពួកគេនឹងក្លាយជាគ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងរយៈពេល២០ឆ្នាំ បើសិនជាគ្រូបង្រៀនច្រើនជាង ១,៥០០នាក់នឹងត្រូវបានផលិតថ្មីតាមតាមរយៈកម្មវិធី១២+៤ ឬបរិញ្ញាបត្រ+១ ឬត្រូវបានដំឡើងគុណវុឌ្ឍិតាមរយៈកម្មវិធីវិក្រឹតការ/អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជារៀងរាល់ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយចំនួនគ្រូបង្រៀន១២+២ នឹងនៅដដែល ដរាបណានៅតែមានការបណ្តុះបណ្តាលតាមរូបមន្ត១២+២។



ប្រភព៖ ដូចនឹងរូបភាពទី២.១

រូបភាព ២.២ ជម្រើសនៃការបណ្តុះបណ្តាលគ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

២.៤.២ ក្របខណ្ឌគតិយុត្ត

ក្របខណ្ឌគតិយុត្តសម្រាប់រៀបចំកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀននេះគឺផ្អែកលើប្រកាសលេខ១៨៧០ របស់ក្រសួងអប់រំ យុវជន និងកីឡា អនុម័តនៅឆ្នាំ២០១៩ ដែលក្នុងនោះចំនួនក្រេឌីត មុខវិជ្ជាសិក្សា វិធីនៃការកាត់បន្ថយក្រេឌីតផ្អែកលើចំនួនឆ្នាំនៃបទពិសោធន៍បង្រៀន និងសញ្ញាបត្របរិញ្ញាបត្រដែលគាត់មាន។ល។ ត្រូវបានចែងនៅក្នុងប្រកាសនេះ។

តារាង ២.១១ និង២.១២ ដែលដកស្រង់ចេញពីប្រការ១០ និង១៣ បង្ហាញពីចំនួនក្រេឌីតអប្បបរមាដែលចាំបាច់សម្រាប់គ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានក្នុងការដំឡើងគុណវុឌ្ឍិ។ ដូចដែលបានបង្ហាញនៅក្នុងតារាង កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនសម្រាប់គ្រូបង្រៀនបឋមសិក្សា១២+២ ផ្តោតច្រើនលើការសិក្សាពីកម្មវិធីសិក្សា(ឧទាហរណ៍ វិធីសាស្រ្តបង្រៀន) ខណៈដែលកម្មវិធីសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានផ្តោតខ្លាំងលើចំណេះដឹងលើមុខវិជ្ជាឯកទេស ដើម្បីជួយពួកគេបង្រៀនមុខវិជ្ជានៅសាលាមធ្យមសិក្សាបឋមភូមិដោយផ្អែកលើការយល់ដឹងពីបញ្ញត្តិដែលត្រូវអភិវឌ្ឍទូទាំងកម្រិតមធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។

តារាង២.១១ ចំនួនក្រេឌីតអប្បបរមាសម្រាប់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនបឋមសិក្សា

មុខវិជ្ជាសិក្សា		ចំនួនក្រេឌីត ដែលត្រូវទទួលបានពីគ្រឹះស្ថានអប់រំ	ម៉ូឌុលដែលចាំបាច់
១	ការសិក្សាពីការអប់រំ	៦	-ការអប់រំចិត្តវិទ្យា(កុមារតូច/ដំណាក់កាលវិវត្ត) -ការគ្រប់គ្រងថ្នាក់រៀន -ការវាយតម្លៃ
២	ចំណេះដឹងមុខវិជ្ជាឯកទេស	១៤	ខ្លឹមសារមុខវិជ្ជាកម្រិតបឋមសិក្សាឬមធ្យមសិក្សា៖ -ភាសាខ្មែរ -គណិតវិទ្យា -សិក្សាសង្គម -វិទ្យាសាស្រ្ត -ភាសាអង់គ្លេស
៣	ការសិក្សាពីកម្មវិធីសិក្សា	២១	មុខវិជ្ជាទាក់ទងនឹងទ្រឹស្តីនិងការអនុវត្តលើការបង្រៀន និងរៀននៅកម្រិតបឋមសិក្សាមានដូចខាងក្រោម៖ -ការអប់រំភាសាខ្មែរ -ការអប់រំគណិតវិទ្យា -ការអប់រំសិក្សាសង្គម -ការអប់រំវិទ្យាសាស្រ្ត

			- ការអប់រំភាសាអង់គ្លេស - ការអប់រំអប់រំកាយ - ការអប់រំសិល្បៈ - ការអប់រំសុខភាព
៤	ការលើកកម្ពស់ផ្នែកភាសាបរទេស	២	- ការអាននិងសរសេរអត្ថបទអប់រំជាភាសាអង់គ្លេស
៥	ការស្រាវជ្រាវអប់រំ	៣	- ទ្រឹស្តីពីការស្រាវជ្រាវ - ការស្រាវជ្រាវប្រតិបត្តិ
៦	កម្មសិក្សាប្រតិបត្តិ	០	---
៧	មុខវិជ្ជារួម	៤	- ការប្រឹក្សាអប់រំ (សម្រាប់សិស្សបឋមសិក្សា) - ការអប់រំសម្រាប់កុមារមានតម្រូវការពិសេស
ជម្រើស		**១០**	(គ្រឹះស្ថានអប់រំនីមួយៗអាចបន្ថែមម៉ូឌុលផ្សេងទៀតបាន)
សរុប		**៦០**	

តារាង២.១២ ចំនួនក្រេឌីតអប្បបរមាសម្រាប់ដំឡើងគុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាន

មុខវិជ្ជាសិក្សា		**ចំនួនក្រេឌីតដែលត្រូវទទួលបានពីគ្រឹះស្ថានអប់រំ**	**ម៉ូឌុលដែលចាំបាច់**
១	ការសិក្សាពីការអប់រំ	៦	- ការអប់រំចិត្តវិទ្យា (កុមារតូច/ដំណាក់កាលវិវត្ត) - ការគ្រប់គ្រងថ្នាក់រៀន - ការវាយតម្លៃ - ការប្រើ ICT ក្នុងការអប់រំ
២	ចំណេះដឹងមុខវិជ្ជាឯកទេស	២២	ម៉ូឌុលដែលទាក់ទងនឹងមុខវិជ្ជាណាមួយនៅកម្រិតមធ្យមសិក្សាឬខ្ពស់ជាងនេះ
៣	ការសិក្សាពីកម្មវិធីសិក្សា	៩	ម៉ូឌុលពីការបង្រៀននិងរៀនដែលទាក់ទងនឹងមុខវិជ្ជាឯកទេស
៤	ការលើកកម្ពស់ផ្នែកភាសាបរទេស	៦	- ការអាននិងសរសេរអត្ថបទអប់រំជាភាសាអង់គ្លេស
៥	ការស្រាវជ្រាវអប់រំ	៣	- ទ្រឹស្តីពីការស្រាវជ្រាវ - ការស្រាវជ្រាវប្រតិបត្តិ
៦	កម្មសិក្សាប្រតិបត្តិ	០	----

៧	មុខវិជ្ជារួម	៤	- ការអប់រំពីការណែនាំនិងការផ្ដល់ប្រឹក្សាអាជីព - ការអប់រំសម្រាប់កុមារមានតម្រូវការពិសេស
ជម្រើស		**១០**	(គ្រឹះស្ថានអប់រំនីមួយៗអាចបន្ថែមម៉ូឌុលផ្សេងៗទៀតបាន)
សរុប		**៦០**	

តារាង២.១៣ កម្រិតសញ្ញាបត្រសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានទទួលបានការកាត់បន្ថយចំនួនក្រេឌីត

មុខវិជ្ជា	**សញ្ញាបត្របរិញ្ញាបត្រឬខ្ពស់ជាងនេះ**
ភាសាខ្មែរ	អក្សរសាស្ត្រខ្មែរ
គណិតវិទ្យា	គណិតវិទ្យា
វិទ្យាសាស្ត្រ	រូបវិទ្យា/គីមីវិទ្យា/ជីវវិទ្យា/ផែនដីវិទ្យា
សិក្សាសង្គម	ប្រវត្តិវិទ្យា/ភូមិវិទ្យា/សេដ្ឋកិច្ច/ទស្សនវិទ្យា/រដ្ឋបាលសាធារណៈ
ភាសាអង់គ្លេស	អក្សរសាស្ត្រអង់គ្លេស/ភាសាសង្គមវិទ្យា (Sociolinguistics)/ការប្រើប្រាស់ភាសា
ភាសាបារាំង	អក្សរសាស្ត្របារាំង/ភាសាសង្គមវិទ្យា (Sociolinguistics)/ការប្រើប្រាស់ភាសា
សិល្បៈ	សិល្បៈ/តន្ត្រី/របាំ
អប់រំកាយ	កីឡា/វិទ្យាសាស្ត្រកីឡា/អប់រំកាយ
ICT	ICT/បច្ចេកវិទ្យា

តារាង២.១៤ ចំនួនក្រេឌីតមូលដ្ឋានផ្អែកលើបទពិសោធន៍បង្រៀន

បទពិសោធន៍បង្រៀន		**ចំនួនក្រេឌីតត្រូវកាត់បន្ថយ**	**ចំនួនក្រេឌីតអប្បបរមាចាំបាច់សម្រាប់ការដំឡើងគុណវុឌ្ឍិ**
១	ពី១ឆ្នាំទៅ៤ឆ្នាំ	មិនមានកាត់បន្ថយ	៦០
២	ពី៥ឆ្នាំទៅ១០ឆ្នាំ	កាត់បន្ថយ ៣ក្រេឌីតពីមុខវិជ្ជាជម្រើស	៥៧
៣	ពី១១ឆ្នាំទៅ១៥ឆ្នាំ	កាត់បន្ថយ ៦ក្រេឌីតពីមុខវិជ្ជាជម្រើស	៥៤
៤	ពី១៦ឆ្នាំឡើងទៅ	កាត់បន្ថយ ៩ក្រេឌីតពីមុខវិជ្ជាជម្រើស	៥១

ដូចមាននៅក្នុងតារាង២.១៣ ប្រការ១៦នៃប្រកាសលេខ១៨៧០ ក៏បានឱ្យនិយមន័យនៃជំនាញដែលត្រូវបានទទួលស្គាល់ថាជា "បរិញ្ញាបត្រលើជំនាញពាក់ព័ន្ធ" សម្រាប់ការបណ្ដុះបណ្ដាលបរិញ្ញាបត្រ+១ ឬក៏កម្មវិធីរយៈពេលខ្លី។ ឧទាហរណ៍ ប្រសិនបើគ្រូបង្រៀនគណិតវិទ្យាកម្រិតមូលដ្ឋាន១២+២មួយរូប ទទួលបានបរិញ្ញាបត្រផ្នែកគណិតវិទ្យា ឬគណិតវិទ្យាអនុវត្តន៍ពីសាកលវិទ្យាល័យ(ឯកជន) គាត់នឹងត្រូវបានទទួលស្គាល់ថាជា "គ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" ដោយគ្រាន់តែទទួលការបណ្ដុះបណ្ដាលបន្ថែមចំនួន ៣០ក្រេឌីត។ ប្រការ១៤ និង១៧ បានចែងពីសមាសភាពនៃចំនួន ៣០ក្រេឌីតនេះ ក្នុងន័យដែលគ្រូបង្រៀនបឋមសិក្សា/គ្រូបង្រៀនកម្រិតមូលដ្ឋានដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬខ្ពស់ជាងនេះលើ

ការអប់រំបឋមសិក្សា/មុខវិជ្ជានៅមធ្យមសិក្សាបឋមភូមិ តម្រូវឱ្យទទួលការបណ្តុះបណ្តាលយ៉ាងហោច ៣០ក្រេឌីត ដែលរួមមាន ការសិក្សាពីការអប់រំចំនួន ៤ក្រេឌីត ការសិក្សាអំពីកម្មវិធីសិក្សាចំនួន ៩ក្រេឌីត ការស្រាវជ្រាវអប់រំចំនួន ៣ក្រេឌីត មុខវិជ្ជារួមចំនួន ២ក្រេឌីត និងមុខវិជ្ជាជម្រើសចំនួន ១២ក្រេឌីត។

តារាង ២.១៣ នៃប្រការ១៩ បង្ហាញថា ចំនួនក្រេឌីតដែលត្រូវកាត់បន្ថយពីចំនួនក្រេឌីតអប្បបរមាដូចបានរៀបរាប់ខាងលើ ផ្អែកលើចំនួនឆ្នាំនៃបទពិសោធន៍បង្រៀន ដែលនឹងសម្រួលដល់គ្រូបង្រៀនដែលមានបទពិសោធន៍ ក្នុងការទទួលបានចំនួនក្រេឌីតដែលចាំបាច់ក្នុងរយៈពេលខ្លី។

គ្រប់កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនទាំងអស់ ត្រូវបានរៀបចំឡើងដោយផ្អែកលើប្រកាសនេះ ដូច្នេះប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនអាចធានាបាននូវតុល្យភាពរវាងចំណេះដឹង និងជំនាញវិជ្ជាជីវៈរបស់គ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

២.៤.៣ យុទ្ធសាស្ត្រការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

ផ្អែកលើការពិភាក្សាខាងលើ យុទ្ធសាស្ត្រចំនួន៤ខាងក្រោមត្រូវបានស្នើឡើងដើម្បីធានាថាគ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានផលិតជាប្រចាំ ហើយស្តង់ដារនេះនឹងក្លាយជាស្តង់ដាររួមយ៉ាងឆាប់រហ័សក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនត្រឹមឆ្នាំ២០២៥។

យុទ្ធសាស្ត្រទី១៖ ពង្រឹងសមត្ថភាពដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត ១២+៤ នៅវិទ្យាស្ថានគរុកោសល្យ

យុទ្ធសាស្ត្រទី២៖ ការបណ្តុះបណ្តាលបរិញ្ញាបត្រ+១ ដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់

យុទ្ធសាស្ត្រទី៣៖ បង្កើតយន្តការក្នុងការដំឡើងគុណវុឌ្ឍិតាមរយៈកម្មវិធីបណ្តុះបណ្តាលរយៈពេលវែង

យុទ្ធសាស្ត្រទី៤៖ ជំរុញគ្រូបង្រៀន១២+២ ចូលរួមក្នុងការដំឡើងគុណវុឌ្ឍិតាមរយៈកម្មវិធីបណ្តុះបណ្តាលរយៈខ្លីៗ

២.៤.៣.១ យុទ្ធសាស្ត្រទី១៖ ពង្រឹងសមត្ថភាពដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត ១២+៤ នៅវិទ្យាស្ថានគរុកោសល្យ

ការបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត១២+៤ ដែលកំពុងតែដំណើរការគឺជាសមាសភាពស្នូលក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ព្រោះកម្មវិធីនេះផលិតគ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៀងទាត់។ ទោះបីជាយ៉ាងណា ចំនួនកូតាសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានគឺមានចំនួន ៣០០នាក់ និង២០០នាក់នៅឆ្នាំសិក្សា២០១៨ និង២០១៩ ដែលមានចំនួនតិចជាង ១ភាគរយនៃអត្រាគ្រូបង្រៀនតាមកម្រិតនីមួយៗ។ មានទិដ្ឋភាពចំនួន២ក្នុងការពង្រឹងសមត្ថភាពដើម្បីបណ្តុះបណ្តាលគ្រូបង្រៀន១២+៤៖ (១)បង្កើនចំនួនកូតានៃការជ្រើសរើសគ្រូបង្រៀនសម្រាប់វិទ្យាស្ថានគរុកោសល្យទាំង២ក្នុងរយៈពេលខ្លី និងមធ្យម និង(២) បង្កើនចំនួនវិទ្យាស្ថានគរុកោសល្យក្នុងរយៈពេលមធ្យម និងវែង។ ទិដ្ឋភាពទី១ រួមមានគំនិតដែលថា វិទ្យាស្ថានគរុកោសល្យមួយត្រូវចាត់ទុកសាលាគរុកោសល្យនិងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនៅជិតខាង ជាគ្រឹះស្ថានរណបដែលគរុនិស្សិតក្នុងតំបន់នោះអាចសិក្សាម៉ូឌុលកម្រិត១២+៤ តាមរយៈការបញ្ចូលគ្នារវាងការរៀនពីចម្ងាយ ការរៀនផ្ទាល់នៅសាលាគរុកោសល្យ និងការរៀននៅវិទ្យាស្ថានគរុកោសល្យ។ ម្យ៉ាងវិញទៀតឧបសគ្គនៃការអភិវឌ្ឍសមត្ថភាពផ្គត់ផ្គង់

គ្រូបង្រៀនគឺកង្វះគ្រូឧទ្ទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅវិទ្យាស្ថានគរុកោសល្យ។ ដូច្នេះវាជាការចាំបាច់ដែលត្រូវជួលគ្រូឧទ្ទេសថ្មីៗ និងបំប៉នគ្រូឧទ្ទេសដែលមានស្រាប់ដើម្បីត្រៀមក្នុងការពង្រីកវិសាលភាពនេះ ហើយក្រសួងអប់រំ យុវជន និងកីឡាក៏ត្រូវខិតខំប្រឹងប្រែងដើម្បីទាក់ទាញបេក្ខជនមានសមត្ថភាពតាមរយៈការលើកកម្ពស់ស្ថានភាពនៃវិទ្យាស្ថានគរុកោសល្យ និងបុគ្គលិកបង្រៀនរបស់ខ្លួន។ ការខិតខំប្រឹងប្រែងក្នុងការជ្រើសរើសគ្រូឧទ្ទេសបែបនេះ ត្រូវគិតពីទស្សនៈទីផ្សារការងារ។ ការដំឡើងគុណវុឌ្ឍិទាមទារឱ្យមានការផ្តល់រង្វាន់ដែលមានលក្ខណៈប្រកួតប្រជែង ឱកាសនៃការអភិវឌ្ឍវិជ្ជាជីវៈ និងលក្ខខណ្ឌការងារ។

សកម្មភាពចម្បងៗទាក់ទងនឹងយុទ្ធសាស្ត្រទី១ ត្រូវបានស្នើឡើងដូចមានបង្ហាញក្នុងតារាងខាងក្រោម។

តារាង ២.១៥ សកម្មភាពចម្បងៗសម្រាប់យុទ្ធសាស្ត្រទី១

សកម្មភាពចម្បង	ពេលវេលា
១ បង្កើនកូតាចូលរៀនសម្រាប់វិទ្យាស្ថានគរុកោសល្យទាំង២	
១.១ បង្កើនចំនួនគរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យបន្តិចម្តង រហូតដល់ចំនួន៥០០នាក់សម្រាប់កម្រិតបឋមសិក្សា និង៣០០នាក់សម្រាប់មធ្យមសិក្សាបឋមភូមិ	២០២១-២០២៣
១.២ បញ្ឈប់ជាបណ្តើរៗការបណ្តុះបណ្តាល ១២+២នៅវិទ្យាស្ថានគរុកោសល្យ	២០២១-២០២៣
១.៣ ជ្រើសរើសបុគ្គលិកបង្រៀនដែលមានសមត្ថភាពសម្រាប់វិទ្យាស្ថានគរុកោសល្យ	២០២១-២០២៣
១.៤ រៀបចំ និងអនុវត្តវគ្គបណ្តុះបណ្តាលពីចម្ងាយ ១២+៤	២០២១-២០២៣
១.៤.១ ជ្រើសរើសសាលាគរុកោសល្យភូមិភាគនិងគ្រូឧទ្ទេសសាលាគរុកោសល្យដែលមានសមត្ថភាព	២០២១
១.៤.២ អភិវឌ្ឍវគ្គសិក្សាពីចម្ងាយ	២០២២
១.៤.៣ ផ្តល់ការបណ្តុះបណ្តាលដល់គ្រូឧទ្ទេសដែលទទួលបន្ទុកការបណ្តុះបណ្តាលពីចម្ងាយ	២០២២
១.៤.៤ ចាប់ផ្តើមវគ្គបណ្តុះបណ្តាលពីចម្ងាយ	២០២៣-
២ បង្កើនចំនួនវិទ្យាស្ថានគរុកោសល្យ	
២.១ កំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់វិទ្យាស្ថានគរុកោសល្យបន្ទាប់ និងជ្រើសរើសសាលាគរុកោសល្យដែលមានសក្តានុពល	២០២២
២.២ ពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលរបស់សាលាគរុកោសល្យដើម្បីឱ្យស្របទៅនឹងស្តង់ដាកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានគរុកោសល្យ	២០២៣
២.៣ រៀបចំសាលាគរុកោសល្យខាងលើឱ្យក្លាយជាវិទ្យាស្ថានគរុកោសល្យ	២០២៣-២០២៤
២.៣.១ បង្កើតវិទ្យាស្ថានគរុកោសល្យថ្មីផ្លូវការដោយអនុក្រឹត្យ	២០២៣
២.៣.២ ជ្រើសរើស តែងតាំង និងបណ្តុះបណ្តាលគណៈគ្រប់គ្រងនៃវិទ្យាស្ថានគរុកោសល្យថ្មី	២០២៣-២០២៤
២.៣.៣ ជ្រើសរើស និងបណ្តុះបណ្តាលបុគ្គលិកបង្រៀននៃវិទ្យាស្ថានគរុកោសល្យថ្មី	២០២៤-២០២៥
២.៣.៤ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងរៀបចំសម្ភារៈសម្រាប់វិទ្យាស្ថានគរុកោសល្យថ្មី	២០២៤-២០២៥
២.៤ ចាប់ផ្តើមបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត ១២+៤ នៅវិទ្យាស្ថានគរុកោសល្យថ្មី	២០២៥-

២.៤.៣.២ យុទ្ធសាស្ត្រទី២៖ ការបណ្តុះបណ្តាលបរិញ្ញាបត្រ+១ ដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់

បច្ចុប្បន្ននេះ កម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រ+១ ដែលអ្នកមានបរិញ្ញាបត្រលើជំនាញពាក់ព័ន្ធនឹងមុខវិជ្ជាបង្រៀននៅតាមសាលារៀន ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេល១ឆ្នាំ ផ្នែកគរុកោសល្យ និងការបង្រៀន ត្រូវបានធ្វើឡើងនៅតែវិទ្យាស្ថានជាតិអប់រំតែមួយគត់ ក្នុងការផលិតគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ។ យុទ្ធសាស្ត្រទី២ ស្នើឱ្យផ្តល់កម្មវិធីកម្រិតបរិញ្ញាបត្រ+១ ជាការបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន ដូចដែលមានចែងនៅក្នុងគោលនយោបាយស្តីពីគ្រូបង្រៀនផែនការសកម្មភាពក្នុងឆ្នាំ២០១៥។ ការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ+១ គួររៀបចំឡើងដោយការកាត់បន្ថយ និងការរៀបចំឡើងវិញកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានគរុកោសល្យដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការសិក្សាពីការអប់រំ ការសិក្សាពីកម្មវិធីសិក្សា ការស្រាវជ្រាវអប់រំ រួមទាំងរបៀបសរសេរជាភាសាអង់គ្លេស និងកម្មសិក្សាគរុកោសល្យ។ គ្រឹះស្ថានដែលមានសក្តានុពលក្នុងការបណ្តុះបណ្តាលបរិញ្ញាបត្រ+១ មានវិទ្យាស្ថានគរុកោសល្យ និងវិទ្យាស្ថានជាតិអប់រំ ដែលមានគ្រូឧទ្ទេសជំនាញលើវិធីសាស្ត្របង្រៀនតាមមុខវិជ្ជា។ ទោះបីជាយ៉ាងណា វាចាំបាច់ក្នុងការស្ទង់មតិបឋមពីកម្រិតប្រជាប្រិយភាពដែលទទួលបានក្នុងចំណោមនិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ហើយអ្នកដែលនឹងជ្រើសរើសការបណ្តុះបណ្តាលបរិញ្ញាបត្រ+១សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានជាជាងការបណ្តុះបណ្តាលបរិញ្ញាបត្រ+១នៅវិទ្យាស្ថានជាតិអប់រំ។ ឧទាហរណ៍ ប្រសិនបើលទ្ធផលនៃការស្ទង់មតិបង្ហាញថា និស្សិតមួយចំនួនដែលបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ស្វែងរកការងារនៅតាមខេត្តដែលជាស្រុកកំណើតរបស់ពួកគេ នោះកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រ+១អាចដាក់ឱ្យសាកល្បងជាមួយនិស្សិតមួយចំនួនតូចនៅតាមខេត្តមួយចំនួន។ ដោយសារទីផ្សារការងារ និង/ឬកម្រិតប្រាក់បៀវត្ស (កាំប្រាក់) ជាកត្តាដែលអាចកំណត់ថាបេក្ខជនត្រូវរើសយកបរិញ្ញាបត្រ+១សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន ឬបរិញ្ញាបត្រ+១នៅវិទ្យាស្ថានជាតិអប់រំ ដូច្នេះត្រូវមានយុទ្ធសាស្ត្រដែលធ្វើឱ្យការបណ្តុះបណ្តាលបរិញ្ញាបត្រ+១ សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានមានភាពទាក់ទាញដូចជា យុទ្ធសាស្ត្រទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ការលើកទឹកចិត្ត និងឱកាសនៃការអភិវឌ្ឍវិជ្ជាជីវៈ សម្រាប់បេក្ខជនដែលជ្រើសរើសជម្រើសនេះ។

គុណសម្បត្តិនៃការបណ្តុះបណ្តាលបរិញ្ញាបត្រ+១ គឺជួយផ្គត់ផ្គង់គ្រូបង្រៀនបានឆាប់រហ័សនៅតាមសាលារៀន ដែលរងគ្រោះពីការខ្វះគ្រូបង្រៀនច្រើន។ ដូច្នេះ ជម្រើសមួយនៃគោលនយោបាយ គឺការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានដែលបានបញ្ចប់ការបណ្តុះបណ្តាលបរិញ្ញាបត្រ+១ ទៅបំពេញកន្លែងទំនេរនៅតាមអនុវិទ្យាល័យនៅតំបន់ដាច់ស្រយាល ដោយធានាថាគ្រូបង្រៀនចេញថ្មីទាំងនេះ នឹងអាចផ្លាស់ប្តូរទៅសាលារៀននៅទីប្រជុំជនប្រសិនបើពួកគេបង្ហាញនូវការបំពេញការងារបានល្អក្នុងស្ថានភាពលំបាកបែបនេះ។ ភស្តុតាងជាច្រើនបានបង្ហាញថា គ្រូបង្រៀនដែលទើបទទួលការបណ្តុះបណ្តាលថ្មីៗអាចធ្វើការបានល្អនៅសាលារៀនតំបន់ដាច់ស្រយាល ប្រសិនបើពួកគេទទួលបានការគាំទ្រយ៉ាងទូលំទូលាយនិងមានគុណភាពពីសហការីសហការនីដែលមានបទពិសោធជាងក្នុងអំឡុងពេលនេះ។ ដូច្នេះគួរតែមានការបញ្ចូលកម្មវិធីកម្មសិក្សា/កម្មវិធីណែនាំ ឬកម្មវិធីប្រឹក្សាគរុកោសល្យតាមសាលារៀនសម្រាប់រយៈពេលពីរឬបីឆ្នាំដំបូងនៃការបង្រៀន ដើម្បីធានាថាគ្រូបង្រៀនចេញថ្មីទទួលបាននូវការគាំទ្រនិងត្រួតពិនិត្យចាំបាច់ដែលអាចឱ្យពួកគេអភិវឌ្ឍទៅជាគ្រូបង្រៀនដែលមានសមត្ថភាពនិងមានការប្តេជ្ញាចិត្តក្នុងការបំពេញការងារ។

សកម្មភាពចម្បងៗទាក់ទងនឹងយុទ្ធសាស្ត្រទី២ ត្រូវបានស្នើឡើងដូចមានបង្ហាញនៅតារាងខាងក្រោម៖

តារាង២.១៦ សកម្មភាពចម្បងៗសម្រាប់យុទ្ធសាស្ត្រទី២

សកម្មភាពចម្បង	ពេលវេលា
១ ធ្វើការស្ទង់មតិខ្នាតតូចសម្រាប់ការវិភាគតម្រូវការ	
១.១ រៀបចំនិងធ្វើការស្ទង់មតិ និងវិភាគតម្រូវការនៃបរិញ្ញាបត្រ+១ សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន	២០២១
១.២ ជ្រើសរើសខេត្តគោលដៅសម្រាប់ការបណ្តុះបណ្តាល បរិញ្ញាបត្រ+១សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន	២០២១
២ អនុវត្តការបណ្តុះបណ្តាល បរិញ្ញាបត្រ+១ សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន	
២.១ ជ្រើសរើសគ្រឹះស្ថានបណ្តុះបណ្តាល បរិញ្ញាបត្រ+១ (វិទ្យាស្ថានជាតិអប់រំឬវិទ្យាស្ថានគរុកោសល្យ) និងកំណត់កូតាសម្រាប់ការសាកល្បង បរិញ្ញាបត្រ+១	២០២១
២.២ អភិវឌ្ឍកម្មវិធីបរិញ្ញាបត្រ+១ ឱ្យស្របជាមួយស្តង់ដាកម្មវិធីបណ្តុះបណ្តាលវិទ្យាស្ថានគរុកោសល្យ	២០២២
២.៣ អនុវត្តការបណ្តុះបណ្តាល បរិញ្ញាបត្រ+១ លើមូលដ្ឋានសាកល្បង	២០២២-

២.៤.៣.៣ យុទ្ធសាស្ត្រទី ៣៖ បង្កើតយន្តការក្នុងការដំឡើងគុណវុឌ្ឍិតាមរយៈកម្មវិធីបណ្តុះបណ្តាលរយៈពេលវែង

មធ្យោបាយមួយទៀតសម្រាប់បង្កើនចំនួនគ្រូបង្រៀនមានបរិញ្ញាបត្រដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺអនុវត្តកម្មវិធីវិក្រឹតការមួយចំនួនដើម្បីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន។ មានកម្មវិធីវិក្រឹតការ/អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលវែងមួយចំនួនដែលបានផ្តល់ឱ្យគ្រូបង្រៀនដូចជា កម្មវិធីលើកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (TUP) សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ កម្មវិធីពន្លឿនសម្រាប់គ្រូមធ្យមសិក្សាទុតិយភូមិនៅវិទ្យាស្ថានជាតិអប់រំ និងការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានសម្រាប់គ្រូបង្រៀនបឋមសិក្សានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។ លក្ខណៈនៃកម្មវិធីទាំងនេះ ត្រូវបានសង្ខេបនៅតារាង ២.១៧ ខាងក្រោម៖

តារាង២.១៧ កម្មវិធីលើកកម្ពស់គុណវុឌ្ឍិដែលមានស្រាប់សម្រាប់គ្រូបង្រៀនបឋមសិក្សានិងគ្រូបង្រៀនកម្រិតមូលដ្ឋាន

ឈ្មោះ	គោលដៅ	គ្រឹះស្ថានអនុវត្ត	ថវិកា	ការដំឡើងកម្រិតបៀវត្ស	ការដំឡើងគុណវុឌ្ឍិ	ក្រេឌីត/រយៈពេល
កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន	គ្រូបង្រៀនកម្រិតមូលដ្ឋានប្រមាណ ២,០០០នាក់នៅតាមសាលាគោលដៅ	សាកលវិទ្យាល័យភូមិន្ទភ្នំពេញ	គម្រោងធនាគារពិភពលោក	គ្មាន	ពី១២+២ ទៅ បរិញ្ញាបត្រ	៦០ក្រេឌីតក្នុងរយៈពេល ២ឆ្នាំ

កម្មវិធីពន្លឿន	គ្រូបង្រៀនកម្រិតមូលដ្ឋានប្រមាណ ៣,០០០នាក់ បង្រៀននៅវិទ្យាល័យ	វិទ្យាស្ថានជាតិអប់រំ	ថវិកាកម្មវិធី(PB)	ពីក្របខណ្ឌ ខ ទៅ ក	ពី១២+២ ទៅ បរិញ្ញាបត្រ	៦០ក្រេឌីត ក្នុងរយៈពេល ១ឆ្នាំ
បណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន	គ្រូបឋមសិក្សា	មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ	ថវិកាកម្មវិធី(PB)	ពីក្របខណ្ឌ គ ទៅ ខ	គ្មាន	រយៈពេល១ខែកន្លះ ចំនួន ២ដង

យុទ្ធសាស្ត្រនេះរួមមានគំរូវគ្គវិក្រឹតការ/ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមួយចំនួនដូចជា៖ ការអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិចំនួន ៦០ក្រេឌីតដែលប្រើប្រាស់ថវិកាដៃគូអភិវឌ្ឍន៍ ឬថវិកាជំនួយពីរដ្ឋ ដូចជាកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (TUP) ខាងលើ សម្រាប់រយៈពេលកំណត់មួយ [កម្មវិធីមានកាលកំណត់] និង/ឬ ផ្តល់ការដំឡើងគុណវុឌ្ឍិចំនួន ៦០ក្រេឌីតដែលបើកទូលាយដល់គ្រូបង្រៀន១២+២ [កម្មវិធីគ្មានកាលកំណត់]។ សម្រាប់កម្មវិធីមានកាលកំណត់ ក្រសួងអប់រំ យុវជន និងកីឡាគួរកំណត់ចំនួនគ្រូបង្រៀនចូលរួម (ព្រោះវាមានតម្លៃថ្លៃ) និងផ្តល់អាទិភាពដល់គ្រូបង្រៀននៅតំបន់ដាច់ស្រយាលដែលនឹងជំរុញឱ្យមានការពង្រាយគ្រូបង្រៀនឡើងវិញទៅតាមតំបន់ទាំងនេះប្រសិនបើមានលក្ខខណ្ឌការងារ និងឱកាសសម្រាប់ការរីកចម្រើនអាជីពត្រឹមត្រូវ។ សម្រាប់កម្មវិធីគ្មានកាលកំណត់ គួរតែអនុញ្ញាតឱ្យគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាន៦០ក្រេឌីតនៅក្នុងរយៈពេលវែង (ឧទាហរណ៍ ១០ឆ្នាំ) ឬដោយគ្មានកំណត់ពេលវេលា ប៉ុន្តែត្រូវអនុវត្តជាកម្មវិធី "បង់ថ្លៃ" ដែលជាគោលការណ៍ដើម្បីលើកកម្ពស់ឯករាជ្យភាពផ្នែកហិរញ្ញវត្ថុនៃវិទ្យាស្ថានគរុកោសល្យ ខណៈដែលក្រសួងអប់រំ យុវជន និងកីឡាគួរតែចំណាយថវិកាលើការចាត់វិធានការពិសេសសម្រាប់គ្រូបង្រៀននៅតំបន់ដាច់ស្រយាលឬនៅតាមសាលារៀនជួបការលំបាក(ឧទាហរណ៍ ផ្តល់ប័ណ្ណបញ្ចុះតម្លៃ ទទួលបានការបញ្ចុះតម្លៃ...)។ កម្មវិធីទាំងពីរនេះនឹងត្រូវបានអនុវត្តដោយការបញ្ចូលគ្នារវាងការរៀនផ្ទាល់ និងការប្រឹក្សាដោយការរៀនពីចម្ងាយ។ ខណៈដែលវិទ្យាស្ថានគរុកោសល្យ វិទ្យាស្ថានជាតិអប់រំ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាបេក្ខភាពគ្រឹះស្ថានអនុវត្តន៍ សាលាគរុកោសល្យនិងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគអាចដើរតួនាទីជាអ្នកបំពេញបន្ថែមក្នុងការអនុវត្តម៉ូឌុលមួយចំនួន នៅក្នុងកម្មវិធីគ្មានកាលកំណត់។ បន្ថែមលើនេះ ពេលវេលា និងកម្លាំងពលកម្មក្នុងការអភិវឌ្ឍផ្នែកជាកាតព្វកិច្ចនៃកម្មវិធីរយៈពេលវែងអាចត្រូវបានកាត់បន្ថយ ដោយការប្រើប្រាស់កម្មវិធីសិក្សាលម្អិត និងសម្ភារៈដែលមានស្រាប់របស់វិទ្យាស្ថានគរុកោសល្យ។ លើសពីនេះទៀត គ្រូបង្រៀនសិក្សាកម្មវិធីនេះ អាចរាប់ចំនួនក្រេឌីតទទួលបានពីសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ផ្តល់ដោយគ្រឹះស្ថានផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានការទទួលស្គាល់ នៅក្នុងរង្វង់ដែលមានចែងក្នុងដំណើរការទទួលស្គាល់ និងក្នុងតារាង ២.១។

សកម្មភាពចម្បងៗទាក់ទងនឹងយុទ្ធសាស្ត្រទី៣ ត្រូវបានស្នើឡើងដូចមានបង្ហាញនៅតារាងខាងក្រោម៖

តារាង២.១៨ សកម្មភាពចម្បងៗសម្រាប់យុទ្ធសាស្ត្រទី៣

សកម្មភាពចម្បង	ពេលវេលា
១ អភិវឌ្ឍកម្មវិធីរយៈពេលវែង	
១.១ រៀបចំកញ្ចប់ម៉ូឌុលសម្រាប់កម្មវិធី៦០ក្រេឌីតដោយយោងតាមប្រកាសលេខ ១៨៧០ និងការប្រើប្រាស់ឯកសារវគ្គសិក្សារបស់វិទ្យាស្ថានគរុកោសល្យ	២០២១
១.២ អភិវឌ្ឍផែនការលម្អិតសម្រាប់កម្មវិធីមានកាលកំណត់ និងកម្មវិធីគ្មានកាលកំណត់ ដែលមានពត៌មានដូចជា៖ ក្រុមគោលដៅ ចំនួនសិក្ខាកាម គ្រឹះស្ថានអនុវត្តន៍ របៀបបង្រៀន លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសនិងនីតិវិធី ពេលវេលាអនុវត្តន៍ ។ល។	២០២១
១.៣ រៀបចំផែនការថវិកា និងកៀរគរការគាំទ្រហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍	២០២១-២០២២
១.៤ រៀបចំគ្រូឧទ្ទេស និងសម្ភារៈបណ្តុះបណ្តាល	២០២២
២ អនុវត្តកម្មវិធីមានកាលកំណត់	
២.១ ជ្រើសរើសអ្នកចូលរួមក្នុងការបណ្តុះបណ្តាល	២០២២
២.២ ចាប់ផ្តើមអនុវត្តកម្មវិធីរយៈពេលខ្លី	២០២២-
៣ ចាប់ផ្តើមអនុវត្តកម្មវិធីគ្មានកាលកំណត់[8]	២០២២-

២.៤.៣.៤ យុទ្ធសាស្ត្រទី ៤៖ ជំរុញគ្រូបង្រៀន ១២+២ ដែលមានសញ្ញាបត្របរិញ្ញាបត្រ ចូលរួមក្នុងការដំឡើងគុណវុឌ្ឍិតាមរយៈកម្មវិធីបណ្តុះបណ្តាលរយៈខ្លី

ក្រុមគោលដៅសម្រាប់កម្មវិធីរយៈពេលខ្លីគឺគ្រូបង្រៀន១២+២ ដែលមានបរិញ្ញាបត្រលើមុខវិជ្ជាឯកទេស ដែលពួកគេបង្រៀននៅសាលារៀន។ ពួកគេភាគច្រើនជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ព្រោះមានតែសាកលវិទ្យាល័យក្នុងស្រុកមួយចំនួនតូចប៉ុណ្ណោះដែលផ្តល់បរិញ្ញាបត្រលើជំនាញការអប់រំបឋមសិក្សា។ ដូចបានឃើញនៅក្នុងតារាង ២.១៩ ចំនួន និងសមមាត្រគ្រូបង្រៀនដែលមានបរិញ្ញាបត្របាននិងកំពុងមានការកើនឡើងក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ ទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា[9]។

[8] ក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលទទួលបានពីការបញ្ចប់សកម្មភាព CPD ដោយជោគជ័យ ទទួលស្គាល់ដោយការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៃក្រសួង អ.យ.ក ដូចជាកញ្ចប់អំណាននិងគណិតវិទ្យាថ្នាក់ដំបូង ការគ្រប់គ្រងថែរក្សាសម្រាប់នាយកសាលាគរុកោសល្យ ។ល។ នឹងត្រូវរាប់ឡើងវិញ។

[9] ក្នុងតារាងនៃកម្រិតមធ្យមសិក្សា ចំនួនអ្នកបញ្ចប់ការសិក្សាត្រឹមបឋមសិក្សានិងអនុវិទ្យាល័យត្រូវធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែចំនួនអ្នកបញ្ចប់ការសិក្សាត្រឹមបឋមសិក្សាបានកើនឡើងបើទោះបីជាថ្មីៗនេះមិនមានការជ្រើសរើសអ្នកបញ្ចប់ការសិក្សាត្រឹមបឋមសិក្សាជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលទាមទារឱ្យមានការស៊ើបអង្កេតបន្ថែម។

តារាង២.១៩ គុណវុឌ្ឍិអប់រំគ្រូបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋាន

	កម្រិតបឋមសិក្សា						កម្រិតមធ្យមសិក្សា(អនុវិទ្យាល័យ+វិទ្យាល័យ)					
	បឋមសិក្សា	អនុវិទ្យាល័យ	វិទ្យាល័យ	បរិញ្ញាបត្រ	បរិញ្ញា. ជាន់ខ្ពស់	បណ្ឌិត	បឋមសិក្សា	អនុវិទ្យាល័យ	វិទ្យាល័យ	បរិញ្ញាបត្រ	បរិញ្ញា. ជាន់ខ្ពស់	បណ្ឌិត
២០១៩-២០២០	១,៤២៨	១០,០៦២	២៦,៩០៤	៦,២៥៦	២៣០	៤	៨១៦	៥,៧១១	១៦,៤៦៥	១៨,៤២០	១,៣០២	១៨
២០១៨-២០១៩	៩៥៨	១០,៥៦៩	២៨,៩១៦	៥,២៧១	១៧៩	០	៥១២	៥,០១៦	១៨,៧៩៩	១៦,៩៨៥	១,១៩១	១០
២០១៧-២០១៨	១,០៧១	១១,៤៩០	២៨,៦៥៥	៤,៤៨០	១២៩	១	៥៩៤	៥,២៩០	១៨,៨៥៣	១៥,៤២៣	១,០០៤	៤
២០១៦-២០១៧	១,១០៤	១២,៥២១	២៨,៧០១	៣,៥៨៥	៩៥	៣	៤៩៤	៥,០៨៤	២០,៣០៥	១៤,២៣១	៩៩៥	១២
២០១៥-២០១៦	១,១៧៥	១៣,៤៤៥	២៧,១៥៩	៣,០២៧	៧៨	០	២៩១	៥,៨២១	២០,៦៨៤	១៣,២៣៨	៨៨៩	១

ប្រភព៖ ក្រសួងអប់រំ សូចនាករនិងស្ថិតិអប់រំ ២០១៥-១៦ ២០១៦-១៧ ២០១៧-១៨ ២០១៨-១៩ ២០១៩-២០

ម្យ៉ាងវិញទៀត ទោះបីជាយ៉ាងណាក៏ដោយ គ្រូបង្រៀននៅក្នុងក្រុមគោលដៅនេះ ច្រើនតែដាក់ពាក្យប្រឡងចូលរៀនបរិញ្ញាបត្រ+១ នៅវិទ្យាស្ថានជាតិអប់រំដើម្បីក្លាយជាគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ ជាមួយនឹងការដំឡើងទៅក្របខណ្ឌ "ក" ដែលជាគុណវិបត្តិមួយនៃប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនព្រោះវាបណ្តាលឱ្យបាត់បង់ធនធានមនុស្សនៅកម្រិតអប់រំមូលដ្ឋាន។ ដូច្នេះសកម្មភាពក្នុងយុទ្ធសាស្ត្រទី៤គួរតែបំពេញបន្ថែមដោយការផ្តួចផ្តើមរបស់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីបង្កើតយន្តការលើកទឹកចិត្តគ្រូបង្រៀនឱ្យស្ថិតនៅកម្រិតអប់រំមូលដ្ឋាន ដូចជាការអនុវត្តគន្លងអាជីពគ្រូបង្រៀន និងពិនិត្យឡើងវិញលើកាំប្រាក់ ដើម្បីឆ្លុះបញ្ចាំងពីគុណវុឌ្ឍិអប់រំរបស់គ្រូបង្រៀន ផ្តល់ការគាំទ្រខ្លាំងជាងនេះសម្រាប់សាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិដើម្បីពង្រឹងបរិស្ថានបង្រៀន និងរៀន។ យន្តការនេះនឹងធ្វើឱ្យមានការលើកទឹកចិត្តទាំងខ្សែបណ្តោយ និងទទឹងនៅក្នុងការអប់រំបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ និងនាំឱ្យមានការទាក់ទាញ និងរក្សាគ្រូបង្រៀនដែលមានការលើកទឹកចិត្ត និងមានគុណសម្បត្តិសមស្របនៅក្នុងកម្រិតអប់រំទាំងពីរ។

កម្មវិធីរយៈពេលខ្លី ៣០ក្រេឌីត ត្រូវបានរៀបចំឡើងផ្អែកលើប្រការ ១៤ និង១៧ នៃប្រកាសលេខ ១៨៧០។ ដោយសារយុទ្ធសាស្ត្រទី៤មានគោលដៅពន្លឿនដំណើរការដំឡើងគុណវុឌ្ឍិ កម្មវិធីគួរតែត្រូវបានរៀបចំក្នុងរបៀបដែលអ្នកចូលរួមទាំងអស់អាចបញ្ចប់វគ្គបណ្តុះបណ្តាលក្នុងរយៈពេល១ឆ្នាំ ដោយមានការរួមបញ្ចូលគ្នានៃការរៀនផ្ទាល់ និងការរៀនពីចម្ងាយ។ យុទ្ធសាស្ត្រទី៤ រំពឹងផងដែរថាវិទ្យាស្ថានគរុកោសល្យ វិទ្យាស្ថានជាតិអប់រំ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាបេក្ខភាពគ្រឹះស្ថានអនុវត្តន៍ ហើយគ្រឹះស្ថាននីមួយៗអាចប្តូរមុខវិជ្ជាជម្រើសចំនួន ១២ក្រេឌីត ដើម្បីឱ្យមានកម្មវិធីខុសប្លែកពីគ្រឹះស្ថានដទៃទៀត។ គ្រូបង្រៀនដែលចូលរួមនឹងត្រូវជ្រើសរើសមកពីគ្រប់ខេត្តទាំងអស់ជាពិសេសនៅតាមសាលារៀនជនបទ/ដាច់ស្រយាល។ ការអភិវឌ្ឍផ្នែកដែលជាកាតព្វកិច្ចចំនួន ១៨ក្រេឌីតនៃកម្មវិធីរយៈពេលខ្លី អាចត្រូវប្រើពេលវេលា និងកម្លាំងតិចជាងមុនដោយការប្រើប្រាស់កម្មវិធីសិក្សាលម្អិត និងសម្ភារៈដែលមានស្រាប់របស់វិទ្យាស្ថានគរុកោសល្យ។ លើសពីនេះទៀត

គ្រូបង្រៀនសិក្សាកម្មវិធីនេះ អាចរាប់ចំនួនក្រេឌីទទួលបានពីសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផ្ដល់ដោយគ្រឹះស្ថានផ្ដល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានការទទួលស្គាល់ នៅក្នុងរង្វង់ដែលមានថែងក្នុងដំណើរការទទួលស្គាល់ និងក្នុងតារាង ២.១។

សកម្មភាពចម្បងៗទាក់ទងនឹងយុទ្ធសាស្ត្រទី៤ ត្រូវបានស្នើឡើងដូចមានបង្ហាញនៅតារាងខាងក្រោម៖

តារាង២.២០ សកម្មភាពចម្បងៗសម្រាប់យុទ្ធសាស្ត្រទី៤

សកម្មភាពចម្បង	កាលវេលា
១ អភិវឌ្ឍកម្មវិធីរយៈពេលខ្លី	
១.១ រៀបចំកញ្ចប់ម៉ូឌុលសម្រាប់កម្មវិធី៣០ក្រេឌីតដោយយោងតាមប្រកាសលេខ ១៨៧០ និងការប្រើប្រាស់ឯកសារវគ្គសិក្សារបស់វិទ្យាស្ថានគរុកោសល្យ	២០២១
១.២ អភិវឌ្ឍផែនការលម្អិតដែលមានព័ត៌មានដូចជា៖ ក្រុមគោលដៅ ចំនួនសិក្ខាកាម គ្រឹះស្ថានអនុវត្តន៍ របៀបបង្រៀន លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសនិងនីតិវិធី ពេលវេលាអនុវត្តន៍ ។ល។	២០២១
១.៣ រៀបចំផែនការថវិកា និងកៀរគរការគាំទ្រហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍	២០២១-២០២២
១.៤ រៀបចំគ្រូឧទ្ទេស និងសម្ភារៈបណ្ដុះបណ្ដាល	២០២២
២ អនុវត្តកម្មវិធីរយៈពេលខ្លី	
២.១ ជ្រើសរើសអ្នកចូលរួមការបណ្ដុះបណ្ដាល	២០២២
២.២ ចាប់ផ្ដើមអនុវត្តកម្មវិធីរយៈពេលខ្លី	២០២២-

២.៤.៤ ការគិតពីចំនួនគ្រូបង្រៀន និងពេលវេលា

តួលេខគោលដៅនៅក្នុងផែនការមធ្យមស្ដីពីការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ត្រូវបន្សុីគ្នាជាមួយគោលដៅជាតិ[10]។

១. ចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានសរុប ដើម្បីដំឡើងគុណវុឌ្ឍិទៅបរិញ្ញាបត្រ (ជំនាញបង្រៀន) (រហូតដល់ឆ្នាំ ២០២៣)៖ ចំនួន ៤,៥០០ នាក់

ដោយពិចារណាលើកំណើនបន្តិចបន្តួចនៃចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានក្នុងរយៈពេលពីរបីឆ្នាំខាងមុខ ដោយសារការរាតត្បាតនៃជំងឺកូវីដ១៩ ផែនការមធ្យមនេះកំណត់គោលដៅសម្រាប់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនចំនួន ៤,៥០០នាក់ ដែលស្មើនឹង ១៥.៨ភាគរយនៃចំនួនតួលេខគោល ២៨,៤២២នាក់[11] នៅឆ្នាំសិក្សា ២០២៨-២០១៩ និងស្នើពិនិត្យប្រចាំឆ្នាំនូវគោលដៅខាងលើដោយយោងលើកំណើនជាក់ស្ដែងនៃគ្រូបង្រៀន

[10] តួលេខគោលដៅនៃការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនក្នុងផែនការមធ្យមរួមមានគ្រូបង្រៀនដែលទទួលការបណ្ដុះបណ្ដាលកម្មវិធី ១២+៤ ដូចនឹងសូចនាករផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣គឺ "ភាគរយនៃគ្រូបង្រៀនកម្រិតមូលដ្ឋាន/បឋមសិក្សាដែលបញ្ចប់បរិញ្ញាបត្រតាមរយៈវគ្គបណ្ដុះបណ្ដាលគ្រូបង្រៀន" (ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣)

[11] ប្រភពនៃតួលេខគោល ២៨,៤២២ គឺ "របាយការណ៍វិភាគអនុវិស័យបណ្ដុះបណ្ដាលគ្រូបង្រៀន (E-TEC ឆ្នាំ២០១៩)" ដែលទំព័រទី៤៥-៤៧ ពន្យល់ពីនីតិវិធីគណនា។

កម្រិតមូលដ្ឋាន។ តារាង ២.២០ បង្ហាញនូវចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានគោលដៅដែលត្រូវដំឡើងគុណវុឌ្ឍិស្មើនឹងកម្រិតបរិញ្ញាបត្រ ដោយកម្មវិធីណាមួយ និងនៅពេលណាមួយ។ តារាង ២.២២ បង្ហាញនូវទស្សនាទានសង្ខេបនៃកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គោលបំណងបែបនេះ។

តារាង២.២១ ចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានដែលត្រូវដំឡើងគុណវុឌ្ឍិតាមគំរូនានា(ត្រឹមឆ្នាំ២០២៣)

គំរូ	២០២១	២០២២	២០២៣	សរុប
ការបណ្ដុះបណ្ដាល				
១២+៤	-	២០០ (មិនប្រែប្រួល)	២០០ (មិនប្រែប្រួល)	៤០០ (មិនប្រែប្រួល)
បរិញ្ញាបត្រ+១	-	-	-	-
វិក្រឹតការ				
ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលខ្លី	-	-	៦០០	៦០០
ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលវែង	-	-	១,៥០០	១,៥០០
កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន(ធនាគារពិភពលោក/សកលវិទ្យាល័យភូមិន្ទភ្នំពេញ)	២,000 (មិនប្រែប្រួល)	-	១,៥០០ (មិនប្រែប្រួល	៣,៥០០ (មិនប្រែប្រួល)
សរុប				**៤,៥០០**

តារាង ២.២២ ការសង្ខេបខ្លីស្តីពីកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានដើម្បីដំឡើងគុណវុឌ្ឍិស្មើនឹងកម្រិតបរិញ្ញាបត្រ

	ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលខ្លី	ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រយៈពេលវែង
ក្រុមគោលដៅ	គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ ដែលមានបរិញ្ញាបត្រពាក់ព័ន្ធនឹងមុខវិជ្ជាពួកគេបង្រៀន	គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ ដែលមិនមានបរិញ្ញាបត្រ / មានបរិញ្ញាបត្រមិនពាក់ព័ន្ធនឹងមុខវិជ្ជាពួកគេបង្រៀន
ចំនួនគោលដៅ	៦០០	០
គ្រឹះស្ថានអនុវត្តន៍	វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ	វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
រយៈពេលនៃវគ្គសិក្សា	១ឆ្នាំ(កម្មវិធីនៅសាលានឹងរំពឹងថានឹងធ្វើចាប់ពីខែសីហា ដល់ខែ កញ្ញា ក្នុងកំឡុងពេលវិស្សមកាល)	២ឆ្នាំ (កម្មវិធីនៅសាលានឹងរំពឹងថានិងធ្វើចាប់ពីខែសីហា ដល់ខែ កញ្ញា ក្នុងកំឡុងពេលវិស្សមកាល)
ចំនួនគរុនិស្សិតក្នុងមួយថ្នាក់	គរុនិស្សិតចំនួន២៥នាក់ ក្នុងមួយថ្នាក់ វិទ្យាស្ថានជាតិអប់រំ៖ ២៥*៦ថ្នាក់/ឆ្នាំ*២=៣០០ វិទ្យាស្ថានគរុកោសល្យ៖ ២៥*៦ ថ្នាក់/ឆ្នាំ*២=៣០០	គរុនិស្សិតចំនួន២៥នាក់ ក្នុងមួយថ្នាក់ វិទ្យាស្ថានជាតិអប់រំ៖ ២៥*០ថ្នាក់/ឆ្នាំ*១=០ វិទ្យាស្ថានគរុកោសល្យ/សាកលវិទ្យាល័យភូមិន្ទភ្នំពេញ៖ ២៥*០ថ្នាក់/ឆ្នាំ*១=០
វិធីបង្រៀន	ការបញ្ចូលគ្នានៃ(១) កម្មវិធីអនឡាយ ដោយប្រើប្រាស់សម្ភារៈវីដេអូដែលនឹងត្រូវផលិតដោយវិទ្យាស្ថានគរុកោសល្យ និង(២) កម្មវិធីរៀនផ្ទាល់ដែលផ្តោតលើខ្លឹមសារផ្អែកលើការអនុវត្ត	
លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសនិងនីតិវិធី	ត្រូវពិភាក្សា	ត្រូវពិភាក្សា
វេលានៃការអនុវត្ត	២០២២-២០២៣	២០២២-២០២៤
ចំនួនក្រេឌីត	៣០	៦០

២. ចំនួនគ្រូបឋមសិក្សាសរុប ដើម្បីដំឡើងគុណវុឌ្ឍិទៅបរិញ្ញាបត្រ (ជំនាញបង្រៀន) (រហូតដល់ឆ្នាំ ២០២៣)៖ ៣,២០០នាក់

ប្រហាក់ប្រហែលនឹងគ្រូបង្រៀនកម្រិតមូលដ្ឋាន ផែនការមធ្យមនេះកំណត់គោលដៅសម្រាប់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនបឋមសិក្សាចំនួន ៣២០០នាក់ ដែលស្មើនឹង៦.៩ភាគរយ នៃចំនួនតួលេខគោល

៤៦,៥៨៧នាក់[12] នៅឆ្នាំសិក្សា២០១៨-២០១៩ និងស្នើពិនិត្យប្រចាំឆ្នាំនូវគោលដៅខាងលើដោយយោងលើកំណើនជាក់ស្តែងនៃគ្រូបង្រៀនបឋមសិក្សា។ តារាង ២.២៣ បង្ហាញនូវចំនួនគ្រូបង្រៀនបឋមសិក្សាគោលដៅដែលត្រូវដំឡើងគុណវុឌ្ឍិស្មើនឹងកម្រិតបរិញ្ញាបត្រ ដោយកម្មវិធីណាមួយនិងនៅពេលណាមួយ។ តារាង ២.២៤ បង្ហាញនូវទស្សនាទានសង្ខេបនៃកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គោលបំណងបែបនេះ។

តារាង២.២៣ ចំនួនគ្រូបង្រៀនបឋមសិក្សាដែលត្រូវដំឡើងគុណវុឌ្ឍិតាមគំរូនានា (ត្រឹមឆ្នាំ២០២៣)

គំរូ	២០២១	២០២២	២០២៣	សរុប
ការបណ្តុះបណ្តាល				
១២+៤	-	៣០០ (មិនប្រែប្រួល)	៣០០ (មិនប្រែប្រួល)	៦០០ (មិនប្រែប្រួល)
បរិញ្ញាបត្រ+១	-	-	-	-
វិក្រឹតការ				
CPD រយៈពេលខ្លី	-	៨០០	៨០០	១,៦០០
CPD រយៈពេលវែង	-	-	១,០០០	១,០០០
សរុប				**៣,២០០**

តារាង២.២៤ ការសង្ខេបខ្លីស្តីពីកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀនបឋមសិក្សាដើម្បីដំឡើងគុណវុឌ្ឍិស្មើនឹងកម្រិតបរិញ្ញាបត្រ

	ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលខ្លី	ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេលវែង
ក្រុមគោលដៅ	គ្រូបង្រៀនបឋមសិក្សា១២+២ដែលមានបរិញ្ញាបត្រលើជំនាញពាក់ព័ន្ធការអប់រំ	គ្រូបង្រៀនបឋមសិក្សា១២+២ ដែលមិនមានបរិញ្ញាបត្រ/មានបរិញ្ញាបត្រលើជំនាញមិនពាក់ព័ន្ធការអប់រំ
ចំនួនគោលដៅ	១,៦០០	១,០០០
គ្រឹះស្ថានអនុវត្តន៍	វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ	វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
រយៈពេលនៃវគ្គសិក្សា	១ឆ្នាំ (កម្មវិធីនៅសាលានឹងរំពឹងថានឹងធ្វើចាប់ពីខែសីហា ដល់ខែកញ្ញា ក្នុងកំឡុងពេលវិស្សមកាល)	២ឆ្នាំ (កម្មវិធីនៅសាលានឹងរំពឹងថានិងធ្វើចាប់ពីខែសីហា ដល់ខែកញ្ញា ក្នុងកំឡុងពេលវិស្សមកាល)

[12] ប្រភពនៃតួលេខគោលគឺ "របាយការណ៍វិភាគអនុវិស័យបណ្តុះបណ្តាលគ្រូបង្រៀន (E-TEC ឆ្នាំ២០១៩)" ដែលទំព័រទី២៧-៣៩ ពន្យល់ពីនីតិវិធីគណនា។

ចំនួនគរុនិស្សិតក្នុងមួយថ្នាក់	គរុនិស្សិតចំនួន២៥នាក់ ក្នុងមួយថ្នាក់ - វិទ្យាស្ថានជាតិអប់រំ៖ ២៥*១០ថ្នាក់/ឆ្នាំ*២=៥០០ - វិទ្យាស្ថានគរុកោសល្យ៖ ២៥*១៤ថ្នាក់/ឆ្នាំ*២=៧០០ - សាកលវិទ្យាល័យភូមិន្ទភ្នំពេញ៖ ២៥*៨ថ្នាក់/ឆ្នាំ*២=៤០០	គរុនិស្សិតចំនួន២៥នាក់ ក្នុងមួយថ្នាក់ - វិទ្យាស្ថានជាតិអប់រំ៖ ២៥*១០ថ្នាក់/ឆ្នាំ*១=២៥០ - វិទ្យាស្ថានគរុកោសល្យ៖ ២៥*២០ថ្នាក់/ឆ្នាំ*១=៥០០ - សាកលវិទ្យាល័យភូមិន្ទភ្នំពេញ៖ ២៥*១០ថ្នាក់/ឆ្នាំ*១=២៥០
វិធីបង្រៀន	ការបញ្ចូលគ្នានៃ(១) កម្មវិធីអនឡាយ ដោយប្រើប្រាស់សម្ភារៈវីដេអូដែលនឹងត្រូវផលិតដោយវិទ្យាស្ថានគរុកោសល្យ និង(២) កម្មវិធីរៀនផ្ទាល់ដែលផ្តោតលើខ្លឹមសារផ្អែកលើការអនុវត្ត	
លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស និងនីតិវិធី	ត្រូវពិភាក្សា	នត្រូវពិភាក្សា
វេលានៃការអនុវត្ត	២០២២-២០២៣	២០២២-២០២៤
ចំនួនក្រេឌីត	៣០	៦០

២.៥ ថវិកាសម្រាប់ការអនុវត្ត

ដើម្បីអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិដែលលើកឡើងនៅផ្នែក ២.៤.៤ ក្រសួងអប់រំ យុវជន និងកីឡា នឹងទម្លាក់ថវិកាចាំបាច់។ ផែនការថវិកាព្រាង ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម។

តារាង២.២៥ ការប៉ាន់ស្មានថវិកាសម្រាប់កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន(កម្មវិធី CPD រយៈពេលវែង/ខ្លី) សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋានត្រឹមឆ្នាំ២០២៣

កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន (CPD រយៈពេលវែង)						
ឆ្នាំ	**សិក្ខាកាម**	**ថ្លៃសិក្សា/កម្មវិធី**	**ប្រាក់ឧបត្ថម្ភ/កម្មវិធី**	**សរុប**	**យថាភាព (៥%)**	**ចំណាយសរុបនៃកម្មវិធី**
២០២១	០					
២០២២	០	$ ១,១៥០.០០	$ ២,៩០០.០០	$ -	$ -	$ -
២០២៣	០	$ ១,១៥០.០០	$ ២,៩០០.០០	$ -	$ -	$ -
			សរុប	$ -	$ -	$ -
កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន (CPD រយៈពេលខ្លី)						
ឆ្នាំ	**សិក្ខាកាម**	**ថ្លៃសិក្សា/កម្មវិធី**	**ប្រាក់ឧបត្ថម្ភ/កម្មវិធី**	**សរុប**	**យថាភាព (៥%)**	**ចំណាយសរុបនៃកម្មវិធី**
២០២១	០					
២០២២	០	$ ៥៧៥.០០	$ ១,៤៥០.០០	$ -		
២០២៣	៦០០	$ ៥៧៥.០០	$ ១,៤៥០.០០	$១,២១៥,០០០.០០	$ ៦០,៧៥០.០០	$ ១,២៧៥,៧៥០.០០
			សរុប	**$១,២១៥,០០០.០០**	**$ ៦០,៧៥០.០០**	**$ ១,២៧៥,៧៥០.០០**
					ចំណាយសរុបនៃគម្រោងសម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន	**$ ១,២៧៥,៧៥០.០០**

តារាង ២.២៦ ការប៉ាន់ស្មានថវិកាសម្រាប់កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន(កម្មវិធី CPD រយៈពេលវែង/ខ្លី) សម្រាប់គ្រូបង្រៀនបឋមសិក្សាត្រឹមឆ្នាំ២០២៣

កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន (CPD រយៈពេលវែង)						
ឆ្នាំ	សិក្ខាកាម	ថ្លៃសិក្សា/កម្មវិធី	ប្រាក់ឧបត្ថម្ភ/កម្មវិធី	សរុប	យថាភាព (៥%)	ចំណាយសរុបនៃកម្មវិធី
២០២១	0					
២០២២	0	$ ១,១៥0.00	$ ២,៩00.00	$ -	$ -	$ -
២០២៣	១,000	$ ១,១៥0.00	$ ២,៩00.00	$៤,0៥0,000.00	$២0២,៥00.00	$ ៤,២៥២,៥00.00
			សរុប	$៤,0៥0,000.00	$២0២,៥00.00	$ ៤,២៥២,៥00.00
កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន (CPD រយៈពេលខ្លី)						
ឆ្នាំ	សិក្ខាកាម	ថ្លៃសិក្សា/កម្មវិធី	ប្រាក់ឧបត្ថម្ភ/កម្មវិធី	សរុប	យថាភាព (៥%)	ចំណាយសរុបនៃកម្មវិធី
២០២១	0					
២០២២	៨00	$ ៥៧៥.00	$ ១,៤៥0.00	$ ១,៦២0,000.00	$ ៨១,000.00	$ ១,៧0១,000.00
២០២៣	៨00	$ ៥៧៥.00	$ ១,៤៥0.00	$ ១,៦២0,000.00	$ ៨១,000.00	$ ១,៧0១,000.00
			សរុប	**$ ៣,២៤0,000.00**	**$ ១៦២,000.00**	**$ ៣,៤0២,000.00**
					ចំណាយសរុបនៃគម្រោងសម្រាប់គ្រូបង្រៀនបឋមសិក្សា	**$ ៧,៦៥៤,៥00.00**

ក្នុងករណីដែលពាក់ព័ន្ធនឹងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ប្រាក់ឧបត្ថម្ភនឹងត្រូវកែតម្រូវតាមពេលវេលាកំណត់ ហើយព័ត៌មានលម្អិតទាំងនេះនឹងត្រូវពិភាក្សានៅដំណាក់កាលក្រោយៗទៀត។

២.៦ បញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងអនាគត

ដើម្បីពន្លឿនដំណើរការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន មានបញ្ហាជាច្រើនត្រូវដោះស្រាយដូចជា៖

១) ការទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

២) កង្វះគ្រូឧទ្ទេសដែលមានសមត្ថភាព

៣) ការលើកទឹកចិត្តដល់គ្រូបង្រៀនដែលមានសមត្ថភាពរួមទាំងគ្រូបង្រៀនក្នុងប្រព័ន្ធ

៤) កង្វះយុទ្ធសាស្ត្ររយៈពេលវែងដែលកំណត់ផែនការច្បាស់លាស់សម្រាប់ផ្គត់ផ្គង់គ្រូបង្រៀនដែលមានសមត្ថភាពជាបន្តបន្ទាប់

៥) តម្រូវការយុទ្ធសាស្ត្ររួមដើម្បីទាក់ទាញបេក្ខជនដែលសមស្របចូលក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន និងរក្សាពួកគេនៅក្នុងវិជ្ជាជីវៈគ្រូបង្រៀន

បញ្ហាប្រឈមទី១ ដល់ទី៣ នឹងត្រូវដោះស្រាយក្នុងរយៈពេលខ្លី និងបញ្ហាប្រឈមទី៤និង៥ នឹងត្រូវដោះស្រាយក្នុងរយៈពេលមធ្យម និងវែង។

២.៦.១ បញ្ហាប្រឈមរយៈពេលខ្លី

២.៦.១.១ ការទទួលស្គាល់កម្មវិធីដំឡើងគុណវុឌ្ឍិ

ប្រកាសលេខ ១៨៧0 (ឆ្នាំ២០១៩) បានចែងថា៖

- គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនរួមមាន សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យនិងវិក្រឹតការខេត្ត មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ វិទ្យាស្ថានគរុកោសល្យ

និងវិទ្យាស្ថានជាតិអប់រំ (ប្រការ៤)

- ក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ការអនុញ្ញាតឱ្យអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន (ប្រការ៥)
- គ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលមានបរិញ្ញាបត្ររង ឬ១២+២ អាចទទួលបានចំនួនក្រេឌីតចាំបាច់សម្រាប់ការដំឡើងគុណវុឌ្ឍិនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនខាងលើ (ប្រការ៧)

នេះជាសំណើ ប៉ុន្តែមិនបានបញ្ជាក់ឱ្យច្បាស់ទេថា មានតែគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដែលអាចអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ហេតុផលនៃការសម្រេចចិត្តបែបនេះ អាចទំនងជាថាក្រសួងអប់រំ យុវជន និងកីឡាត្រូវការរក្សានូវគុណភាព និងស្តង់ដានៃការបណ្តុះបណ្តាលគ្រូបង្រៀន ដោយម៉ូឌុលដែលមានចំណងជើងដូចគ្នាត្រូវបានអនុវត្តនៅកម្រិតដូចគ្នាដោយមិនគិតពីគ្រឹះស្ថានដែលផ្តល់សេវា។

ការទទួលស្គាល់កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន គឺជាកិច្ចការមួយរបស់គណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀន(CTD) ដែលដឹកនាំដោយឯកឧត្តមសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ ប្រការ៥ នៃប្រកាសលេខ ៣១៤ (ឆ្នាំ២០១៧) បានចែងពីតួនាទីនិងភារកិច្ចរបស់គណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀន (CTD) និងបានចែងថាគណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀន(CTD) ជាអ្នកផ្តល់សុពលភាពដល់កម្មវិធីនានាពាក់ព័ន្ធនឹងការបណ្តុះបណ្តាល និងអភិវឌ្ឍគ្រូបង្រៀន។

ម្យ៉ាងវិញទៀត អ្វីដែលខ្វះចន្លោះក្នុងការពិភាក្សាពេលមុនអំពីការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនគឺអ្នកដែលនឹងទទួលខុសត្រូវក្នុងការធ្វើផែនការ និងគ្រប់គ្រងកម្មវិធី។ ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសហការជាមួយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការទទួលខុសត្រូវរៀបចំផែនការកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន ទទួលស្គាល់គុណភាពគ្រឹះស្ថានផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងកៀរគរធនធានហិរញ្ញវត្ថុនិងធនធានមនុស្សសម្រាប់អនុវត្តកម្មវិធីទាំងនេះ ដែលអាចរាប់បញ្ចូលកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនសម្រាប់គ្រូបង្រៀន១២+២ សម្របសម្រួលដំណើរការទទួលស្គាល់គុណភាពអប់រំតាមរយៈគណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀន។ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការទទួលខុសត្រូវក្នុងការរៀបចំផែនការ និងអនុវត្តការបណ្តុះបណ្តាលកម្មវិធីដែលមានតម្លៃស្មើនឹងកម្រិតបរិញ្ញាបត្ររួមមានបរិញ្ញាបត្រ+១ និង១២+៤។ ដោយសារប្រព័ន្ធទទួលក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានភាពស្របគ្នានឹងប្រព័ន្ធក្រេឌីតគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនរបស់កម្ពុជា គ្រប់សកម្មភាពបណ្តុះបណ្តាល និងវិក្រឹតការអាចមានអន្តរកម្មគ្នាជាលក្ខណៈរួមបញ្ចូលគ្នា ដោយមានការចូលរួមពីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

២.៦.១.២ លក្ខណៈវិនិច្ឆ័យទទួលបានក្រេឌីតតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនឹងទទួលខុសត្រូវចំពោះការផ្តល់ និងកត់ត្រាទុកចំនួនក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគ្រប់គ្រងក្រេឌីតដែលទទួលបានតាមរយៈកម្មវិធីទាំងអស់នៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

ក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំត្រូវបានផ្តល់ជូនដោយផ្អែកលើ៖

- ចំនួនម៉ោងដែលបានអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានរចនាសម្ព័ន្ធច្បាស់លាស់ឬដែលធ្វើដោយខ្លួនឯង ដោយជោគជ័យ
- ចំនួនម៉ោងស្វ័យសិក្សាដែលផ្សាភ្ជាប់នឹងចំនួនម៉ោងនៃអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ឬដែលធ្វើដោយខ្លួនឯង
- គុណភាព និងខ្លឹមសារនៃកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងសកម្មភាព រួមទាំងសមត្ថភាពដែលត្រូវបានលើកកម្ពស់ (បទដ្ឋាន និងស្តង់ដា)
- វង្វាយតម្លៃ (ការបង្ហាញលទ្ធផល)

សម្រាប់ព័ត៌មានលម្អិតពីប្រព័ន្ធក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សូមពិនិត្យមើលប្រព័ន្ធទទួលក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (ឆ្នាំ២០២០)។

<u>ចំនួនម៉ោងនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលបានអនុវត្តនិងទទួលស្គាល់ដោយជោគជ័យ</u>

ដោយសារការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជាដំណើរការសកម្ម មិនមែនជាដំណើរការអកម្ម ការចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលគឺមិនគ្រប់គ្រាន់ដើម្បីទទួលបានក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំឡើយ។ ដើម្បីធានាថាក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំត្រូវបានផ្តល់ជូនសម្រាប់ CPD មានគុណភាពល្អដែលសិក្ខាកាមបានចូលរួមយ៉ាងសកម្ម និងបានប្រើនៅក្នុងការអនុវត្តវិជ្ជាជីវៈរបស់ពួកគេ "ចំនួនម៉ោង" ដែលបានចូលរួមក្នុង CPD តែមួយមុខ មិនត្រូវបានគិតថាជាមូលដ្ឋានសមស្របដើម្បីទទួលបានក្រេឌីតរបស់ CPD ឡើយ៖ ដើម្បីទទួលបានក្រេឌីត CPD សកម្មភាព CPD ចាំបាច់ត្រូវបំពេញតាមបទដ្ឋាន (ស្តង់ដាអប្បបរមា) នៃគុណភាពនិងខ្លឹមសារ។ គ្រូបង្រៀនត្រូវបង្ហាញតាមរយៈការងារវាយតម្លៃទាំងលទ្ធផល និងការផ្លាស់ប្តូរវិជ្ជមាន ដែលអាចវាស់វែងបាន និងមានគុណភាពគ្រប់គ្រាន់ដើម្បីទទួលបានក្រេឌីត CPD ដែលបានអនុវត្ត។

គោលការណ៍ជាមូលដ្ឋាននៃការបែងចែកក្រេឌីត CPD គឺ សកម្មភាព CPD រួមមាន ការរៀនផ្ទាល់ចំនួន១៥ម៉ោងនិងស្វ័យសិក្សាចំនួន៣០ម៉ោង ឬនៅមន្ទីរពិសោធន៍ឬកិច្ចការនៅក្រៅសាលារៀនចំនួន៤៥ម៉ោង (ឬការរួមបញ្ចូលគ្នា) អនុលោមតាមស្តង់ដានៃគុណភាព និងលទ្ធផលដែលអាចវាស់វែងបាន នឹងទទួលបានមួយក្រេឌីត។

ក្នុងករណី CPD ធ្វើដោយខ្លួនឯង ដែលមិនរាប់បញ្ចូលពេលវេលារៀនផ្ទាល់ នេះត្រូវជំនួសដោយធាតុចូលបានមកពីប្រភពដែលមានការទទួលស្គាល់ដូចជា MOOC ទិនានុប្បវត្តិវិជ្ជាជីវៈ ឬសៀវភៅសិក្សា។ ដូច្នេះ សម្រាប់ CPD ធ្វើដោយខ្លួនឯងគឺមានគោលការណ៍ស្រដៀងគ្នានឹងសកម្មភាព CPD ដែលមានរយៈពេល ១៥ ម៉ោងនៃ "ធាតុចូល" ពីប្រភពដែលអាចទទួលយកបាន និង៣០ម៉ោងនៃការងារអនុវត្តដែលធ្វើដោយខ្លួនឯង ឬ

ការអនុវត្តជាតុចូល អនុលោមតាមស្តង់ដានៃគុណភាព និងលទ្ធផលដែលអាចវាស់វែងបាន នឹងទទួលបានមួយក្រេឌីត ដូចមានបង្ហាញក្នុងប្រអប់ ២.១។

ប្រអប់ ២.១ រូបមន្តនៃការផ្តល់ក្រេឌីត CPD

មួយក្រេឌីតនៃ CPD ត្រូវបានផ្តល់ជូន៖

- ១៥ម៉ោងរៀនផ្ទាល់ + ៣០ម៉ោង ស្វ័យសិក្សាឬការងារអនុវត្តធ្វើដោយខ្លួនឯង ការស្រាវជ្រាវ ឬការអនុវត្តអ្វីដែលបានរៀន
- ៤៥ម៉ោងនៅមន្ទីរពិសោធន៍ឬកិច្ចការនៅក្រៅសាលារៀន (ឬបញ្ចូលគ្នា) ឬ
- ១៥ម៉ោង នៃ "ជាតុចូល" ពីប្រភពដែលទទួលស្គាល់ + ៣០ម៉ោង ស្វ័យសិក្សាឬការងារអនុវត្តធ្វើដោយខ្លួនឯង ការស្រាវជ្រាវ ឬការអនុវត្តអ្វីដែលបានរៀន ឬ៤៥ម៉ោងនៅមន្ទីរពិសោធន៍ឬកិច្ចការនៅក្រៅសាលារៀន (ឬបញ្ចូលគ្នា)

រូបមន្តនៃការផ្តល់ក្រេឌីតនេះមានដូចគ្នានឹងរូបមន្តផ្តល់ក្រេឌីតនៃការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ដូចបានបញ្ជាក់ក្នុងប្រកាសលេខ ១៨៧០។ ក្នុងលក្ខខណ្ឌទាំងនេះ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន/គ្រឹះស្ថានឧត្តមសិក្សាដែលផ្តល់សកម្មភាព CPD ត្រូវការអនុវត្តបែបនេះដើម្បីទទួលបានការទទួលស្គាល់ពី CPDMO (សូមមើល CPD Handbook ឆ្នាំ២០២០ ស្តីពីការទទួលស្គាល់អ្នកផ្តល់សេវា និងការផ្តល់សេវា CPD) ដើម្បីធានាថា សកម្មភាពនិងក្រេឌីត CPD ឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនកម្ពុជា (ឆ្នាំ២០១០) ឬស្តង់ដាសមត្ថភាព CPD (ឆ្នាំ២០២០) ដើម្បីអនុញ្ញាតិឱ្យក្រេឌីត CPD អាចចូលរួមក្នុងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន។ ប្រព័ន្ធក្រេឌីត CPD នឹងអនុញ្ញាតឱ្យគ្រូបង្រៀនចូលរួមជាបន្តបន្ទាប់ក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានការទទួលស្គាល់ ដើម្បីទទួលបានកំណើនចំនួនក្រេឌីត ដូច្នេះពួកគេអាចដំឡើងគុណវុឌ្ឍិក្នុងរយៈពេលខ្លី។ ផ្នែកខាងក្រោមនេះរៀបរាប់លម្អិតអំពីរបៀបចំនួនក្រេឌីតដែលត្រូវផ្តល់ឱ្យសកម្មភាព CPD ទាក់ទងនឹងការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន។

<u>ការផ្តល់ក្រេឌីតសម្រាប់ CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់</u>

នៅពេលដែល CPD មានរចនាសម្ព័ន្ធច្បាស់លាស់ត្រូវបានអនុវត្តតាមរយៈអ្នកផ្តល់សេវា CPD ដែលមានការទទួលស្គាល់ដូចជា គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន/គ្រឹះស្ថានឧត្តមសិក្សា ទាំងនៅសាលារៀនឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន/គ្រឹះស្ថានឧត្តមសិក្សា អ្នកផ្តល់សេវានឹងជូនដំណឹងដល់អ្នកពាក់ព័ន្ធដែលទទួលខុសត្រូវក្នុងការបញ្ចូលព័ត៌មាន CPD ទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស (HRMIS) នូវបញ្ជីរាយនាមគ្រូបង្រៀនដែលបានអនុវត្តសកម្មភាព CPD ណាមួយដោយជោគជ័យ រួមមានកាលបរិច្ឆេទ ទីកន្លែង ពិន្ទុដែលទទួលបាន។ល។ ការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស អាចត្រូវបានអនុវត្តដោយសាលារៀន ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន/គ្រឹះស្ថានឧត្តមសិក្សា ការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ឬការិយាល័យគ្រប់គ្រង CPD អាស្រ័យលើទីតាំង និងកម្រិតនៃការតភ្ជាប់រវាងសាលារៀន។ ព័ត៌មានត្រូវបានបញ្ចូលក្នុងកម្រិតវិមជ្ឈការដែលអាចធ្វើបាន៖ នៅសាលារៀន ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន/គ្រឹះស្ថានឧត្តមសិក្សា។ ព័ត៌មាននេះត្រូវបានចាប់យកនៅក្នុងប្រព័ន្ធ

គ្រប់គ្រងព័ត៌មានធនធានមនុស្សដោយប្រើទម្រង់សមស្រប។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សបានបញ្ចូលព័ត៌មានពីអ្នកផ្តល់សេវា និងសកម្មភាព CPD ដែលត្រូវបានវាយតម្លៃដើម្បីឆ្លើយតបនឹងបទដ្ឋាន និងតម្រូវការ (សូមមើលសៀវភៅណែនាំ CPD ស្តីពីការទទួលស្គាល់គុណភាពអ្នកផ្តល់សេវានិងសកម្មភាព CPD) ។ ព័ត៌មានទាំងនេះនឹងបង្ហាញជាបញ្ជីទម្លាក់ចុះនៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស ។ នៅពេលដែលឈ្មោះគ្រូបង្រៀន ឬនាយកសាលាដែលបានអនុវត្តសកម្មភាព CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស ហើយព័ត៌មានត្រូវបានធ្វើឱ្យមានសុពលភាពនៅកម្រិតពាក់ព័ន្ធ នោះក្រេឌីត CPD នឹងលេចចេញនៅក្នុងប្រវត្តិរូបប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស (លិខិតឆ្លងដែនអាជីព) របស់គ្រូបង្រៀនឬនាយកសាលាម្នាក់ៗ។ ទីកន្លែងដែលព័ត៌មានក្រេឌីត CPD ត្រូវបានបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស នៅសាលារៀន ឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន/គ្រឹះស្ថានឧត្តមសិក្សា ការិយាល័យអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡា នឹងផ្តល់ QA នៃទិន្នន័យដែលបានបញ្ចូល៖ ពួកគេនឹងអនុវត្តការផ្ទៀងផ្ទាត់ទិន្នន័យ និងធ្វើការត្រួតពិនិត្យឯកសារដើម្បីធានាសុពលភាពនៃព័ត៌មានដែលបានបញ្ចូល។

ស្របពេលនេះដែរ នៅពេលបញ្ចប់ដោយជោគជ័យនូវចំណុចទាំងអស់នៃសកម្មភាព CPD ណាមួយ រួមទាំងការវាយតម្លៃ លិខិតឆ្លងដែនអាជីពរបស់គ្រូបង្រៀនឬនាយកសាលានឹងត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីបង្ហាញព័ត៌មាននេះ និងបោះត្រាដោយការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ឬការិយាល័យគ្រប់គ្រង CPD ។

<u>ការផ្តល់ក្រេឌីតសម្រាប់ CPD ដែលធ្វើដោយខ្លួនឯង</u>

នៅពេលដែល CPD ធ្វើដោយខ្លួនឯងត្រូវបានអនុវត្តនៅសាលារៀន សាលាកម្រង ឬកម្រិតសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) ផែនការសិក្សាផ្ទាល់ខ្លួនរបស់គ្រូបង្រៀនម្នាក់ៗត្រូវមានការព្រមព្រៀងជាមួយអ្នកត្រួតពិនិត្យរបស់ពួកគេ។ រចនាសម្ព័ន្ធបែបនេះត្រូវបានរៀបចំឡើងដើម្បីរាប់បញ្ចូលចំនួនម៉ោងដែលផ្តល់ឱ្យពីប្រភព CPD ធ្វើដោយខ្លួនឯង ដែលមានការទទួលស្គាល់ដូចជា MOOC ទិនានុប្បវត្តិ ជំពូកសៀវភៅដែលបានផ្តល់ឱ្យ។ល។ និងផែនការសម្រាប់ចំនួនម៉ោងស្វ័យសិក្សាឬការឆ្លុះបញ្ចាំងពីការអនុវត្ត តាមពីក្រោយដោយការរៀបចំលទ្ធផលដើម្បីបង្ហាញពីផលជះនៃ CPD ធ្វើដោយខ្លួនឯង។ ក្នុងអំឡុងពេលនៃការវាយតម្លៃប្រចាំឆ្នាំ គ្រូបង្រៀនឬនាយកសាលាបង្ហាញពីផលប័ត្រភស្តុតាងរបស់ពួកគេ បញ្ជាក់ថាពួកគេបានសម្រេចផែនការសិក្សាវិជ្ជាជីវៈដោយជោគជ័យ (ផែនការ CPD) រួមទាំងភស្តុតាងនៃផលជះ(លទ្ធផល) ។ ប្រសិនបើលទ្ធផលវាយតម្លៃមានលក្ខណៈវិជ្ជមាន អ្នកវាយតម្លៃបញ្ជាក់ពីចំនួនក្រេឌីត CPD ត្រូវទទួលបាន ហើយទំនាក់ទំនងព័ត៌មាននេះទៅការិយាល័យអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ឬការិយាល័យគ្រប់គ្រង CPDដែលនឹងបញ្ចូលព័ត៌មាននេះទៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សបានបញ្ចូលព័ត៌មានពីប្រភពដែលទទួលបានការទទួលស្គាល់សម្រាប់ CPD ធ្វើដោយខ្លួនឯង ដែលត្រូវបានវាយតម្លៃដើម្បីឆ្លើយតបនឹងបទដ្ឋាន និងតម្រូវការ (និងចន្លោះសម្រាប់ប្រភពដែលមិនទាន់ត្រូវបានទទួលស្គាល់ដើម្បីធ្វើសុពលភាពដោយផ្អែកលើបុគ្គលម្នាក់ៗ)។ នៅពេលដែលព័ត៌មានត្រូវបានធ្វើឱ្យមានសុពលភាពនៅកម្រិតពាក់ព័ន្ធ នោះក្រេឌីត CPD នឹងបង្ហាញនៅក្នុងប្រវត្តិរូបរបស់គ្រូបង្រៀនម្នាក់ៗ។

ស្របគ្នានឹងការវាយតម្លៃដោយជោគជ័យ លិខិតឆ្លងដែនអាជីពរបស់គ្រូបង្រៀន/នាយកសាលា (សៀវភៅកំណត់ហេតុCPD) នឹងត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីបង្ហាញព័ត៌មាននេះដែលមានហត្ថលេខារបស់អ្នកត្រួតពិនិត្យនិងបោះត្រា។ គ្រូបង្រៀន/នាយកសាលាជាអ្នករក្សាទុកលិខិតឆ្លងដែនអាជីពនេះ។

ការផ្តល់ក្រេឌីត CPD នឹងត្រូវគ្រប់គ្រងដោយ CPDMO ដែលនឹងទទួលស្គាល់សកម្មភាព CPD និងផ្តល់ក្រេឌីត CPD ដល់សកម្មភាពទាំងនេះ ផ្អែកលើប្រព័ន្ធទទួលក្រេឌីត CPD។ ប្រព័ន្ធទទួលក្រេឌីត CPDនឹងត្រូវអនុវត្តតាមលំដាប់លំដោយ ចាប់ផ្តើមពីក្រេឌីតសម្រាប់ CPD ដែលមានរចនាសម្ព័ន្ធច្បាស់លាស់នៅឆ្នាំ២០២០ និងបញ្ចូល CPD ធ្វើដោយខ្លួនឯងនៅឆ្នាំ២០២៥។ ដំបូង ក្រេឌីត CPD នឹងត្រូវផ្តល់ជូនដល់គ្រូបង្រៀន និងនាយកសាលាដែលចូលរួមក្នុងសកម្មភាព CPD ផ្តល់ដោយអ្នកផ្តល់សេវា CPD ដែលមានការទទួលស្គាល់ រាប់បញ្ចូលទាំងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដែលបច្ចុប្បន្នកំពុងដំណើរការកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន (ឧទាហរណ៍ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ) និងគម្រោងដៃគូអភិវឌ្ឍន៍ ដែលផ្តល់វគ្គវិក្រឹតការដូចជា STEPCam, SEIP, SBM និង USESDP-2។ សកម្មភាព CPD ក្រោមកម្មវិធីវិក្រឹតការដែលកំពុងដំណើរការនឹងត្រូវទទួលស្គាល់ឡើងវិញ។

គ្រូបង្រៀនដែលមានបំណងដំឡើងគុណវុឌ្ឍិ នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន/គ្រឹះស្ថានឧត្តមសិក្សា អាចប្រើក្រេឌីត CPD របស់គាត់សម្រាប់ការផ្ទេរក្រេឌីត ហើយតម្រូវឱ្យបង្ហាញភស្តុតាងនៃការបំពេញតាមតម្រូវការក្រេឌីតដោយផ្អែកលើស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន/គ្រឹះស្ថានឧត្តមសិក្សាគោលដៅ។ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន/គ្រឹះស្ថានឧត្តមសិក្សាដែលអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន អាចផ្ទៀងផ្ទាត់ក្រេឌីត CPD ដោយផ្អែកលើលិខិតឆ្លងដែនអាជីពបោះត្រារបស់គ្រូបង្រៀន និង/ឬកំណត់ត្រាអេឡិចត្រូនិកនៃ CPD នៅលើប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស រួមទាំងភស្តុតាងនៃលទ្ធផលដែលប្រមូលបានដោយគ្រូបង្រៀនខ្លួនឯង និងអនុញ្ញាតឱ្យផ្ទេរក្រេឌីត CPD ទៅកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនបន្ទាប់ពីការផ្ទៀងផ្ទាត់ដោយជោគជ័យ។

២.៦.១.៣ ការបង្កើនចំនួនគ្រូឧទ្ទេស

ដើម្បីបង្កើនចំនួនគ្រូឧទ្ទេសមានសមត្ថភាព ការជ្រើសរើសគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិដែលមានបរិញ្ញាបត្រជាន់ខ្ពស់ ជាជម្រើសដែលអាចធ្វើបាន។ ក្រសួងអប់រំ យុវជន និងកីឡាចាំបាច់ត្រូវបង្កើនកាំប្រាក់ដើម្បីទាក់ទាញបេក្ខភាពទាំងនោះឱ្យធ្វើជាគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យ។ បច្ចុប្បន្ននេះ គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិត្រូវបានចាត់ចូលក្នុងក្របខណ្ឌ ក គ្រូបង្រៀនកម្រិតមូលដ្ឋាន ក្របខណ្ឌ ខ និងគ្រូបឋមសិក្សាក្របខណ្ឌ គ។ ជម្រើសណាមួយក្នុងចំណោមជម្រើសទាំង៣ខាងក្រោម គួរត្រូវបានអនុវត្ត៖

- ជម្រើសទី១ (គោលដៅរយៈពេលវែង)៖ បង្កើនប្រាក់បៀវត្សមូលដ្ឋានរបស់គ្រូបង្រៀនដែលមានបរិញ្ញាបត្រ ឧទាហរណ៍គ្រូបង្រៀនបឋមសិក្សា និងមត្តេយ្យសិក្សាគួរត្រូវតម្លើងទៅក្របខណ្ឌ ខ (ដូរពីក្របខណ្ឌ គ) គ្រូបង្រៀនកម្រិតមូលដ្ឋានគួរត្រូវតម្លើងទៅ ក្របខណ្ឌ ក (ដូរពីក្របខណ្ឌ ខ)
- ជម្រើសទី២ (គោលដៅរយៈពេលមធ្យម)៖ បង្កើនប្រាក់បៀវត្សមូលដ្ឋានដល់គ្រូបង្រៀនដែលមានបរិញ្ញាបត្រ ឧទាហរណ៍ គ្រូបង្រៀនមានបរិញ្ញាបត្រដែលមានសមត្ថភាពនឹងត្រូវចាប់ផ្តើមពីកម្រិត

ពាក់កណ្តាល (កម្រិត ៦លើ១០) ខណៈគ្រូបង្រៀនដែលបញ្ចប់ការសិក្សា ១២+២ ត្រូវចាប់ផ្តើមពីកម្រិតទាប(កម្រិត ១លើ១០)

- ជម្រើសទី៣ (ជម្រើសផ្សេង)៖ ផ្តល់ឱកាសប្រសើរជាងនេះដល់គ្រូបង្រៀនមានបរិញ្ញាបត្រដែលមានសមត្ថភាពក្នុងការឡើងតំណែង។

២.៦.១.៤ ការណែនាំប្រព័ន្ធផ្តល់អាជ្ញាបណ្ណ

មានគំនិតជាច្រើនទាក់ទងនឹងការផ្តល់អាជ្ញាបណ្ណ។ គំនិតមួយក្នុងចំណោមគំនិតទាំងនេះគឺការផ្តល់ដល់គរុសិស្សដែលបញ្ចប់ការបណ្តុះបណ្តាល នូវឱកាសក្នុងការប្រឡងថ្នាក់ជាតិដើម្បីទទួលបានអាជ្ញាបណ្ណឬវិញ្ញាបនបត្រដែលប្រើប្រាស់បាននៅគ្រប់ខេត្ត ដែលមានក្នុងក្របខណ្ឌវេជ្ជបណ្ឌិតជាឧទាហរណ៍ស្រាប់។ គំនិតមួយទៀតគឺការផ្តល់វិញ្ញាបនបត្របង្រៀនដល់បេក្ខជន ដែលបញ្ចប់កម្មវិធីបណ្តុះបណ្តាលដោយជោគជ័យនៅគ្រឹះស្ថានឧត្តមសិក្សាឬគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ បន្ថែមលើនេះ ជម្រើសទី៣ដែលត្រូវបានប្រើដោយប្រទេសជាច្រើន គឺត្រូវបង្កើតក្រុមប្រឹក្សាគ្រូបង្រៀនថ្នាក់ជាតិឬស្ថាប័នវិជ្ជាជីវៈដែលប្រហាក់ប្រហែលនេះដើម្បីផ្តល់អាជ្ញាបណ្ណដល់គ្រូបង្រៀនដែលបានបំពេញតាមស្តង់ដាគុណវុឌ្ឍិ និងគុណភាព។ នេះគឺជាជំហានសំខាន់ក្នុងការធ្វើឱ្យការបង្រៀនជាអាជីពវិជ្ជាជីវៈដែលគ្រប់គ្រងដោយខ្លួនឯង។ ក្នុងករណីទាំងអស់នេះ បេក្ខជនជាគ្រូបង្រៀនឆ្លងកាត់ដំណើរការពិនិត្យ (ដើម្បីបញ្ចូលបទបង្ហាញនៃឯកសារ រួមមានភស្តុតាងគុណផលនៃការបង្រៀន សម្ភាស និង/ឬ ការប្រឡងសរសេរ) នៅកម្រិតថ្នាក់ជាតិឬខេត្តដើម្បីទទួលបានអាជ្ញាបណ្ណបង្រៀនដែលជាតម្រូវការមុនពេលត្រូវបានចាត់តាំងជាគ្រូបង្រៀននៅទីនោះ។

ភាពខុសគ្នាចម្បងរវាងជម្រើសទាំងពីរខាងលើនេះ គឺមធ្យោបាយក្នុងការគ្រប់គ្រងនូវគុណភាព។ ជម្រើសដំបូងទាមទារឱ្យមានការដឹកនាំរឹងមាំនៃរដ្ឋាភិបាលថ្នាក់ជាតិ ក្នុងការបង្កើតនូវស្តង់ដាវិជ្ជាជីវៈថ្នាក់ជាតិ និងធានាការបែងចែកគ្រូបង្រៀនប្រកបដោយសមភាព។ ឯជម្រើសក្រោយ ផ្តល់ការសម្រេចចិត្តកាន់តែច្រើនដល់ថ្នាក់ខេត្តក្នុងការជ្រើសរើស និងពង្រាយគ្រូបង្រៀន ដែលធ្វើឱ្យខេត្តនីមួយៗមានទំនួលខុសត្រូវជាងមុនលើគុណភាព និងលទ្ធផលនៃការអប់រំនៅក្នុងខេត្ត និងតម្រូវឱ្យរក្សានូវស្តង់ដាក្រមសីលធម៌ខ្ពស់ ដើម្បីជៀសវាងការប្រព្រឹត្តខុសនៅក្នុងដំណើរការជ្រើសរើសគ្រូបង្រៀន។

ប្រព័ន្ធបច្ចុប្បន្ននៅប្រទេសកម្ពុជាគឺដូចជាការផ្តល់អាជ្ញាបណ្ណថ្នាក់ជាតិជាង ទោះបីជាមិនមានវិញ្ញាបនបត្របង្រៀនផ្តល់ដល់គ្រូបង្រៀនម្នាក់ៗ និងមិនមានស្តង់ដាថ្នាក់ជាតិ ហើយដែលផ្អែកលើការប្រឡងបញ្ចប់របស់សាលាគរុកោសល្យ។ ក្រសួងអប់រំ យុវជន និងកីឡានឹងដាក់ចេញនូវប្រព័ន្ធផ្តល់អាជ្ញាបណ្ណជាបន្តបន្ទាប់ជាមួយនិងជម្រើសពីរដែលបានលើកឡើងខាងលើ។ មន្ទីរអប់រំ យុវជន និងកីឡាគួរតែជាស្ថាប័នចម្បងទទួលខុសត្រូវលើការផ្តល់វិញ្ញាបនបត្របង្រៀន ប៉ុន្តែត្រូវមានផែនការលម្អិតពីរបៀបចុះវិញ្ញាបនបត្របង្រៀនដោយការផ្សាភ្ជាប់ឱ្យបានល្អជាមួយប្រព័ន្ធទទួលស្គាល់គុណភាពអប់រំ។

២.៦.២ បញ្ហាប្រឈមសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង

២.៦.២.១ ការបន្តការផ្តត់ផ្គង់គ្រូឧទ្ទេស និងការអភិវឌ្ឍសមត្ថភាពវិទ្យាស្ថានគរុកោសល្យសម្រាប់កម្មវិធីដំឡើងគុណវុឌ្ឍិ

ជារួម វិទ្យាស្ថានគរុកោសល្យជាគ្រឹះស្ថានសាកសមក្នុងការផ្តល់នូវកម្មវិធីដំឡើងគុណវុឌ្ឍិ ព្រោះពួកគេបានអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលថ្មី ១២+៤និងកម្មវិធីសិក្សាលម្អិត និងអនុវត្តកម្មវិធីនេះក្នុងការបង្រៀន។

ទោះបីជាយ៉ាងណាក៏ដោយ វិទ្យាស្ថានគរុកោសល្យខ្វះបុគ្គលិកបង្រៀនច្រើនដែលអាចបំពេញគុណវុឌ្ឍិចង់បាន(បរិញ្ញាបត្រជាន់ខ្ពស់ឬបណ្ឌិត លើជំនាញគរុកោសល្យ ជំនាញលើការបង្រៀន និងភាសាអង់គ្លេស)។ បច្ចុប្បន្ន បុគ្គលិកបង្រៀននៅវិទ្យាស្ថានគរុកោសល្យត្រូវបានចែកជាបីថ្នាក់៖ គ្រូឧទ្ទេស គ្រូឧទ្ទេសរង និងគ្រូឧទ្ទេសជំនួយ។ គ្រូឧទ្ទេសរង និងគ្រូឧទ្ទេសជំនួយ ត្រូវបានលើកទឹកចិត្តឱ្យក្លាយខ្លួនជាគ្រូឧទ្ទេសតាមរយៈការអភិវឌ្ឍសមត្ថភាព ប៉ុន្តែវាត្រូវការពេលពីរ បីឆ្នាំ ឬច្រើនជាងនេះក្នុងការបង្កើនចំនួនគ្រប់គ្រាន់នៃគ្រូឧទ្ទេសដែលបំពេញជំនាញត្រូវការ។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡាគួរបន្តផ្តល់អាទិភាព ក្នុងការផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យដោយប្រើប្រាស់ទម្រង់ផ្សេងៗគ្នា ដែលទាក់ទងនឹងលក្ខខណ្ឌទាក់ទាញ និងឱកាសអភិវឌ្ឍវិជ្ជាជីវៈរួមមានកម្មវិធីក្រោយឧត្តមសិក្សាទាំងក្នុង និងក្រៅស្រុក។

២.៦.២.២ តម្រូវការរួមនៃគោលនយោបាយគ្រូបង្រៀនដើម្បីគាំទ្រ របៀបវារៈការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ចាំបាច់ត្រូវអនុវត្តតាមវិធីសាស្ត្ររួមមួយចំពោះវិជ្ជាជីវៈនៃការបង្រៀនដែលនឹងដោះស្រាយស្ថានភាពនៃឋានៈវិជ្ជាជីវៈគ្រូបង្រៀននិងនៅក្នុងសង្គមដែលត្រូវកែលម្អ និងត្រូវមានការទំនាក់ទំនងសមស្របដើម្បីគាំទ្រកិច្ចការនេះ។ នេះនឹងរួមបញ្ចូលកញ្ចប់វិធានការ និងគោលនយោបាយដើម្បីលើកកម្ពស់ភាពទាក់ទាញនៃវិជ្ជាជីវៈ និងគុណភាពរបស់គ្រូបង្រៀនរួមទាំងសិទ្ធិ និងកាតព្វកិច្ចចូលរួមក្នុងឱកាសនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ទទួលបានឱកាសរីកចម្រើនអាជីពតាមខ្សែបណ្តោយ និងទទឹង រង្វាន់បន្ថែមគណនេយ្យភាពរបស់គ្រូបង្រៀនកាន់តែមានច្រើនតាមរយៈការវាយតម្លៃជាទៀងទាត់ ការប្រើប្រាស់ស្តង់ដាវិជ្ជាជីវៈ និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត។ ផែនការសម្រាប់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន គួរតែមានទំនាក់ទំនងគ្នាយ៉ាងរលូនជាមួយប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ដែលកំពុងត្រូវបានអភិវឌ្ឍ និងអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា។ គំនិតផ្តួចផ្តើមគាំទ្រគ្នាទៅវិញទៅមកហើយអន្តរកម្មរបស់ពួកគេមានសារៈសំខាន់ក្នុងការដោះស្រាយសំណួរនៃគុណវុឌ្ឍិគ្រូបង្រៀននៅកម្ពុជា។

៣. ម៉ាទ្រិចផែនការសកម្មភាពដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

សកម្មភាពចម្បងៗ	ពេលវេលា	២០២១				២០២២				២០២៣				២០២៤				២០២៥				សូចនាករ (សំណើបណ្តោះអាសន្ន)	អង្គភាពទទួលខុសត្រូវ	ថវិកា (USD)	ដៃគូគាំទ្រ
		1	2	3	4	1	2	3	4	1	2	3	4	1	2	3	4	1	2	3	4				
យុទ្ធសាស្ត្រទី១៖ ពង្រឹងសមត្ថភាពដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត ១២+៤ នៅវិទ្យាស្ថានគរុកោសល្យ																									
១ បង្កើនកូតាចូលរៀនសម្រាប់វិទ្យាស្ថានគរុកោសល្យទាំង២																									
១.១ បង្កើនចំនួនគរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យបន្តិចម្តង រហូតដល់ចំនួន ៥០០នាក់សម្រាប់កម្រិតបឋម និង ៣០០នាក់សម្រាប់អនុវិទ្យាល័យ	២០២១-២០២៣																					-ចំនួនគរុនិស្សិតវិ. គរុ(១២+៤)(មបមនិងកម្រិតមូលដ្ឋាន) តាមឆ្នាំ	នា.បវ		
១.២ បញ្ឈប់ជាបណ្តើរៗការបណ្តុះបណ្តាល ១២+២នៅវិទ្យាស្ថានគរុកោសល្យ	២០២១-២០២៣																					-ចំនួនគរុនិស្សិតវគគ(១២+២) តាមឆ្នាំ	នា.បវ		
១.៣ ជ្រើសរើសបុគ្គលិកបង្រៀនដែលមានសមត្ថភាពសម្រាប់វិទ្យាស្ថានគរុកោសល្យ	២០២១-២០២៣																					-ចំនួនគ្រូឧទ្ទេសវគរ១២+៤ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមឆ្នាំ -សមាមាត្រគ្រូឧទ្ទេសដែលលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងចំនួនគ្រូឧទ្ទេសសរុបសម្រាប់កម្មវិធី១២+៤តាមឆ្នាំ	នា.បវ		
១.៤ រៀបចំនិងអនុវត្តវគ្គបណ្តុះបណ្តាលពីចម្ងាយ ១២+៤	២០២១-២០២៣																					-សម្ភារៈវគ្គសិក្សាពីចម្ងាយសម្រាប់កម្មវិធី ១២+៤	វគរ (ដឹកនាំ) គាំទ្រដោយ សភភព វជអ		

សកម្មភាពចម្បងៗ	ពេលវេលា	២០២១				២០២២				២០២៣				២០២៤				២០២៥				សូចនាករ (សំណើបណ្ដោះអាសន្ន)	អង្គភាពទទួលខុសត្រូវ	ថវិកា (USD)	ដៃគូគាំទ្រ
		1	2	3	4	1	2	3	4	1	2	3	4	1	2	3	4	1	2	3	4				
១.៤.១ ជ្រើសរើសសាលាគរុកោសល្យរណបនិងគ្រូឧទ្ទេសសាលាគរុកោសល្យដែលមានសមត្ថភាព	២០២១																					-លទ្ធផលនៃការជ្រើសរើសសាលាគរុកោសល្យរណប -លទ្ធផលនៃការជ្រើសរើសគ្រូឧទ្ទេសសាលាគរុ.ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់	នា.បវ		
១.៤.២ អភិវឌ្ឍវគ្គសិក្សាពីចម្ងាយ	២០២២																					-បន្ទប់សិក្សាពីចម្ងាយចំនួន៨ត្រូវបានដំឡើង -ក្របខណ្ឌកម្មវិធីសិក្សាពីចម្ងាយត្រូវបានអភិវឌ្ឍ -កម្មវិធីសិក្សាលម្អិតពីការសិក្សាពីចម្ងាយត្រូវបានអភិវឌ្ឍ -សម្ភារៈឧបទេសសម្រាប់ការសិក្សាពីចម្ងាយត្រូវបានអភិវឌ្ឍ -កម្មវិធីសម្រាប់ការសិក្សាពីចម្ងាយត្រូវបានអភិវឌ្ឍ	វគរ (ដឹកនាំ) គាំទ្រដោយ សភភព វជអ	៦៨៧,៩០០	
១.៤.៣ ផ្ដល់ការបណ្ដុះបណ្ដាលដល់គ្រូឧទ្ទេសដែលទទួលបន្ទុកការបណ្ដុះបណ្ដាលពីចម្ងាយ	២០២២																					-គ្រូឧទ្ទេសចំនួន៥០នាក់ដែលត្រូវបង្រៀនពីចម្ងាយទទួលការបំប៉ន	វគរ (ដឹកនាំ) នា.បវ	១៤០,០០០	
១.៤.៤ ចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាលពីចម្ងាយ	២០២៣ -																					-វគ្គសិក្សាពីចម្ងាយលើមុខវិជ្ជាឯកទេសចំនួន១១ (គរុនិស្សិតចំនួន២៥នាក់សម្រាប់	វគរ (ដឹកនាំ) នា.បវ	១,៨៤៨,៦០០	

សកម្មភាពចម្បងៗ	ពេលវេលា	២០២១				២០២២				២០២៣				២០២៤				២០២៥				សូចនាករ (សំណើបណ្តោះអាសន្ន)	អង្គភាពទទួលខុសត្រូវ	ថវិកា (USD)	ដៃគូគាំទ្រ
		1	2	3	4	1	2	3	4	1	2	3	4	1	2	3	4	1	2	3	4				
																						ឯកទេសនីមួយៗ) ត្រូវបានអនុវត្តដោយមានការជ្រើសរើសគរុនិស្សិតបន្ថែមសម្រាប់៣ឆ្នាំ -កម្មសិក្សាគរុកោសល្យរបស់គរុនិស្សិតសិក្សាពីចម្ងាយត្រូវបានវាយតម្លៃនិងរាយការណ៍ -របាយការណ៍ត្រួតពិនិត្យនិងលទ្ធផលនៃការវាយតម្លៃពីការអនុវត្តវគ្គសិក្សាពីចម្ងាយត្រូវបានរៀបចំ			
២ បង្កើនចំនួនវិទ្យាស្ថានគរុកោសល្យ																							ក្រ.អយក		
២.១ កំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់វិទ្យាស្ថានគរុកោសល្យបន្ទាប់ និងជ្រើសរើសសាលាគរុកោសល្យដែលមានសក្តានុពល	២០២២																					-លក្ខណៈវិនិច្ឆ័យសម្រាប់ការបើកវគរបន្ទាប់ -លទ្ធផលនៃការជ្រើសរើសសាលាគរុ.	វគរ (ដឹកនាំ) នា.បវ		
២.២ ពិនិត្យឡើងវិញកម្មវិធីបណ្តុះបណ្តាលរបស់សាលាគរុកោសល្យដើម្បីឱ្យស្របទៅនឹងស្តង់ដាកម្មវិធីបណ្តុះបណ្តាលរបស់វិទ្យាស្ថានគរុកោសល្យ	២០២៣																					-កម្មវិធីបណ្តុះបណ្តាលរបស់សាលា.គរុដែលបានពិនិត្យឡើងវិញស្របគ្នាជាមួយកម្មវិធីរបស់វគរ	វគរ (ដឹកនាំ) នា.បវ		
២.៣ រៀបចំសាលាគរុកោសល្យខាងលើឱ្យក្លាយជាវិទ្យាស្ថានគរុកោសល្យ	២០២៣ -២០២៤																					-ផែនការជួសជុលឬលទ្ធកម្មសម្ភារៈផ្សេងៗ	នា.បវ		

សកម្មភាពចម្បងៗ	ពេលវេលា	២០២១				២០២២				២០២៣				២០២៤				២០២៥				សូចនាករ (សំណើបណ្ណោះអាសន្ន)	អង្គភាពទទួលខុសត្រូវ	ថវិកា (USD)	ដៃគូគាំទ្រ
		1	2	3	4	1	2	3	4	1	2	3	4	1	2	3	4	1	2	3	4				
																						-ផែនការជ្រើសរើសគណៈគ្រប់គ្រងនិងគ្រូឧទ្ទេសដែល -មានលក្ខណៈសម្បត្តិគ្រប់គ្រាន់			
២.៣.១ បង្កើតវិទ្យាស្ថានគរុកោសល្យថ្មីផ្លូវការដោយអនុក្រឹត្យ	២០២៣																					-អនុក្រឹត្យបង្កើតវគរថ្មី	នា.បវ		
២.៣.២ ជ្រើសរើស តែងតាំង និងបណ្តុះបណ្តាលគណៈគ្រប់គ្រងនៃវិទ្យាស្ថានគរុកោសល្យថ្មី	២០២៣-២០២៤																					-លក្ខណៈវិនិច្ឆ័យជ្រើសរើស លទ្ធផល និងការតែងតាំងគណៈគ្រប់គ្រង -កម្មវិធីបំប៉នគណៈគ្រប់គ្រង ចំនួនគណៈ -គ្រប់គ្រងដែលបានទទួលការបំប៉ន	នា.បវ		
២.៣.៣ ជ្រើសរើសនិងបណ្តុះបណ្តាលបុគ្គលិកបង្រៀននៃវិទ្យាស្ថានគរុកោសល្យថ្មី	២០២៤-២០២៥																					-លក្ខណៈវិនិច្ឆ័យជ្រើសរើស លទ្ធផល និងការតែងតាំងគ្រូឧទ្ទេស -ចំនួនវគ្គបំប៉នគ្រូឧទ្ទេស	វគរ នា.បវ ម.អយក		
២.៣.៤ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងរៀបចំសម្ភារៈសម្រាប់វិទ្យាស្ថានគរុកោសល្យថ្មី	២០២៤-២០២៥																					-ការសាងសង់/ការជួសជុលវគរថ្មី -បញ្ជីសម្ភារៈសម្រាប់វគរ	នា.បវ នា.ផក មអយក	ប្រហែល ៣០លាន សម្រាប់វគរ ចំនួន២	

សកម្មភាពចម្បងៗ	ពេលវេលា	២០២១				២០២២				២០២៣				២០២៤				២០២៥				សូចនាករ (សំណើបណ្ណោះអាសន្ន)	អង្គភាពទទួលខុសត្រូវ	ថវិកា (USD)	ដៃគូគាំទ្រ
		1	2	3	4	1	2	3	4	1	2	3	4	1	2	3	4	1	2	3	4				
២.៤ ចាប់ផ្តើមបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត ១២+៤ នៅវិទ្យាស្ថានគរុកោសល្យថ្មី	២០២៥-																					-ចំនួនកម្មវិធីដែលបានអនុវត្ត -ទិន្នន័យគ្រូបង្រៀនដែលបានធ្វើបច្ចុប្បន្នភាព -របាយការណ៍ត្រួតពិនិត្យឬលទ្ធផលនៃការវាយតម្លៃនៃការអនុវត្តកម្មវិធី១២+៤ថ្មី	វគរ នា.បវ ម.អយក		
យុទ្ធសាស្ត្រទី២៖ ការបណ្តុះបណ្តាលបរិញ្ញាបត្រ+១ ដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់																									
១ ធ្វើការស្ទង់មតិខ្នាតតូចសម្រាប់ការវិភាគតម្រូវការ																									
១.១ រៀបចំនិងធ្វើការស្ទង់មតិ និងវិភាគតម្រូវការនៃបរិញ្ញាបត្រ+១ សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន	២០២១																					-ឯកសារទស្សនទាននៃការស្ទង់មតិពីតម្រូវការឬផែនការស្ទង់មតិ -របាយការណ៍ការស្ទង់មតិពីតម្រូវការ	នា.បវ		
១.២ ជ្រើសរើសខេត្តគោលដៅសម្រាប់ការបណ្តុះបណ្តាលបរិញ្ញាបត្រ+១សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន	២០២១																					-លក្ខណៈវិនិច្ឆ័យនិងលទ្ធផលនៃការជ្រើសរើស -ចំនួនខេត្តគោលដៅនិងគ្រូដែលត្រូវបំប៉ន	នា.បវ		
២ អនុវត្តការបណ្តុះបណ្តាល បរិញ្ញាបត្រ+១ សម្រាប់គ្រូបង្រៀនកម្រិតមូលដ្ឋាន																									
២.១ ជ្រើសរើសគ្រឹះស្ថានបណ្តុះបណ្តាល បរិញ្ញាបត្រ+១ (វិទ្យាស្ថានជាតិអប់រំឬវិទ្យាស្ថានគរុកោសល្យ) និងកំណត់កូតាសម្រាប់ការសាកល្បង បរិញ្ញាបត្រ+១	២០២១																					-ការវាយតម្លៃសមត្ថភាពអ្នកផ្តល់សេវា (វដអឬវគរ)	នា.បវ		

សកម្មភាពចម្បងៗ	ពេលវេលា	២០២១				២០២២				២០២៣				២០២៤				២០២៥				សូចនាករ (សំណើបណ្តោះអាសន្ន)	អង្គភាពទទួលខុសត្រូវ	ថវិកា (USD)	ដៃគូគាំទ្រ
		1	2	3	4	1	2	3	4	1	2	3	4	1	2	3	4	1	2	3	4				
២.២ អភិវឌ្ឍកម្មវិធីបរិញ្ញាបត្រ+១ ឱ្យស្របជាមួយស្តង់ដាកម្មវិធីបណ្តុះបណ្តាលវិទ្យាស្ថានគរុកោសល្យ	២០២២																					-កម្មវិធីបរិញ្ញាបត្រ+១ស្របជាមួយស្តង់ដាកម្មវិធីបណ្តុះបណ្តាលរបស់វគរ	វជអ (ដឹកនាំ) គាំទ្រដោយ វគរ/ សភគព		
២.៣ អនុវត្តការបណ្តុះបណ្តាល បរិញ្ញាបត្រ+១ លើមូលដ្ឋានសាកល្បង	២០២២-																					-ទិន្នន័យគ្រូបង្រៀនបានបំប៉នដែលបានធ្វើបច្ចុប្បន្នភាព -របាយការណ៍ត្រួតពិនិត្យឬលទ្ធផលវាយតម្លៃនៃការអនុវត្តកម្មវិធីបរិញ្ញាបត្រ+១	វជអ (ដឹកនាំ) គាំទ្រដោយ វគរ/ សភគព		
យុទ្ធសាស្ត្រទី ៣៖ បង្កើតយន្តការក្នុងការដំឡើងគុណវុឌ្ឍិតាមរយៈកម្មវិធីបណ្តុះបណ្តាលរយៈពេលវែង																									
១ អភិវឌ្ឍកម្មវិធីរយៈពេលវែង																									
១.១ រៀបចំកញ្ចប់ម៉ូឌុលសម្រាប់កម្មវិធី៦០ក្រេឌីតដោយយោងតាមប្រកាសលេខ១៨៧០ និងការប្រើប្រាស់ឯកសារវគ្គសិក្សារបស់វិទ្យាស្ថានគរុកោសល្យ	២០២១																					-ម៉ូឌុលនៃកម្មវិធី ៦០ក្រេឌីត	សភគព (ដឹកនាំ) វជអ វគរ នា.បវ		
១.២ អភិវឌ្ឍផែនការលម្អិតសម្រាប់កម្មវិធីមានកាលកំណត់ និងកម្មវិធីគ្មានកាលកំណត់ ដែលមានព័ត៌មានដូចជា៖ ក្រុមគោលដៅ ចំនួនសិក្ខាកាម គ្រឹះស្ថានអនុវត្តន៍ របៀបបង្រៀន លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសនិងនីតិវិធី ពេលវេលា	២០២១																					-ផែនការលម្អិតសម្រាប់កម្មវិធីមិនប្រែប្រួលនិងបើកចំហ	សភគព (ដឹកនាំ) វជអ វគរ នា.បវ		

សកម្មភាពចម្បងៗ	ពេលវេលា	២០២១				២០២២				២០២៣				២០២៤				២០២៥				សូចនាករ (សំណើបណ្តោះអាសន្ន)	អង្គភាពទទួលខុសត្រូវ	ថវិកា (USD)	ដៃគូគាំទ្រ
		1	2	3	4	1	2	3	4	1	2	3	4	1	2	3	4	1	2	3	4				
អនុវត្តន៍ ។ល។																									
១.៣ រៀបចំផែនការថវិកា និងកៀរគរការគាំទ្រហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍	២០២១- ២០២២																					-ផែនការថវិកាតាមកម្មវិធីនីមួយៗ -សំណើហិរញ្ញវត្ថុដើម្បីទទួលបានមូនិធិពីដៃគូអភិវឌ្ឍន៍	សភកព (ដឹកនាំ) វជអ វគរ នា.បវ		ផ្នែកមួយ GEIP SIEP សម្រាប់អនុវិ
១.៤ រៀបចំគ្រូឧទ្ទេស និងសម្ភារៈបណ្តុះបណ្តាល	២០២២																					-សម្ភារៈបំប៉នសម្រាប់គ្រូឧទ្ទេស	សភកព (ដឹកនាំ) វជអ វគរ នា.បវ		ផ្នែកមួយ GEIP SIEP សម្រាប់អនុវិ
២ អនុវត្តកម្មវិធីមានកាលកំណត់																									
២.១ ជ្រើសរើសអ្នកចូលរួមក្នុងការបណ្តុះបណ្តាល	២០២២																					-លក្ខណៈវិនិច្ឆ័យជ្រើសរើសសិក្ខាកាម -បញ្ជីឈ្មោះសិក្ខាកាម	នា.បវ មអយក		
២.២ ចាប់ផ្តើមអនុវត្តកម្មវិធីរយៈពេលវែង	២០២២-																					-ទិន្នន័យគ្រូបង្រៀនបានបំប៉នដែលបានធ្វើបច្ចុប្បន្នភាព -របាយការណ៍ត្រួតពិនិត្យឬលទ្ធផលវាយតម្លៃនៃការអនុវត្តកម្មវិធីរយៈពេលវែង	វជអ វគរ សភកព	៤,២៥២,៥០០	ថវិកាសម្រាប់បឋម

សកម្មភាពចម្បងៗ	ពេលវេលា	២០២១				២០២២				២០២៣				២០២៤				២០២៥				សូចនាករ (សំណើបណ្ណោះអាសន្ន)	អង្គភាពទទួលខុសត្រូវ	ថវិកា (USD)	ដៃគូគាំទ្រ
		1	2	3	4	1	2	3	4	1	2	3	4	1	2	3	4	1	2	3	4				
																									និង អនុវិ
៣ ចាប់ផ្តើមអនុវត្តកម្មវិធីគ្មានកាលកំណត់	២០២២-																					-ទិន្នន័យគ្រូបង្រៀនបានបំប៉នដែលបានធ្វើបច្ចុប្បន្នភាព -របាយការណ៍ត្រួតពិនិត្យឬលទ្ធផលវាយតម្លៃនៃការអនុវត្តកម្មវិធីបើកចំហ	ជអ វគរ សភកព នា.បវ		
យុទ្ធសាស្ត្រទី ៤៖ ជំរុញគ្រូបង្រៀន ១២+២ ដែលមានសញ្ញាបត្របរិញ្ញាបត្រចូលរួមក្នុងការដំឡើងគុណវុឌ្ឍិតាមរយៈកម្មវិធីបណ្តុះបណ្តាលរយៈខ្លីៗ																									
១ អភិវឌ្ឍកម្មវិធីរយៈពេលខ្លី																									
១.១ រៀបចំកញ្ចប់ម៉ូឌុលសម្រាប់កម្មវិធី៣០ក្រេឌីតដោយយោងតាមប្រកាសលេខ១៨៧០ និងការប្រើប្រាស់ឯកសារវគ្គសិក្សារបស់វិទ្យាស្ថានគរុកោសល្យ	២០២១																					-ម៉ូឌុលនៃកម្មវិធី ៣០ក្រេឌីត	សភកព (ដឹកនាំ) វជអ វគរ នា.បវ		
១.២ អភិវឌ្ឍផែនការលម្អិតដែលមានព័ត៌មានដូចជា៖ ក្រុមគោលដៅ ចំនួនសិក្ខាកាមគ្រឹះស្ថានអនុវត្តន៍ របៀបបង្រៀន លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសនិងនីតិវិធី ពេលវេលាអនុវត្តន៍ ។ល។	២០២១																					-ផែនការលម្អិតសម្រាប់កម្មវិធីរយៈពេលវែង	សភកព (ដឹកនាំ) វជអ វគរ នា.បវ		
១.៣ រៀបចំផែនការថវិកានិងកៀរគរការគាំទ្រហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍	២០២១-២០២២																					-ផែនការថវិកាតាមកម្មវិធីនីមួយៗ -សំណើហិរញ្ញវត្ថុដើម្បីទទួលបានមូនិធិពីដៃគូអភិវឌ្ឍន៍	សភកព (ដឹកនាំ) វជអ វគរ នា.បវ		

សកម្មភាពចម្បងៗ	ពេលវេលា	២០២១				២០២២				២០២៣				២០២៤				២០២៥				សូចនាករ (សំណើបណ្តោះអាសន្ន)	អង្គភាពទទួលខុសត្រូវ	ថវិកា (USD)	ដៃគូគាំទ្រ
		1	2	3	4	1	2	3	4	1	2	3	4	1	2	3	4	1	2	3	4				
១.៤ រៀបចំគ្រូឧទ្ទេស និងសម្ភារៈបណ្តុះបណ្តាល	២០២២																					-សម្ភារៈបំប៉នសម្រាប់គ្រូឧទ្ទេស	សភកព (ដឹកនាំ) វជអ វគរ នា.បវ		
២ អនុវត្តកម្មវិធីរយៈពេលខ្លី																									
២.១ ជ្រើសរើសអ្នកចូលរួមការបណ្តុះបណ្តាល	២០២២																					-លក្ខណៈវិនិច្ឆ័យជ្រើសរើសសិក្ខាកាម -បញ្ជីឈ្មោះសិក្ខាកាម	នា.បវ មអយក		
២.២ ចាប់ផ្តើមអនុវត្តកម្មវិធីរយៈពេលខ្លី	២០២២-																					-ទិន្នន័យគ្រូបង្រៀនបានបំប៉នដែលបានធ្វើបច្ចុប្បន្នភាព -របាយការណ៍ត្រួតពិនិត្យឬលទ្ធផលវាយតម្លៃនៃការអនុវត្តកម្មវិធីរយៈពេលខ្លី	វជអ វគរ សភកព	៤,៦៧៧,៧៥០	ថវិកាសម្រាប់បឋម និង អនុវិ

បម្កាល់៖ព័ត៌មានដូចជា សូចនាករ អង្គភាពទទួលខុសត្រូវ និងដៃគូគាំទ្រគ្រាន់តែជាសំណើនិងបណ្តោះអាសន្ន។ ព័ត៌មានលម្អិតត្រូវបំពេញដោយក្រ.អយកនៅដំណាក់កាលបន្ទាប់។

ឯកសារយោង

ជំពូកទី១

BernardJean-Marc, TiyabKB, , VianouK. Profils enseignants et qualité de l'éducation primaire en Afrique subsaharienne francophone. Dakar: CONFEMEN, 2004.

Darling-HammondLinda. Teacher education around the world: What can we learn from international practice? Routledge, 2017, VOL. 40, NO. 3, 291–309.

Fasli JalalSamani, Mae Chu Chang, Ritchie Stevenson, Andrew B Ragatz, Siwage D NegaraMuchlas. "Teacher Certification in Indonesia: A Strategy for Teacher Quality Improvement." 2009. https://pdfs.semanticscholar.org/df3d/2786622e159d2bd7b9598b4610fbebdd0ca3.pdf.

Global Partnership for Education (GPE). "Improving Teaching and Learning: The knowledge and Innovation Exchanging (KIX) Discussion Paper." 2019. https://www.globalpartnership.org/sites/default/files/2019-07-kix-tl-final-english.pdf.

Global Partnership for Education "Results Report 2019." 2019. https://www.globalpartnership.org/content/results-report-2019.

Ingvarson, L. "Development of a National Standards Framework for the Teaching Profession." 2002. https://research.acer.edu.au/cgi/viewcontent.cgi?article=1007&context=teaching_standards

Ingersoll M.Richard. "A Comparative Study of Teacher Preparation and Qualifications in Six Nations." 2007. https://files.eric.ed.gov/fulltext/ED498318.pdf.

International Reading Association. Status of Teacher Education in the Asia-Pacific Region. UNESCO, 2008.

Jawawi, R. et al. (2014). Teacher education in Brunei Darussalam: Transforming tomorrow's generation through teacher education today. http://digilib.uin-suka.ac.id/19316/1/01.%20ROSMAWIJAH%20JAWAWI,%20DKK%20-%20TEACHER%20EDUCATION%20IN%20BRUNEI%20DARUSSALAM%20TRANSFORMING%20TOMORROWS%20GENERATION%20THROUGH%20TEACHER%20EDUCATION%20TODAY.pdf

JICA. "Report of Basic Study for Project for Improving Teaching and Learning Mathematics for Primary Education in Laos." 2015.

MoEYS. Education Statistics and Indicators 2014-2015. Cambodia: Ministry of Education, Youth and Sport, 2015.

MoEYS. Education Statistics and Indicators 2015-2016. Cambodia: Ministry of Education, Youth and Sport, 2016.

MoEYS. Education Statistics and Indicators 2016-2017. Cambodia: Ministry of Education, Youth and Sport, 2017.

MoEYS. Education Statistics and Indicators 2017-2018. Cambodia: Ministry of Education, Youth and Sport, 2018.

MoEYS. Education Statistics and Indicators 2018-2019. Cambodia: Ministry of Education, Youth and Sport, 2019.

MoEYS. Education Strategic Plan 2014-2018. Cambodia: Ministry of Education, Youth and Sport, 2014.

MoEYS. Education Strategic Plan 2019-2023. Cambodia: Ministry of Education, Youth and Sport, 2019.

MoEYS. Teacher Policy. Cambodia: Ministry of Education, Youth and Sport, 2013.

MoEYS. Teacher Policy Action Plan. Cambodia: Ministry of Education, Youth and Sport, 2015.

MoyleKathryn. "Global Trends in Higher Education Policies." 2015. https://research.acer.edu.au/cgi/viewcontent.cgi?article=1016&context=teacher_education.

Musset P. Initial Teacher Education and Continuing Training Policies in a Comparative Perspective: Current Practices in OECD Countries and a Literature Review on Potential Effects. OECD Education Working Papers No.48, 2010.

Naron Chuon Hang. "Moving Toward Digital Education." Power point handout, 2019.

Nguyen T.H. "Teacher Training in Vietnam." 2008. http://www.hurights.or.jp/pub/hreas/.

Nomura, J. et al. "Teacher Education Curriculum: A Comparative Study across Asia and ASEAN." 2019. http://twincle.e.chiba-u.jp/jpn/news/2019/02/20190215.pdf.

OECD. Teachers Matter: Attracting, Developing, and Retaining Effective Teachers. OECD, 2005.

OECD. 21st Century Skills and Competences for New Millennium Learners in OECD Countries. OECD, 2009.

OECD. "Building a Teaching Profession: Lessons from around the World." 2011. https://files.eric.ed.gov/fulltext/ED518775.pdf.

OECD/UNESCO. " Education in Thailand: An OECD-UNESCO Perspective, Reviews of National Policies for Education", OECD Publishing, Paris, 2016.

OECD. Education Policy Outlook 2015: Making Reforms Happen. OECD Publishing, 2015.

OECD. "Teaching in Focus No.11: Supporting New Teachers." 2015.

OECD. "The Future of Education and Skills: Education 2030." 2018.

https://www.oecd.org/education/2030/E2030%20Position%20Paper%20(05.04.2018).pdf. *http://dx.doi.org/10.1787/9789264259119-en*

UNESCO. "EFA Global Monitoring Report 2003/4: Quality Imperative." 2004. https://unesdoc.unesco.org/ark:/48223/pf0000137333.

UNESCO. "Handbook on Education Policy Analysis and Programming. Vol.1., Education Policy Analysis." 2013. https://unesdoc.unesco.org/ark:/48223/pf0000221189.

UNESCO. "EFA Global Monitoring Report 2013/4: Teaching and Learning: Achieving Quality for All." 2014. https://unesdoc.unesco.org/ark:/48223/pf0000225660.

UNESCO. "Education Systems in ASEAN+6 Countries: A Comparative Analysis of Selected Educational Issues (Discussion Document No.5)." 2015.

UNESCO Institute for Statistics (UIS). "Teachers and Educational Quality: Monitoring Global Needs for 2015." 2006. http://uis.unesco.org/sites/default/files/documents/teachers-and-educational-quality-monitoring-global-needs-for-2015-en_0.pdf.

Wang, A. Coleman, et al. "Preparing Teachers Around the World". Educational Testing Service. 2003. https://www.ets.org/Media/Research/pdf/PICPRETEACH.pdf

World Bank. Secondary Education in Africa: At the Cross Roads: Choices for Secondary Education and Training in Sub-Saharan Africa. Washington D.C.: SEIA and the World Bank, 2007.

World Bank. "SABER–Teachers: Objectives, Rationale, Methodological Approach, and Products." 2011. http://siteresources.worldbank.org/EDUCATION/Resources/278200-1290520949227/7575842-1290520985992/SABER-Teachers_Framework.pdf.

World Bank. "What Matters Most for Teacher Policies: A Framework Paper. SABER Working Paper Series." 2013. http://documents.worldbank.org/curated/en/503591468331856077/pdf/901820NWP0no4000Box385307B00PUBLIC0.pdf.

World Bank. Educating the Next Generation: Improving Teacher Quality in Cambodia. Phnom Penh: The World Bank, 2014.

World Bank. Indonesia: Teacher Certification and Beyond - An empirical evaluation of the teacher certification program and education quality improvements in Indonesia. World Bank, 2015.

ជំពូកទី២

JICA E-TEC. "Teacher Education Subsector Analysis Report: For the strategic upgrade of basic teacher qualifications to the degree level." 2019.

MoEYS. Education Statistics & Indicators 2007/8-2018/19

MoEYS." Education Congress, The Education, Youth and Sport Performance in the Academic Year 2015-2016." 2017.

MoEYS. "Education Congress, The Education, Youth and Sport Performance in the Academic Year 2014-2015." 2016.

MoEYS. "Teacher Policy Action Plan." 2015.

MoEYS," Curriculum Framework of General Education and Technical Education." 2015.

MoEYS. "Directive on Standard of the Usage of Educational Personnel, No. 33." 2014.

MoEYS. "Education Strategic Plan 2014-2018." 2014.

National Institute of Statistics, Ministry of Planning. "General Population Census of Cambodia 2008." 2011.

National Institute of Statistics, Ministry of Planning. "Population Projection of Cambodia 2013-2023." 2017.

World Bank (2020). Cambodia in the time or COVID-19: Special Focus Teacher Accountability and Student Learning Outcomes". 2020.